ក្រសួងអប់រំ យុវជន និងកីឡា

Ministry of Education, Youth and Sport

វិទ្យាស្ថានជាតិអប់រំ

National Institute of Education

# និក្ខេបបទ

# ស្ថានភាពនៃការអនុវត្តគោលការណ៍អភិបាលកិច្ច
# នៅសាលារៀនជំនាន់ថ្មីនៅរាជធានីភ្នំពេញ

# THE IMPLEMENTATION OF EDUCATION GOVERNANCE AT NEW GENERATION SCHOOLS IN PHNOM PENH

ដោយ/By

**គៀត គឹក**

KEAT KOEK

**ដើម្បីបំពេញលក្ខខណ្ឌបញ្ចប់ការបណ្តុះបណ្តាល**
**ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី១០**

**ឯកទេសៈ គ្រប់គ្រងអប់រំ**

**ឆ្នាំសិក្សា ២០២១-២០២៣**

ក្រសួងអប់រំ យុវជន និងកីឡា
Ministry of Education, Youth and Sport

វិទ្យាស្ថានជាតិអប់រំ
National Institute of Education

# និក្ខេបបទ

# ស្ថានភាពនៃការអនុវត្តគោលការណ៍អភិបាលកិច្ច នៅសាលារៀនជំនាន់ថ្មីនៅរាជធានីភ្នំពេញ

# THE IMPLEMENTATION OF EDUCATION GOVERNANCE AT NEW GENERATION SCHOOLS IN PHNOM PENH

ឈ្មោះនិស្សិត ៖ គៀត គឹក / KEAT KOEK

ដើម្បីបំពេញលក្ខខណ្ឌបញ្ចប់ការបណ្តុះបណ្តាល
ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី១០
ឯកទេស៖ គ្រប់គ្រងអប់រំ

ឆ្នាំសិក្សា ២០២១-២០២៣

គ្រូណែនាំគោល៖ លោក ម៉ៅ សារឿន
គ្រូណែនាំរង៖ លោកបណ្ឌិត អាន វ៉ូប្រាថ

# សេចក្ដីអះអាងរបស់បេក្ខជន

ខ្ញុំបាទ **គៀត គឹក** សូមបញ្ជាក់ថានិក្ខេបបទស្រាវជ្រាវដែលមានចំណងជើងថា «**ស្ថានភាពនៃការអនុវត្តគោលការណ៍អភិបាលកិច្ចនៅសាលារៀនជំនាន់ថ្មីនៅរាជធានីភ្នំពេញ**» សម្រាប់បំពេញលក្ខខណ្ឌសញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំនៅវិទ្យាស្ថានជាតិអប់រំ ពិតជាស្នាដៃរបស់ខ្ញុំបាទទាំងស្រុង។ ស្នាដៃនេះពុំទាន់បានប្រើប្រាស់ដើម្បីបំពេញលក្ខខណ្ឌសិក្សាសម្រាប់ទទួលសញ្ញាបត្រនៅវិទ្យាស្ថាននេះ ឬសាកលវិទ្យាល័យណា ឬវិទ្យាស្ថានថ្នាក់ស្មើណាមួយនៅឡើយទេ។ ពុំមានសេចក្ដីដកស្រង់ ឬខ្លឹមសារអ្វីមួយត្រូវបានប្រើប្រាស់ក្នុងអត្ថបទស្រាវជ្រាវនេះ ដោយគ្មានការអនុញ្ញាតពីអ្នកនិពន្ធ ឬចុះបញ្ជីឯកសារយោងឡើយ។ និក្ខេបបទស្រាវជ្រាវខាងលើនេះពិតជាត្រូវបាន ស្រាវជ្រាវនិងចងក្រងដោយខ្ញុំបាទពិតប្រាកដមែន។

ថ្ងៃសុក្រ ១១រោច ខែកត្តិក ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០២៣

**ហត្ថលេខា**



**គៀត គឹក**

# លិខិតបញ្ជាក់

| | | |
|---|---|---|
| **ឈ្មោះ** | លោក ម៉ៅ សារឿន | ជាគ្រូណែនាំគោល |
| **ឈ្មោះ** | លោកបណ្ឌិត អាន វ៉ូប្រាវ | ជាគ្រូណែនាំរង |

**សូមបញ្ជាក់ និងទទួលស្គាល់ថា**

លោក **គៀត គីគ** ជានិស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី១០ ពិតជាបានសរសេរនិក្ខេបបទស្រាវជ្រាវស្តីពី «**ស្ថានភាពនៃការអនុវត្តគោលការណ៍អភិបាលកិច្ចនៅសាលារៀនជំនាន់ថ្មីនៅរាជធានីភ្នំពេញ**» ពិតប្រាកដមែន។

ថ្ងៃសុក្រ ១១រោច ខែកត្តិក ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០២៣

| | |
|---|---|
| ..................................... | ..................................... |
| **លោក ម៉ៅ សារឿន** | **លោកបណ្ឌិត អាន វ៉ូប្រាវ** |
| គ្រូណែនាំគោល | គ្រូណែនាំរង |

# សេចក្តីថ្លែងអំណរគុណ

ជាបឋមខ្ញុំសូមថ្លែងអំណរគុណចំពោះ **ឯកឧត្តមបណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា** ដែលបានផ្តល់ជាអាហារូបករណ៍ដល់ខ្ញុំបានសិក្សារៀនសូត្រថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី១០នេះ រយៈពេល២ឆ្នាំ នៃវិទ្យាស្ថានជាតិអប់រំ ព្រមទាំងលោកសាស្ត្រាចារ្យទាំងអស់ដែលបានខិតខំចំណាយពេលវេលាដ៏មានតម្លៃក្នុងការបង្ហាត់បង្រៀនតាមអនឡាញផង និងផ្ទាល់ផងទោះស្ថិតក្នុងដំណាក់កាលកូវីដ-១៩យ៉ាងណាក្តី ។ ជាពិសេស ខ្ញុំបាទសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះលោកគ្រូ **ម៉ៅ សារឿន** សាស្ត្រាចារ្យណែនាំគោល និង**លោកបណ្ឌិត អាន វ៉ុប្រាជ** សាស្ត្រាចារ្យណែនាំរង ដឹកនាំសរសេរនិក្ខេបបទដែលបានចំណាយពេលវេលាដ៏មានតម្លៃក្នុងការជួយណែនាំ និងផ្តល់យោបល់ដល់រូបខ្ញុំបាទក្នុងការសរសេរនិក្ខេបបទ ស្តីពី "**ស្ថានភាពនៃការអនុវត្តគោលការណ៍អភិបាលកិច្ច នៅសាលារៀនជំនាន់ថ្មី នៅរាជធានីភ្នំពេញ**" ។

ខ្ញុំបាទសូមថ្លែងអំណរគុណ ដល់គណៈគ្រប់គ្រងសាលារៀនជំនាន់ថ្មី វិទ្យាល័យព្រះស៊ីសុវត្ថិ ដែលបានទុកពេលវេលារៀងរាល់ថ្ងៃសៅរ៍ ឱ្យសម្រាកពីការងារដើម្បីឱ្យខ្ញុំបាទបានបន្តការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់នេះ ។

ខ្ញុំបាទសូមគោរពថ្លែងអំណរគុណ និងដឹងគុណយ៉ាងជ្រាលជ្រៅជាទីបំផុត ចំពោះ**លោកឪពុក មួ គឿន** និង**អ្នកម្តាយ សឿន លៀម** ដែលបានផ្តល់កំណើត និងចិញ្ចឹមបីបាច់ថែរក្សា ទំនុកបំរុងដល់រូបកូនឱ្យទទួលបានការសិក្សារហូតដល់រូបកូនមានថ្ងៃនេះ ។

ជាទីបញ្ចប់ ខ្ញុំបាទសូមប្រសិទ្ធពរជ័យ ជូនចំពោះឯកឧត្តម លោក/លោកស្រីសាស្ត្រាចារ្យ លោកលោក ស្រី នាងកញ្ញា និងមិត្តរួមជំនាន់ទាំងអស់ សូមទទួលបាននូវព្រះពុទ្ធពរទាំង៤ប្រការ គឺ **អាយុ វណ្ណៈ សុខៈ និងពលៈ** កុំបីឃ្លៀងឃ្លាតឡើយ។

# មូលន័យសង្ខេប

អភិបាលកិច្ចល្អសាលារៀននឹងធ្វើឱ្យអាកប្បកិរិយា និងឥរិយាបថក្នុងការបំពេញការងាររបស់បុគ្គលិកអប់រំមានការផ្លាស់ប្តូរពីអ្នកគ្រប់គ្រងទៅជាអ្នកបម្រើសេវា ព្រមទាំងចូលរួមលើកកម្ពស់ គុណភាព ប្រសិទ្ធភាព គណនេយ្យភាព ការអភិវឌ្ឍសមត្ថភាពរបស់បុគ្គលិកអប់រំ និងស្ថាប័ន ដើម្បីធានាបាននូវការអភិវឌ្ឍប្រកបដោយចីរភាព។ នៅតាមបណ្តាសាលារដ្ឋមួយចំនួននៅក្នុងប្រទេសកម្ពុជា យើងសង្កេតឃើញថាអភិបាលកិច្ចនៅតាមក្នុងសាលានៅមានទន់ខ្សោយនៅឡើយ ។ អភិបាលកិច្ចទន់ខ្សោយឆ្លុះឱ្យឃើញថាខ្វះគណនេយ្យភាពក្នុងការបំពេញភារកិច្ច ដែលនាំឱ្យមានការអនុគ្រោះខ្ពស់ចំពោះទង្វើខ្វះវិជ្ជាជីវៈជាគ្រូបង្រៀន។

ការសិក្សាស្រាវជ្រាវនេះ គឺមានគោលបំណងចម្បងចំនួនពីរគឺ ១). ស្វែងយល់ពីប្រសិទ្ធភាពនៃការអនុវត្តអភិបាលកិច្ចនៅសាលារៀនជំនាន់ថ្មីនៅរាជធានីភ្នំពេញ ផ្តោតសំខាន់លើគោលការណ៍ទាំង៤គឺ តម្លាភាព គណនេយ្យភាព នីតិរដ្ឋ និងការចូលរួម ២). ស្វែងយល់ពីបញ្ហាប្រឈមនៃការអនុវត្តដែលសាលារៀនជំនាន់ថ្មីកំពុងជួបប្រទះ។ ក្រុមគោលដៅដែលចូលរួមក្នុងការសិក្សាស្រាវជ្រាវនេះរួមមានគ្រូបង្រៀនចំនួន ១១១នាក់ និងគណៈគ្រប់គ្រងចំនួន ០៦នាក់  នៃសាលារៀនជំនាន់ថ្មីចំនួនពីរទីតាំងគឺ វិទ្យាល័យព្រះស៊ីសុវត្ថិ សាលារៀនជំនាន់ថ្មី និងវិទ្យាល័យព្រែកលៀប ។

តាមរយៈលទ្ធផលនៃការស្រាវជ្រាវបានបង្ហាញឱ្យដឹងថា ការអនុវត្តគោលការណ៍អភិបាលកិច្ចនៅសាលារៀនជំនាន់ថ្មី នៅរាជធានីភ្នំពេញ ផ្តោតលើគោលការណ៍ទាំង៤រួមមាន ១).តម្លាភាព ២). គណនេយ្យភាព ៣).នីតិរដ្ឋ និង ៤).ការចូលរួម ស្ថិតក្នុង "**អនុវត្តកម្រិតខ្ពស់**" ។

ក្នុងការសិក្សាស្រាវជ្រាវនេះក៏បានរកឃើញផងដែរ នៅបញ្ហាប្រឈមមួយចំនួន០៦ដូចជា ១). ការធ្វើបញ្ជីស្នាមគណនេយ្យមិនទាន់តាមកាលកំណត់ប្រចាំខែ ជាហេតុធ្វើឱ្យការបិទផ្សាយមានការយឺតយ៉ាវនៅចុងខែ និងធ្វើការបិទបញ្ជីមិនទាន់ពេលវេលា ២).សាលាមិនដឹងពីរបៀបចំណាយថវិកាភាគទានឱ្យបានត្រឹមត្រូវតាមលំនាំរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុនៅឡើយព្រោះសាលាធ្វើតាមតែទម្លាប់ដែលបានចំណាយកន្លងមក ៣).មិនទាន់មានសវនកម្មចុះមកពិនិត្យមើលដំណើរការនៃការចំណាយ ថាតើការ

អនុវត្តកន្លងមកមានភាពត្រឹមត្រូវតាមច្បាប់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងសវនកម្មរបស់ក្រសួងអប់រំ យុវជន និងកីឡាបានកម្រិតណានោះទេ និងមិនដឹងថាតើការធ្វើឯកសារហិរញ្ញវត្ថុ មានភាពត្រឹមត្រូវបានកម្រិតណាបើធៀបនឹងក្របខណ្ឌច្បាប់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ៤).គ្រូមិនមានស្ថេរភាព (គ្រូបង្រៀនធ្វើកិច្ចសន្យាមួយឆ្នាំម្តង) ៥).គ្រូបង្រៀននៅក្នុងកម្មវិធីសិក្សាធម្មតាមានការចូលរួមតិចតួចបំផុតក្នុងកម្មវិធីសាលារៀនជំនាន់ថ្មី ជាហេតុធ្វើឱ្យគ្រូកម្មវិធីធម្មតានៅសល់ ៦).បញ្ហាការទទួលសិស្សពីសាលាគោលដៅ ព្រោះយោងតាមគោលការណ៍សាលារៀនជំនាន់ថ្មី សិស្សទាំងអស់ដែលចុះឈ្មោះចូលរៀននៅសាលារៀនជំនាន់ថ្មីត្រូវឆ្លងកាត់ការប្រឡងឱ្យជាប់ជាមុនសិនទើបមានសិទ្ធចូលរៀន ជាហេតុធ្វើឱ្យសល់សិស្សពីសាលាគោលដៅ ឬសិស្សតម្រង់ទិស ដែលនាំឱ្យទៅរកសេចក្តីសន្និដ្ឋាន និងសំណូមពរផ្សេងៗក្នុងគោលបំណងសម្រាប់ការអនុវត្តឱ្យកាន់តែមានកម្រិតខ្ពស់។

# លិខិតឧទ្ទេសនាមគណៈកម្មការមេប្រយោគការពារនិក្ខេបបទ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអប់រំ យុវជន និងកីឡា**
**លេខ:** ៦៤៧៣ **អយក.ខុន**

(**ការសម្ងាត់**)

**លិខិតឧទ្ទេសនាម**
**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**យោង៖** - បទប្បញ្ញត្តិស្ដីពីការបណ្ដុះបណ្ដាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ នៅវិទ្យាស្ថានជាតិអប់រំ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥។
- ផែនការអនុវត្តកម្មវិធីបណ្ដុះបណ្ដាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី១០ ឆ្នាំសិក្សា ២០២២-២០២៣ ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០២២។
- សំណើសុំដូរកាលបរិច្ឆេទរៀបចំការការពារនិក្ខេបបទស្រាវជ្រាវបញ្ចប់ការសិក្សារបស់និស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី១០ ឆ្នាំសិក្សា២០២២-២០២៣ នៅវិទ្យាស្ថានជាតិអប់រំ។

ថ្នាក់ដឹកនាំ និងបុគ្គលិកអប់រំ នៃក្រសួងអប់រំ យុវជន និងកីឡា ដូចមានរាយនាមខាងក្រោម ត្រូវបានចាត់តាំងជា **គណៈកម្មការមេប្រយោគ** សម្រាប់ការការពារនិក្ខេបបទស្រាវជ្រាវបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី១០ ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី០៨-០៩ ខែធ្នូ ឆ្នាំ២០២៣ នៅវិទ្យាស្ថានជាតិអប់រំ៖

| | | | |
|---|---|---|---|
| ១-ឯកឧត្តមបណ្ឌិតសភាចារ្យ | ហង់ជួន ណារ៉ុន | ក្រសួង អយក | ប្រធាន |
| ២-ឯកឧត្តម | អ៊ុង បូរាត | ក្រសួង អយក | អនុប្រធាន |
| ៣-ឯកឧត្តម | លាង សេងហាក់ | ក្រសួង អយក | សមាជិក |
| ៤-ឯកឧត្តមបណ្ឌិត | ឌី ខាំបូលី | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៥. ឯកឧត្តមបណ្ឌិត | សៀង សុវណ្ណា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៦-ឯកឧត្តមបណ្ឌិត | សិត សេង | វិទ្យាស្ថានគរ.ភ្នំពេញ | សមាជិក |
| ៧-លោកបណ្ឌិត | នូវ វីរ៉ា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៨-លោក | ឌី បុណ្ណា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៩-លោកស្រី | ប៊ុន សុផានី | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១០-លោក | ថៃ ហេង | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១១-លោកបណ្ឌិត | ឈូក ច័ន្ទឆាយា | នាយកដ្ឋានបរ. | សមាជិក |
| ១២-លោកបណ្ឌិត | នី វដ្ឋា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៣-លោក | ម៉ន មុនិន្ទ | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៤-លោកបណ្ឌិត | ឈាង សង្វាត | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៥-លោកបណ្ឌិត | ម៉ម ចាន់សៀន | វិទ្យាស្ថានជាតិអប់រំ | សមាជិក |

អាសយដ្ឋានលេខ៨០ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ២២០ ៦៧៣ / ២២០ ៣០៤ ទូរសារ: (៨៥៥-២៣) ២១៧ ២៥០ / ២១២ ៥១២
អ៊ីមែល: info@moeys.gov.kh / administration@moeys.gov.kh គេហទំព័រ : www.moeys.gov.kh

ឯកឧត្តម លោក លោកស្រី ដូចមានរាយនាមខាងលើ ត្រូវអញ្ជើញមកវាយតម្លៃការការពារនិក្ខេបបទរបស់និស្សិតនៅថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០២៣ ចាប់ពីម៉ោង៧:៣០នាទីព្រឹកតទៅ នៅវិទ្យាស្ថានជាតិអប់រំ។

ថ្ងៃព្រហស្បតិ៍ ៣រោច ខែកត្តិក ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២៣

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន**

**កន្លែងទទួល៖**

- អគ្គនាយកដ្ឋានរ.ហិ អគ្គនាយកដ្ឋានឧស.
- ខុទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យឧបនាយករដ្ឋមន្ត្រី
- គ្រប់អង្គភាពក្រោមឱវាទអយកដែលមានការពាក់ព័ន្ធ "ដើម្បីជ្រាបជាព័ត៌មាន"
- សាមីខ្លួន " ដើម្បីអនុវត្ត "
- កាលប្បវត្តិ
- ឯកសារ៖ វិទ្យាស្ថានជាតិអប់រំ

# លិខិតឧទ្ទេសនាមគណៈកម្មការការពារនិក្ខេបបទស្រាវជ្រាវបញ្ចប់

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអប់រំ យុវជន និងកីឡា**

**លេខ** ៤៥០១ **អយក.ខថន**

(**ការសម្រាប់**)

**លិខិតឧទ្ទេសនាម**

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**យោង៖** - បទប្បញ្ញត្តិស្តីពីការបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ នៅវិទ្យាស្ថានជាតិអប់រំ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥។

- ផែនការអនុវត្តកម្មវិធីបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី១០ ឆ្នាំសិក្សា២០២២-២០២៣ ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០២២។
- សំណើសុំផ្ទេរកាលបរិច្ឆេទរៀបចំការការពារនិក្ខេបបទស្រាវជ្រាវបញ្ចប់ការសិក្សារបស់និស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី១០ ឆ្នាំសិក្សា២០២២-២០២៣ នៅវិទ្យាស្ថានជាតិអប់រំ។

បុគ្គលិកអប់រំ នៃក្រសួងអប់រំ យុវជន និងកីឡា ដូចមានរាយនាមខាងក្រោម ត្រូវបានចាត់តាំងជា **គណៈកម្មការការពារនិក្ខេបបទស្រាវជ្រាវបញ្ចប់** ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី១០ ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី០៨-០៩ ខែធ្នូ ឆ្នាំ២០២៣ នៅវិទ្យាស្ថានជាតិអប់រំ៖

| | | |
|---|---|---|
| ១. ឯកឧត្តមបណ្ឌិត ជ័យ សារិន | អគ្គាធិការដ្ឋាន | ប្រធាន |
| ២. លោកស្រីបណ្ឌិត បូ ច័ន្ទគុលិកា | នាយកដ្ឋានគោលនយោបាយ | អនុប្រធាន |
| ៣. លោកបណ្ឌិត កាន់ ពុទ្ធី | នា.បឋមសិក្សា អយក. | សមាជិក |
| ៤. លោក ម៉ៅ សារឿន | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៥. លោកស្រី សាំង សុចិន្តា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៦. លោកបណ្ឌិត មាឃ ចាន់ថេង | នាយកដ្ឋានតម្រង់ទិសវិជ្ជាជីវៈ | សមាជិក |
| ៧. លោកបណ្ឌិត អែ សុងហ៊ាង | SEAMEO TED អយក | សមាជិក |
| ៨. ឯកឧត្តមបណ្ឌិត ប៉ិច សៀង | វិ.បច្ចេកវិទ្យាកំពង់ឈើទាល | សមាជិក |
| ៩.លោកបណ្ឌិត លី គឹមឡុង | សាកលវិទ្យាល័យភូមិន្ទភ្នំពេញ | សមាជិក |
| ១០.លោក ចាប រតនា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១១.លោក លឹម វ៉ាន់ | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១២. លោកបណ្ឌិត អាន រ៉ូប្រាវ | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៣. លោកស្រី នូ ចន្នី | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៤. លោកស្រី បណ្ឌិត ឡឹយ សុខគា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៥. លោកបណ្ឌិត អ៊ឹម គឿន | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៦. លោកបណ្ឌិត ទី សុផល | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៧. លោកបណ្ឌិត គួយ សុគាន | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៨. លោកបណ្ឌិត សោន វណ្ណៈ | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៩. លោកបណ្ឌិត ឈន ថន | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ២០. លោកបណ្ឌិត សឿង សុផា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ២១. លោក ចាន់ ធឿន | វិទ្យាស្ថានជាតិអប់រំ | សមាជិក |

អាសយដ្ឋានលេខ៨០ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ២២០ ៦៧៣ / ២២០ ៣០៤ ទូរសារ: (៨៥៥-២៣) ២១៧ ២៥០ / ២១២ ៥១២
អ៊ីមែល: info@moeys.gov.kh / administration@moeys.gov.kh គេហទំព័រ : www.moeys.gov.kh

| | | |
|---|---|---|
| ២២. លោកបណ្ឌិត សោភទ្រា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ២៣. លោក ឡុច ចាន់ថន | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ២៤. លោក ចាន់ រ៉ាដា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |

លោក និងលោកស្រី ដូចមានរាយនាមខាងលើ ត្រូវអញ្ជើញមកវាយតម្លៃការការពារនិក្ខេបបទរបស់និស្សិត នៅថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០២៣ ចាប់ពីម៉ោង៧:៣០នាទីព្រឹកតទៅ នៅវិទ្យាស្ថានជាតិអប់រំ។

ថ្ងៃព្រហស្បតិ៍ ៣រោច ខែ កត្តិក ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ២០២៣

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន**

**កន្លែងទទួល៖**

- អគ្គនាយកដ្ឋានរ.ហិ អគ្គនាយកដ្ឋានឧស.
- ខុទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យឧបនាយករដ្ឋមន្ត្រី
- គ្រប់អង្គភាពក្រោមឱវាទអយកដែលមានការពាក់ព័ន្ធ "ដើម្បីជ្រាបជាព័ត៌មាន"
- សាមីខ្លួន " ដើម្បីអនុវត្ត "
- កាលប្បវត្តិ
- ឯកសារៈ វិទ្យាស្ថានជាតិអប់រំ

**មាតិកា**

**សេចក្តីអះអាងរបស់បេក្ខជន** ........ i

**លិខិតបញ្ជាក់** ........ ii

**សេចក្តីថ្លែងអំណរគុណ** ........ iii

**មូលន័យសង្ខេប** ........ iv

**លិខិតឧទ្ទេសនាមគណៈកម្មការមេប្រយោគការពារនិក្ខេបបទ** ........ vi

**លិខិតឧទ្ទេសនាមគណៈកម្មការការពារនិក្ខេបបទស្រាវជ្រាវបញ្ចប់** ........ viii

**ជំពូក១ សេចក្តីផ្តើម** ........ ១

១.១. លំនាំបញ្ហានៃការស្រាវជ្រាវ ........ ១

១.២. បញ្ហានៃការស្រាវជ្រាវ ........ ៥

១.៣. គោលបំណងស្រាវជ្រាវ ........ ៧

១.៤. សំណួរស្រាវជ្រាវ ........ ៧

១.៥. សារៈសំខាន់នៃការស្រាវជ្រាវ ........ ៧

១.៦. ដែនកំណត់និងវិសាលភាពនៃការស្រាវជ្រាវ ........ ៧

១.៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ ........ ៨

**ជំពូក ២ រំលឹកទ្រឹស្តី** ........ ១០

២.១. បញ្ញត្តិ និងទ្រឹស្តីពាក់ព័ន្ធនឹងការអនុវត្តន៍ គោលការណ៍អភិបាលកិច្ច ........ ១០

២.២. ស្នូលនៃយុទ្ធសាស្រ្តបញ្ញាកោណ ........ ១២

២.៣. គោលការណ៍នៃអភិបាលកិច្ចល្អ ........ ១៤

២.៤. កំណែទម្រង់អភិបាលកិច្ច ........ ១៨

២.៥. គោលការណ៍ស្នូលនៃគំរូអភិបាលកិច្ចថ្មី ........ ២០

  ២.៥.១. អំពីម៉ោងធ្វើការនៅសាលារៀនជំនាន់ថ្មី ........ ២៤

  ២.៥.២. ស្វ័យភាពប្រតិបត្តិការសាលារៀន ........ ២៥

២.៦. សាលាធម្មនុញ្ញ (Charter School) ..................................... ២៦
២.៦.១. អភិបាលកិច្ច និងការគ្រប់គ្រង ..................................... ២៧
២.៧. សាលារៀនល្អ ..................................... ២៨
២.៨. ស្តង់ដាសាលារៀនមានគុណភាព ..................................... ២៨
២.៩. ការគ្រប់គ្រងសាលារៀនមានប្រសិទ្ធភាព ..................................... ៣១
២.៩.១. កំណែទម្រង់កម្រិតសាលារៀនតាមរយៈគោលការណ៍ ៤A ..................................... ៣១
២.១០. ប្រសិទ្ធភាព និងគណនេយ្យភាព ..................................... ៣៣
២.១០.១. ប្រសិទ្ធភាពសាលារៀន ..................................... ៣៣
២.១០.២. សូចនាករប្រសិទ្ធភាព ..................................... ៣៤
២.១១. ការពង្រឹងគណនេយ្យភាពរបស់សាលារៀន ..................................... ៣៧
២.១២. ការពង្រឹងប្រសិទ្ធភាព និងគណនេយ្យភាព ..................................... ៣៩
២.១៣. ការគ្រប់គ្រងរដ្ឋបាលសាលារៀន ..................................... ៣៩
២.១៤. ធាតុសំខាន់ៗនៃអភិបាលកិច្ចសាលារៀន ..................................... ៤២
២.១៤.១. តម្លាភាព ..................................... ៤២
២.១៤.២. គណនេយ្យភាព ..................................... ៤៤
២.១៤.៣. នីតិរដ្ឋ (ភាពអាចគ្រោងទុកបាន) ..................................... ៤៦
២.១៤.៤. ការចូលរួម ..................................... ៤៦
២.១៥. គណនេយ្យភាពសាលារៀន ..................................... ៤៩
២.១៥.១. គណនេយ្យភាពពីដំណើរការសាលារៀន ..................................... ៤៩
២.១៥.២. គណនេយ្យភាពសិក្សា ..................................... ៤៩
២.១៥.៣. គណនេយ្យភាពហិរញ្ញវត្ថុ ..................................... ៥០
២.១៦. ស្វ័យភាពភាពប្រតិបត្តិការរបស់សាលារៀនជំនាន់ថ្មី ..................................... ៥០
២.១៧. គោលនយោបាយសាលារៀនជំនាន់ថ្មី ..................................... ៥១

២.១៨. ស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀន ..................... ៥៤
២.១៩. កំណែទម្រង់អប់រំនៃការគ្រប់គ្រងគំរូអភិបាលកិច្ច ..................... ៥៥
២.១៩.១ ការគ្រប់គ្រងគំរូអភិបាលកិច្ចថ្មី ដំណាក់កាលទី១ ..................... ៥៥
២.១៩.២ ការគ្រប់គ្រងគំរូអភិបាលកិច្ចថ្មី ដំណាក់កាលទី២ ..................... ៥៦
២.១៩.៣ ការគ្រប់គ្រងគំរូអភិបាលកិច្ចថ្មី ដំណាក់កាលទី៣ ..................... ៥៦
២.១៩.៤ ការគ្រប់គ្រងគំរូអភិបាលកិច្ចថ្មី ដំណាក់កាលទី៤ ..................... ៥៧
២.២០ ការកែទម្រង់កម្រិតសាលារៀន ..................... ៥៩
**ជំពូក៣ វិធីសាស្ត្រស្រាវជ្រាវ** ..................... ៦១
៣.១. ព័ត៌មានទូទៅនៃការស្រាវជ្រាវ ..................... ៦១
៣.២. ទីកន្លែងស្រាវជ្រាវ ..................... ៦១
៣.៣. គម្រោងវិភាគ ..................... ៦១
៣.៤. ការប្រមូលទិន្នន័យ ..................... ៦២
៣.៥. ឧបករណ៍នៃការស្រាវជ្រាវ ..................... ៦៣
៣.៥.១ កម្រិតចង្អុលបង្ហាញ ..................... ៦៤
៣.៥.២ កម្រងសំណួរ ..................... ៦៥
៣.៦. ការជ្រើសរើសសំណាក ..................... ៦៦
៣.៧. ការវិភាគទិន្នន័យ ..................... ៦៨
**ជំពូក៤ លទ្ធផល និងការពិភាក្សា** ..................... ៦៩
៤.១. ទិន្នន័យពីព័ត៌មានទូទៅរបស់គណៈគ្រប់គ្រង និងគ្រូបង្រៀន ..................... ៦៩
៤.១.១. ព័ត៌មានទូទៅរបស់គណៈគ្រប់គ្រប់គ្រង ..................... ៦៩
៤.១.២. ព័ត៌មានទូទៅរបស់គ្រូបង្រៀន ..................... ៧០
៤.២. លទ្ធផលឆ្លើយតបរបស់គ្រូបង្រៀន ..................... ៧២
៤.៣. លទ្ធផលឆ្លើយតបរបស់គណៈគ្រប់គ្រង ..................... ៧៨

៤.៤. លទ្ធផលឆ្លើយតបរបស់គ្រូបង្រៀន និងគណៈគ្រប់គ្រង ........................................ ៨៥
៤.៥. ប្រឈមនៃការអនុវត្តគោលការណ៍អនុវត្តអភិបាលកិច្ច........................................ ៨៨
៤.៥.១. តម្លាភាព ........................................ ៩០
៤.៥.២. គណនេយ្យភាព ........................................ ៩១
៤.៥.៣. នីតិរដ្ឋ (ភាពអាចគ្រោងទុកបាន) ........................................ ៩២
៤.៥.៤. ការចូលរួម ........................................ ៩២
**ជំពូក៥ សេចក្តីសន្និដ្ឋាន និងសំណូមពរ** ........................................ ៩៤
៥.១. សេចក្តីសន្និដ្ឋាន ........................................ ៩៤
៥.២. សំណូមពរ ........................................ ៩៧
តារាងឧបសម្ព័ន្ធ ........................................ ៩៩
ឯកសារយោង ........................................ ១០៥
កម្រងសំណួរស្រាវជ្រាវសម្រាប់គណៈគ្រប់គ្រងសាលារៀន ........................................ ១២១
កម្រងសំណួរស្រាវជ្រាវសម្រាប់គ្រូបង្រៀន ........................................ ១២៧

## បញ្ជីតារាង និងក្រាប


តារាង 1 ២.៣.១ និយមន័យពាក្យអភិបាលកិច្ច ១៧
តារាង 2 ២ .៥.១ ស្តង់ដាទទួលស្គាល់គុណភាពអប់រំសាលារៀនជំនាន់ថ្មី ៥៥
តារាង 3 ២.១០.២ ទម្រង់សម្រាប់វាយតម្លៃការងារគ្រូបង្រៀន ១០១
តារាង 4 ២.១៤ សមាសធាតុអភិបាលកិច្ច ៤៨
តារាង 5 ៣.៥.១ Frequency Likert scale ៦៥
តារាង 6 ៣.៦. ការជ្រើសរើសសំណាក ៦៨
តារាង 7 ៤.១. លទ្ធផលឆ្លើយតបរបស់គ្រូបង្រៀន ៧៨
តារាង 8 ៤.៣. លទ្ធផលឆ្លើយតបរបស់គណៈគ្រប់គ្រង ៨៤
តារាង 9 ៤.៤. លទ្ធផលឆ្លើយតបរបស់គ្រូបង្រៀន និងគណៈគ្រប់គ្រង ៨៥

ក្រាប 1 ព័ត៌មានទូទៅរបស់គណៈគ្រប់គ្រប់គ្រង ៦៩
ក្រាប 2 បទពិសោធន៍ការងារគណៈគ្រប់គ្រង ៧០
ក្រាប 3 ក្របខណ្ឌគ្រូបង្រៀន ៧០
ក្រាប 4 អាយុគ្រូបង្រៀន ៧១
ក្រាប 5 បទពិសោធន៍ការងាររបស់គ្រូបង្រៀន ៧១
ក្រាប 6 កម្រិតអប់រំចុងក្រោយរបស់គ្រូបង្រៀន ៧២

# ជំពូក១

# សេចក្ដីផ្ដើម

# ជំពូក១
# សេចក្តីផ្តើម

## ១.១. លំនាំបញ្ហានៃការស្រាវជ្រាវ

យុទ្ធសាស្ត្របញ្ចកោណរបស់រាជរដ្ឋាភិបាលកម្ពុជា ដើរតួជាឧបករណ៍ដ៏សំខាន់សម្រាប់ទ្រទ្រង់ការអនុវត្ត កម្មវិធីនយោបាយរាជរដ្ឋាភិបាលសម្រាប់នីតិកាលទី៧ នៃរដ្ឋសភា។ យុទ្ធសាស្ត្រនេះ ត្រូវបានរៀបចំឡើងទៅតាមរចនាសម្ព័ន្ធជាមុំប្រាំនៃបញ្ចកោណ ដែលប្រទាក់ក្រឡាគ្នាហើយផ្សារភ្ជាប់គ្នានៅគ្រប់ជ្រុងទាំងអស់។ ជារួមសមាសធាតុរបស់យុទ្ធសាស្ត្របញ្ចកោណកោណមានដូចតទៅៈ ១) ការអភិវឌ្ឍមូលធនមនុស្ស ២)ការធ្វើពិពិធកម្មសេដ្ឋកិច្ច និងបង្កើនភាពប្រកួតប្រជែង ៣) ការអភិវឌ្ឍវិស័យឯកជន និងការងារ ៤) ការអភិវឌ្ឍប្រកបដោយភាពធន ចីរភាព និងបរិយាបន្ន និងទី ៥)ការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមឌីជីថល (រាជរដ្ឋាភិបាលកម្ពុជា, ២០២៣)។ ក្នុងនោះដែររាជរដ្ឋាភិបាលបានកំណត់ថាស្នូលនៃយុទ្ធសាស្ត្របញ្ចកោណគឺផ្តោតលើការកែទម្រង់ និងការពង្រឹងអភិបាលកិច្ច។

ការអនុវត្តគោលការណ៍អភិបាលកិច្ចនេះ មានសារៈសំខាន់ចំពោះក្រសួងអប់រំ យុវជន និងកីឡា ក្នុងការសម្រេចនូវគោលដៅដ៏ធំធេងដែលបានកំណត់ នៅក្នុងផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០១៩-២០២៣ ដើម្បីឱ្យសម្រេចគោលដៅអភិវឌ្ឍប្រកបដោយចីរភាពទី៤ ស្តីពីការអប់រំដោយឈរលើគោលការណ៍ គុណភាព សមធម៌ បរិយាបន្ន ការសិក្សាពេញមួយជីវិត និងទាំងអស់គ្នា (ក្រសួង.អយក, ២០១៩)។ ឈរលើមូលដ្ឋាននេះ  ក្រសួងអប់រំ យុវជន និងកីឡា (២០១៩)បានកំណត់គោលនយោបាយពីរគឺ ១) ធានាឱ្យការអប់រំមានគុណភាព ប្រកបដោយសមធម៌ បរិយាបន្ន និងលើកគុណភាពឱកាសក្នុងការសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា និង ២) ធានាស័ក្តិសិទ្ធិនៃភាពជាអ្នកដឹកនាំនិងការគ្រប់គ្រងរបស់មន្ត្រីអប់រំគ្រប់លំដាប់ថ្នាក់ក្នុងគោលបំណងបង្ខិតសេវាឱ្យជិតប្រជាពលរដ្ឋអាចជួយកែលំអ គុណភាព សេវាសាធារណៈ និងបង្កើនការចូលរួមទៀតផង ។

ការពង្រឹងអភិបាលកិច្ចសាលារៀនមានគោលដៅ កែលម្អលទ្ធផលសិក្សារបស់សិស្ស ផ្លាស់ប្តូរវប្បធម៌សាលារៀន ពង្រឹងវិន័យ សីលធម៌ ចរិយាធម៌ សុជីវធម៌ គុណធម៌ និងឥរិយាបថល្អរបស់បុគ្គលិក

អប់រំ និងសិស្សានុសិស្ស។ សាលារៀនមានដំណើរការល្អអាស្រ័យលើការអនុវត្តវិធានការដូចជា ១).ពង្រឹងការគ្រប់គ្រងសាលារៀន ២). ការរៀបចំផែនការអភិវឌ្ឍសាលារៀន ៣).ការរៀបចំតេស្តស្តង់ដា ៤).ការវាយតម្លៃការបំពេញការងាររបស់បុគ្គលិក (ណារ៉ុន, ២០២៣) ។

កំណែទម្រង់សាលារៀនជំនាន់ថ្មីត្រូវបានចាប់ផ្តើមតាំងពីឆ្នាំ២០១៦ ដើម្បីលើកកម្ពស់គុណភាពអប់រំនៃសាលារៀនសាធារណៈ ។ សមាសធាតុដ៏សំខាន់មួយនៃកំណែទម្រង់វិស័យអប់រំកម្ពុជា គឺការបង្កើតសាលារៀនជំនាន់ថ្មីដើម្បីកែលម្អលទ្ធផលសិក្សារបស់សិស្ស និងសម្រេចបានតាមគោលដៅនៃការអប់រំ គឺជាការសម្រេចបាន វិជ្ជាសម្បទា បំណិនសម្បទា និងចរិយាសម្បទា ជាពិសេសគឺការបណ្តុះបណ្តាលពលរដ្ឋកម្ពុជាល្អ និងពលរដ្ឋសកលល្អ (ណារ៉ុន, ២០២០)។ ប្រព័ន្ធគុរុកោសល្យនៃសាលារៀនជំនាន់ថ្មីមានសមាសភាគចំនួន៧គឺ (KAPE, ២០២០)

(១)អភិបាលកិច្ច ៖ ការដឹកនាំរបស់នាយកមានគណនេយ្យភាពដែលនាំឱ្យប្រើប្រាស់ធនធានអប់រំប្រកបដោយសក្តានុពលខ្ពស់។ ការលុបបំបាត់ការបង្រៀនឯកជនក្រៅម៉ោងជំរុញគ្រូឱ្យបង្រៀនពេញមួយថ្ងៃ និងអនុវត្តបានយ៉ាងពេញលេញនូវកម្មវិធីសិក្សា ខិតខំស្រាវជ្រាវវិធីសាស្ត្របង្រៀនថ្មី និងបង្កើតជាសហគមន៍សិក្សាវិជ្ជាជីវៈ។ ប្រការនេះនាំឱ្យលទ្ធផលសិក្សារបស់សិស្សត្រូវបានកែលម្អយ៉ាងខ្លាំង។

ទី២-វិធីសាស្ត្របង្រៀនថ្មី ៖ សាលារៀនជំនាន់ថ្មីប្រើប្រាស់វិធីសាស្ត្របង្រៀនចម្រុះ ដែលឈរលើមូលដ្ឋាននៃទ្រឹស្តីស្ថាបនានិយម (Constructivism) ដែលច្របាច់បញ្ចូលគ្នាទ្រឹស្តីជាច្រើនដូចជា ៖ ការរៀនតាមបែបរិះរក (IBL) ការរៀបតាមបែបដោះស្រាយបញ្ហា (PBL) ការរៀនតាមបែបសហការ (CL) ការរៀនជាគម្រោង (Project Work) ការត្រិះរិះពិចារណាការសិក្សាបទពិសោធកន្លងទៅការឆ្លុះបញ្ចាំង (Reflection) ការរៀនតាមវិធីសាស្ត្របួម ការរៀនជាបណ្តាញ ការវិភាគ ការស្រមើស្រមៃ (Imagination), ការរៀនតាមបែបស្វែងរក (Discovery learning), ការសិក្សាតាមបែបបញ្ញត្តិ ការសិក្សាពីបរិបទ និងការពិភាក្សាជាក្រុម។ល។

ក្រសួងអប់រំ យុវជន និងកីឡា សម្រេចជ្រើសរើសវិធីសាស្ត្រសាលារៀនជំនាន់ថ្មីដើម្បីយកទៅអនុវត្តកម្មវិធីសិក្សាថ្មីតាមបែបបញ្ញត្តិ ដោយសារវិធីសាស្ត្រស្ថាបនានិយមរួមបញ្ចូលនូវលក្ខណៈសំខាន់ៗដូចតទៅ ៖

(១). ការសិក្សាតាមបែបសកម្ម និងស្វ័យសិក្សាតាមគោលដៅដាក់ចេញ self-directed

(២). ការស្ថាបនាលើចំណេះដឹង និងបទពិសោធពីមុន

(៣). ការសិក្សាតាមគម្រោង ដើម្បីបង្កើតបញ្ញត្តិថ្មី និង

(៤). ការផ្លាស់ប្តូរគំនិតថ្មីតាមរយៈការសហការ និងការពង្រឹងដំណើរការបង្កើតគំនិតថ្មី និងគំនិតធំៗ (KAPE, ២០២០)។

ទី៣-បច្ចេកវិទ្យា ៖ ការប្រើប្រាស់បច្ចេកវិទ្យាក្នុងការរៀន និងបង្រៀនបានចូលរួមចំណែកក្នុងការពង្រឹងគុណភាពអប់រំ និងកែលម្អលទ្ធផលសិក្សារបស់សិស្ស ជាពិសេសក្នុងការអនុវត្តវិធីសាស្ត្របង្រៀនឱ្យកាន់តែមានប្រសិទ្ធភាពជាមុន។

ទី៤-ប្រព័ន្ធប្រឹក្សាគរុកោសល្យនៅសាលារៀន ៖ ក្រសួងអប់រំ យុវជន និងកីឡាបានសហការជាមួយអង្គការខេបក្នុងការបង្កើត និងដាក់ឱ្យដំណើរការមជ្ឈមណ្ឌលជំនាន់ថ្មីស្តីពីការស្រាវជ្រាវគរុកោសល្យដែលមានតួនាទីបណ្តុះបណ្តាលទីប្រឹក្សាគរុកោសល្យសម្រាប់បម្រើការងារនៅសាលារៀនជំនាន់ថ្មី។ ការស្រាវជ្រាវបង្ហាញឱ្យឃើញថា ការរៀនសូត្រចំនួន ៧០ភាគរយទទួលបានមកពីបទពិសោធការងារ នៅពេលដែលគ្រូទើបចេញថ្មីទទួលបាននៅពេលជួបបញ្ហាប្រឈម ហើយទទួលបានការប្រឹក្សាយោបល់ពីគ្រូប្រឹក្សាយោបល់។ ចំណេះដឹង ២០ភាគរយទៀតបានមកពីការរៀនសូត្រសហការជាមួយសហការី ឬគ្រូដែលធ្វើការជាមួយគ្នាដែលលើកទឹកចិត្តហើយ ១០ភាគរយបានមកពីវគ្គវិក្រឹតការសិក្ខាសាលាផ្សេងៗ។ ដូចនេះវិធីសាស្ត្រគាំទ្រ ៧០-២០-១០ ពិតជានាំមកនូវការកែលម្អវិធីសាស្ត្របង្រៀនរបស់គ្រូ (KAPE, ២០២០)។

ទី៥-ការរៀបចំថ្នាក់រៀននិងសម្ភារឧបទេស ៖ ការរៀបចំថ្នាក់រៀនស្អាតបំពាក់ដោយសម្ភារឧបទ្ទេសពិតជាជួយគាំទ្រដល់ការអនុវត្តវិធីសាស្តបង្រៀនថ្មី និងទាក់ទាញសិស្សឱ្យខិតខំប្រឹងប្រែងរៀនសូត្រ។

ទី៦-សហគមន៍សិក្សាវិជ្ជាជីវៈ ៖ ការបង្កើតសហគមន៍វិជ្ជាជីវៈជួយគ្រូកែលម្អវិធីសាស្ត្របង្រៀន និងរៀនសូត្រពីគ្នាទៅវិញទៅមក និងជួយកែលម្អលទ្ធផលសិក្សា។

ទី៧-បណ្ណាល័យសតវត្សរ៍ទី២១ ៖ បណ្ណាល័យស្តង់ដារមានធនធានសិក្សាសម្បូរបែប និងបំពាក់ដោយឧបករណ៍អេឡិចត្រូនិចជួយដល់គ្រូ និងសិស្សក្នុងការអនុវត្តវិធីសាសាស្ត្របង្រៀនតាមបែបស្ថាបនា និងបណ្តុំចំណង់ចំណូលចិត្តរបស់សិស្សក្នុងការអានសៀវភៅ។

សាលារៀនជំនាន់ថ្មី គឺជាគោលដៅកំណែទម្រង់ទី១៤ របស់ក្រសួងអប់រំ យុវជន និងកីឡា។ គោលដៅនៃការបង្កើតសាលារៀនជំនាន់ថ្មី នេះដើម្បីជាម៉ូដែលនៃការអភិវឌ្ឍការអប់រំឱ្យដល់កម្រិតស្តង់ដាអតិប្បរមា ឆ្ពោះទៅរកគ្រឹះស្ថានសិក្សាសាធារណៈជំនាន់ថ្មីមួយដែលបង្ហាញពីគំរូអភិបាលកិច្ចថ្មីដូចជាស្វ័យភាពប្រតិបត្តិ បង្ហាញបទដ្ឋានវិជ្ជាជីវៈខ្ពស់ ផ្សារភ្ជាប់ជាមួយគណនេយ្យភាពតឹងរ៉ឹង ក្របខណ្ឌបែងចែកធនធានមានសនិទានភាព មានការទទួលស្គាល់ជាផ្លូវការ និងការច្នៃប្រឌិតថ្មី ។ សាលារៀនជំនាន់ថ្មីបង្កើតជាគំរូសាលារៀនស្វយ័តថ្មីមួយនៅក្នុងប្រព័ន្ធអប់រំសាធារណៈ។ គំរូសាលារៀននេះទទួលបានការវិនិយោគខ្ពស់ផ្សារភ្ជាប់ទៅនឹងស្តង់ដាថ្មីនៃគណនេយ្យភាព អភិបាលកិច្ច និងស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀនសម្រាប់ការសិក្សាសតវត្សរ៍ទី២១ ។ ការកែលម្អអភិបាលកិច្ចសាលារៀនត្រូវបានគេមើលឃើញថាជាមធ្យោបាយគន្លឹះដ៏សំខាន់មួយ  សម្រាប់ឈានទៅរកការបង្កើតគំរូអប់រំឱ្យមានគុណភាពខ្ពស់និងមាននិរន្តរភាពដែលមានលក្ខណៈស្រដៀងទៅនឹងអ្វីដែលគេសង្កេតឃើញមាននៅក្នុងសាលារៀនឯកជន ប៉ុន្តែកម្ររកឃើញនៅក្នុងសាលារៀនរដ្ឋ  (ខេប, ២០១៤)។ សាលារៀនជំនាន់ថ្មីជាសាលារៀនមួយដែលប្រើប្រាស់គំរូអភិបាលកិច្ចថ្មី និងផ្តល់គុណភាពអប់រំខ្ពស់នៅក្នុងសាលារៀនរដ្ឋកំពុងតែកើនឡើងជាលំដាប់និង បន្ទាន់ជាមួយនឹងការរីកចម្រើនយ៉ាងឆាប់រហ័សនូវចំនួនសាលាឯកជនទាំងបឋមសិក្សានិងមធ្យមសិក្សា ។

ដើម្បីសម្រេចបាននូវគំរូអភិបាលកិច្ចថ្មី សាលាជំនាន់ថ្មីបានរៀបចំនូវស្តង់ដាទាំង៥គឺ (១) ស្វ័យភាពប្រតិបត្តិ (២)បង្ហាញបទដ្ឋានវិជ្ជាជីវៈខ្ពស់ (៣)ផ្សារភ្ជាប់ជាមួយគណនេយ្យភាពតឹងរ៉ឹង (៤) ក្របខណ្ឌបែងចែកធនធានមានសនិទានភាព (៥)មានការទទួលស្គាល់ជាផ្លូវការ និងការច្នៃប្រឌិតថ្មី (ក្រសួង.អ.យ.ក, ២០២០)។

## ១.២. បញ្ហានៃការស្រាវជ្រាវ

សកលលោកនាសម័យទំនើបនេះបាននឹងកំពុងឈរលើបរិបទនៃការធ្វើកំណែទម្រង់លើគ្រប់វិស័យដើម្បីឆ្លើយតបទៅនឹងតម្រូវការឥតឈប់ឈររបស់សង្គមសំដៅលើកកម្ពស់គុណភាពជីវិត និងលើកស្ទួយសិទ្ធិសេរីភាពរបស់ប្រជាពលរដ្ឋ។

ការធ្វើសមាហរណកម្មទៅក្នុងតំបន់អាស៊ានឆ្នាំ២០១៥ និងការប្រែក្លាយកម្ពុជាឱ្យក្លាយទៅជាប្រទេសមានចំណូលមធ្យមឆ្នាំ២០៣០ ដែលទាមទារឱ្យមានការវិនិយោគបន្ថែមទៀតលើវិស័យអប់រំ។ ប្រទេសកម្ពុជាបានឈានចូលក្នុងដំណាក់កាលថ្មីមួយទៀតនៃការអភិវឌ្ឍវិស័យអប់រំ ដែលចាំបាច់ត្រូវផ្តោតការយកចិត្តទុកដាក់ទៅលើការពង្រឹងការអប់រំមូលដ្ឋាន និងគុណភាពសិក្សានៅក្នុងក្របខណ្ឌសេដ្ឋកិច្ចជាតិដែលមានលក្ខណៈជាប្រព័ន្ធដ៏ទូលំទូលាយ។

ផ្អែកលើគោលនយោបាយកំណែទម្រង់រដ្ឋបាលសាធារណៈ និងយុទ្ធសាស្ត្របញ្ចកោណរបស់រាជរដ្ឋាភិបាល ក្រសួងអប់រំ យុវជន និងកីឡា បាននឹងកំពុងរៀបចំផែនការសកម្មភាពអភិបាលកិច្ចអប់រំសម្រាប់គ្រប់គ្រងអង្គភាព គ្រឹះស្ថានសិក្សាសាធារណៈ និងអ្នកពាក់ព័ន្ធដទៃទៀតដើម្បីរួមគ្នាអភិវឌ្ឍវិស័យអប់រំប្រកបទៅដោយអភិបាលកិច្ចល្អស្របតាម ពាក្យស្លោក «ការអប់រំសម្រាប់ទាំងអស់គ្នា ទាំងអស់គ្នាសម្រាប់ការអប់រំ » ក្រសួងអប់រំ យុវជន និងកីឡា បាននឹងកំពុងលើកឡើងនូវវិធានការសំខាន់ៗជាច្រើនដើម្បីបង្កើនប្រសិទ្ធភាពក្នុងការផ្តល់សេវាអប់រំសាធារណៈដល់ប្រជាពលរដ្ឋគ្រប់តំបន់។ ការបង្រៀន និងការរៀននៅតាមសាលាជាកត្តាចម្បងរបស់វិស័យអប់រំ។

អភិបាលកិច្ចល្អសាលារៀននឹងធ្វើឱ្យអាកប្បកិរិយា និងឥរិយាបថក្នុងការបំពេញការងាររបស់បុគ្គលិកអប់រំមានការផ្លាស់ប្តូរពីអ្នកគ្រប់គ្រងទៅជាអ្នកបម្រើសេវាព្រមទាំងចូលរួមលើកកម្ពស់ គុណភាព

ប្រសិទ្ធភាព គណនេយ្យភាព ការអភិវឌ្ឍសមត្ថភាពរបស់បុគ្គលិកអប់រំ និងស្ថាប័ន ដើម្បីធានាបាននូវការអភិវឌ្ឍប្រកបដោយចីរភាព។

នៅតាមបណ្តាសាលារដ្ឋមួយចំនួននៅក្នុងប្រទេសកម្ពុជា យើងសង្កេតឃើញថាអភិបាលកិច្ចនៅតាមក្នុងសាលានៅមានទន់ខ្សោយនៅឡើយ ។ អភិបាលកិច្ចទន់ខ្សោយឆ្លុះឱ្យឃើញថាខ្វះគណនេយ្យភាពក្នុងការបំពេញភារកិច្ច ដែលនាំឱ្យមានការអនុគ្រោះខ្ពស់ចំពោះទង្វើខ្វះវិជ្ជាជីវៈជាគ្រូបង្រៀន (ខេប, ២០១៤) ។ ការធ្វើឱ្យគ្រូបង្រៀន នាយកសាលា និងបុគ្គលិកអប់រំសំខាន់ៗប្រកាន់ខ្ជាប់នូវការបំពេញភារកិច្ចតាមស្តង់ដាកំណត់ ជាការលំបាកណាស់នៅពេលដែលមានការលើកទឹកចិត្តតិចតួចសម្រាប់អ្នកបំពេញការងារវិជ្ជាជីវៈបានល្អ និងមានការដាក់ទណ្ឌកម្មតិចតួចចំពោះអ្នកមិនយកចិត្តទុកដាក់ក្នុងការបំពេញភារកិច្ច ។ ការផ្សារភ្ជាប់នឹងប្រាក់រង្វាន់តិចតួចពេលខ្លះមិនទៀងទាត់ ក៏ដូចជារចនាសម្ព័ន្ធគណនេយ្យភាពទន់ខ្សោយនៅក្នុងប្រព័ន្ធអប់រំគ្មានការលើកទឹកចិត្តផ្តល់ជាច្រកអាជីព ដែលធ្វើឱ្យស្តង់ដាវិជ្ជាជីវៈទាបនៅទូទាំងប្រព័ន្ធអប់រំនៅកម្ពុជា ។ បើប្រៀបធៀបជាមួយសាលារៀនរដ្ឋធម្មតា រួមមាន៖ អភិបាលកិច្ច៖ សាលារៀនជំនាន់ថ្មី ដំណើរការដោយឯករាជ្យ ហើយត្រូវបានគ្រប់គ្រងដោយក្រុមប្រឹក្សាភិបាលថ្នាក់ជាតិ និងក្រុមប្រឹក្សាថ្នាក់រាជធានី-ខេត្ត។ សាលារៀនជំនាន់ថ្មីមានស្វ័យភាពកាន់តែច្រើនក្នុងការសម្រេចចិត្ត ការអភិវឌ្ឍកម្មវិធីសិក្សា ការជ្រើសរើសគ្រូបង្រៀន និងការអនុវត្តការងារ។

តាមចំណេះដឹងរបស់អ្នកស្រាវជ្រាវ ក្នុងបរិបទកម្ពុជាពុំទាន់មានអ្នកស្រាវជ្រាវណាម្នាក់ ក្រុមណាមួយ ឬស្ថាប័នណាមួយបានធ្វើការសិក្សាលើប្រធានបទនេះនៅឡើយទេជាពិសេសក្នុងកម្រិតសាលារៀន។ ប្រការនេះ ជាកត្តាជំរុញឱ្យអ្នកស្រាវជ្រាវចង់ធ្វើការស្រាវជ្រាវវិភាគលើប្រធានបទ "**ស្ថានភាពនៃការអនុវត្តគោលការន៍អភិបាលកិច្ចនៅសាលារៀនជំនាន់ថ្មីនៅរាជធានីភ្នំពេញ**" ដោយសង្ឃឹមថាលទ្ធផលនៃការសិក្សានេះនឹងអាចជួយកំណែទម្រង់សេដ្ឋកិច្ចរបស់ប្រទេសជាតិ ដោយចាំបាច់ត្រូវតែមានការកំណត់ផែនការនៃការបង្កើតគោលការណ៍អភិបាលកិច្ច ក្នុងបុព្វហេតុជួយអភិវឌ្ឍន៍ប្រទេសជាតិឱ្យមានការរីកចម្រើនឆ្ពោះទៅមុខជាលំដាប់ទាំងនេះជាផ្លែផ្កាដ៏សម្បូរនៃមូលធនមនុស្សដែលមានគុណតម្លៃ មានចំណេះដឹង មានការអប់រំខ្ពស់ដែលរស់នៅក្នុងសង្គមជាតិខ្មែរអច្ឆរិយៈឆ្ពោះទៅរកយុគ្គសម័យសតវត្សទី២១។

## ១.៣. គោលបំណងស្រាវជ្រាវ

១. ស្វែងយល់ពីប្រសិទ្ធភាពនៃការអនុវត្តអភិបាលកិច្ចនៅសាលារៀនជំនាន់ថ្មីនៅរាជធានីភ្នំពេញ

២. ស្វែងយល់ពីបញ្ហាប្រឈមនៃការអនុវត្តដែលសាលារៀនជំនាន់ថ្មីកំពុងជួបប្រទះ

## ១.៤. សំណួរស្រាវជ្រាវ

១.តើការអនុវត្តអភិបាលកិច្ចនៅសាលារៀនជំនាន់ថ្មីមានប្រសិទ្ធភាពកម្រិតណា ធៀបទៅនឹងគោលការណ៍អភិបាលកិច្ចសាលារៀន?

២.តើសាលារៀនជំនាន់ថ្មីបានជួបប្រទះបញ្ហាប្រឈមអ្វីខ្លះក្នុងពេលអនុវត្តអភិបាលកិច្ច?

## ១.៥. សារៈសំខាន់នៃការស្រាវជ្រាវ

លទ្ធផលចុងក្រោយរបស់ការសិក្សាស្រាវជ្រាវនេះនឹងចូលរួមចំណែកក្នុងការលើកកម្ពស់ប្រសិទ្ធភាពក្នុងការអនុវត្តអភិបាលកិច្ច**នៅសាលារៀនជំនាន់ថ្មីនៅកម្ពុជា ទាំងកម្រិតគោលនយោបាយ និងកម្រិតសាលារៀន។**

សម្រាប់គោលនយោបាយ រាជរដ្ឋាភិបាលកម្ពុជា (២០២៣) បានចេញជាយុទ្ធសាស្ត្របញ្ចកោណ កំណត់ថាស្នូលនៃយុទ្ធសាស្ត្របញ្ចកោណគឺ ការកំណែទម្រង់ និងពង្រឹងអភិបាលកិច្ច។

សម្រាប់កម្រិតសាលារៀន បន្ទាប់ពីរាជរដ្ឋាភិបាលបានកំណត់ទិសដៅអទិភាពក្នុងការកែទម្រង់អភិបាលកិច្ចនេះ ក្រសួងអប់រំ យុវជន និងកីឡា (២០២៣) ក៏បានចេញជាគោលនយោបាយ ស្តីពីការសម្រួចអាទិភាព នៃកំណែទម្រង់វិស័យអប់រំ  សម្រាប់ឆ្នាំ២០២៣-២០២៨  ផងដែរ។ អទិភាពស្នូលទី១ គឺ ការពង្រឹងអភិបាលកិច្ចសាលារៀន រួមមាន (១) កំណែទម្រង់នៅថ្នាក់ជាតិ (២) កំណែទម្រង់នៅកម្រិតសាលារៀន ។

## ១.៦. ដែនកំណត់និងវិសាលភាពនៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះ សិក្សាស្វែងយល់ពីស្ថានភាពនៃការអនុវត្តគោលការណ៍អភិបាលកិច្ច នៅសាលារៀនជំនាន់ថ្មីនៅរាជធានីភ្នំពេញ។ អ្នកស្រាវជ្រាវបានសម្រេចចិត្តក្នុងការជ្រើសរើសយកសាលារៀនជំនាន់ថ្មីក្នុងរាជធានីភ្នំពេញមកធ្វើការសិក្សាស្រាវជ្រាវ ពីព្រោះថារាជធានីភ្នំពេញជាតំបន់មានសាលារៀន

ជំនាន់ថ្មីដែលមានសិស្សច្រើនជាពិសេសវិទ្យាល័យព្រះស៊ីសុវត្ថិ ដែលជាសាលារៀនជំនាន់ថ្មីដំបូងគេបំផុតនៅកម្ពុជាក៏ស្ថិតនៅតំបន់នេះផងដែរ ។ ដើម្បីឱ្យការស្រាវជ្រាវនេះមានតម្លៃ និងស៊ីជម្រៅ អ្នកស្រាវជ្រាវបានជ្រើសរើសយកសាលារៀនជំនាន់ថ្មីចំនួនពីរមកធ្វើការស្រាវជ្រាវដែលក្នុងនោះមានគ្រូបង្រៀនចំនួន១១១នាក់ នាយក/នាយករង នាយិការងចំនួន០៦នាក់សម្រាប់ធ្វើជាសំណាកនៃការសិក្សាស្រាវជ្រាវ។

សំណាកទាំងនេះត្រូវបានជ្រើសរើសយកចេញពីគ្រូបង្រៀន និងគណៈគ្រប់គ្រងនៃសាលារៀនជំនាន់ថ្មីទាំងពីររួមមាន សាលារៀនជំនាន់ថ្មី វិទ្យាល័យព្រះស៊ីសុវត្ថិ និងវិទ្យាល័យព្រែកលៀប ដែលមានទីតាំងនៅរាជធានីភ្នំពេញ ដើម្បីជួយកិច្ចសហប្រតិបត្តិការដូចជាការបំពេញនូវកម្រងសំណួរដាច់ដោយឡែកពីគ្នាដែលរៀបចំចងក្រងឡើងដោយអ្នកសិក្សាស្រាវជ្រាវ។

## ១.៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

រចនាសម្ព័ន្ធនៃការស្រាវជ្រាវនេះត្រូវបានបែងចែកជា៥ជំពូកធំៗដូចខាងក្រោម៖

- **ជំពូកទី១ សេចក្តីផ្តើម៖** នៅក្នុងជំពូកទី១នេះអ្នកសិក្សាស្រាវជ្រាវនឹងធ្វើការបង្ហាញពីលំនាំបញ្ហានៃការស្រាវជ្រាវ បញ្ហានៃការស្រាវជ្រាវ គោលបំណងនៃការស្រាវជ្រាវ សំណួរស្រាវជ្រាវ សារៈសំខាន់នៃការស្រាវជ្រាវ ដែនកំណត់ និងរចនាសម្ព័ន្ធនៃការស្រាវជ្រាវ។
- **ជំពូកទី២ រំលឹកទ្រឹស្តី៖** នៅក្នុងជំពូកទី២នេះអ្នកសិក្សាស្រាវជ្រាវបានប្រមូលយកនិយមន័យនៃអភិបាលកិច្ច ចេញពីឯកសារគតិយុត្តិនានាដែលពាក់ព័ន្ធនឹងនិក្ខេបបទនេះដើម្បីធ្វើជាអំណះអំណាង និងជាគំនិតសម្រាប់សិក្សាស្រាវជ្រាវ និងបង្កើតស្នាដៃថ្មីក្នុងនិក្ខេបបទនេះ ។
- **ជំពូកទី៣ វិធីសាស្ត្រស្រាវជ្រាវ៖** នៅក្នុងជំពូកទី៣នេះអ្នកសិក្សាស្រាវជ្រាវនឹងធ្វើការបង្ហាញនូវដែនកំណត់ និងវិសាលភាព ការជ្រើសរើសសំណាក ឧបករណ៍ស្រាវជ្រាវ កម្រងសំណួរស្រាវជ្រាវ វិធីសាស្ត្រប្រមូលទិន្នន័យ ការវិភាគទិន្នន័យ នីតិវិធីក្រមសីលធម៌ និងបង្ហាញពីទំនាក់ទំនងរវាងចំណុចនីមួយៗដែលបានចោទក្នុងចំណោទបញ្ហាទៅនឹងប្រធានបទ។

- **ជំពូកទី៤ លទ្ធផលស្រាវជ្រាវ៖** នៅក្នុងជំពូកទី៤នេះអ្នកសិក្សាស្រាវជ្រាវនឹងយកទិន្នន័យជាក់ស្តែងដែលប្រមូលបានមកវិភាគហើយធ្វើការបកស្រាយយ៉ាងលម្អិត ដើម្បីរកឱ្យឃើញនូវស្ថានភាពនៃការអនុវត្ត និងបញ្ហាប្រឈមដែលកើតមានឡើងដែលបានអនុវត្តគោលគោលការណ៍អភិបាលកិច្ចនៃសាលារៀនជំនាន់ថ្មីទាំងពីរនៅរាជធានីភ្នំពេញ។
- **ជំពូកទី៥ សេចក្តីសន្និដ្ឋាន និងសំណូមពរ៖** វាជាផ្នែកមួយសំខាន់ណាស់ដែលអ្នកសិក្សាស្រាវជ្រាវត្រូវធ្វើការសន្និដ្ឋានទៅលើចំណុចទាំងអស់ ដែលបានយកមកវិភាគព្រមទាំងសំណូមពរមួយចំនួនក្នុងគោលបំណងចូលរួមចំណែកធ្វើឱ្យការអនុវត្តគោលការណ៍អភិបាលកិច្ច នៅសាលារៀនជំនាន់ថ្មីឱ្យបានកាន់តែល្អប្រសើរឡើងថែមទៀត ។

# ជំពូក២

# រំលឹកទ្រឹស្តី

# ជំពូក ២
# រំលឹកទ្រឹស្តី

## ២.១. បញ្ញត្តិ និងទ្រឹស្តីពាក់ព័ន្ធនឹងការអនុវត្តន៍ គោលការណ៍អភិបាលកិច្ច

ជំពូកនេះ បង្ហាញពីបញ្ញត្តិ និងទ្រឹស្តីដែលទាក់ទងនឹងក្របខណ្ឌគំនិតដើម្បីគាំទ្រការស្រាវជ្រាវ។

អភិបាលកិច្ច ជាពាក្យដែលមានប្រភពដើមចេញមកពីភាសាក្រិច និងបានប្រើប្រាស់ជាលើកដំបូង ដោយលោកប្លាតុង Plato ( ទស្សនៈវិទូក្រិច ) ។ តាមវចនានុក្រមខ្មែរភាគទី១ (បោះពុម្ពផ្សាយដោយពុទ្ធសាសនបណ្ឌិតនៅឆ្នាំ១៩៦៧) បានកំណត់ថា ៖

**អភិបាលកិច្ច** = (អភិបាល + កិច្ច) អភិបាល (ន. សំ បា.) មានន័យថា អ្នកគ្រប់គ្រង, អ្នកបីបាច់ថែរក្សា, អ្នកថែរក្សា ការគ្រប់គ្រង, ការបីបាច់, ការថែរក្សា។

កិច្ច (ន. សំ. បា.) មានន័យថាកិច្ចដែលត្រូវធ្វើ, អំពើ, ការរវល់។ ដូចនេះអភិបាលកិច្ចជាដំណើរនៃការគ្រប់គ្រង។ អភិបាលកិច្ចត្រូវបានកំណត់និយមន័យជាច្រើនយ៉ាងទៅតាមបរិបទនៃការប្រើប្រាស់។

អភិបាលកិច្ច គឺជាដំណើរការ ឬការធ្វើសេចក្តីសម្រេចចិត្តផ្សេងៗដែលកំណត់ពីសកម្មភាពនៃការអនុវត្ត ឬតាមរយៈអំណាចដែលត្រូវបានគេផ្តល់ឱ្យដើម្បីអនុវត្តកិច្ចការប្រភេទណាមួយ ។

អភិបាលកិច្ចល្អ ជាការប្រើប្រាស់អំណាចខាងនយោបាយ សេដ្ឋកិច្ច និងរដ្ឋបាល ដើម្បីគ្រប់គ្រងរដ្ឋបាលរបស់ប្រទេស (UNDP, ១៩៩៧) ។

អភិបាលកិច្ចល្អ ជាវិធីសាស្ត្រដែលរដ្ឋ ស្ថាប័ន អង្គភាព ប្រើប្រាស់ក្នុងការគ្រប់គ្រងសេដ្ឋកិច្ច សង្គមកិច្ច និងសន្តិសុខ ដើម្បីបម្រើផលប្រយោជន៍រួមរបស់ប្រជាពលរដ្ឋ (ក្រសួងមហាផ្ទៃ, ២០១០) ។

ក្របខណ្ឌអភិបាលកិច្ចល្អ ការអនុវត្តវិស័យអប់រំឆ្នាំ២០៣០ នឹងតម្រូវឱ្យមានយន្តការថ្នាក់ជាតិ ថ្នាក់តំបន់ និងថ្នាក់សាកលសម្រាប់អភិបាលកិច្ច គណនេយ្យភាព ការសម្របសម្រួល ការអង្កេតតាមដាន និងការពិនិត្យឡើងវិញ ការរាយការណ៍និងការវាយតម្លៃ (UNESCO, ២០១៥)។

បើតាមលោក Barber Conable (១៩៨៦-១៩៩១) អតីតប្រធានធនាគាពិភពលោក "អភិបាលកិច្ចល្អ" គឺសំដៅទៅលើសេវាសាធារណៈដែលមានប្រសិទ្ធភាព ប្រព័ន្ធតុលាការដែលអាចទុកចិត្តបាន និង

រដ្ឋបាលដែលមានគណនេយ្យភាពចំពោះសេវាសាធារណៈនោះ។ ឆ្នាំ១៩៩២ ធនាគាពិភពលោកប្រើជា "អភិបាលកិច្ចនិងការអភិវឌ្ឍ" ដែលមានន័យថាលក្ខណៈនៅក្នុងអំណាចដែលបានអនុវត្តក្នុងការគ្រប់គ្រងស្ថាប័នមួយ និងការបែងចែកធនធានសេដ្ឋកិច្ចនិងសង្គមសម្រាប់ការអភិវឌ្ឍ ។ ឆ្នាំ១៩៩៤ ធនាគាពិភពលោកបានបញ្ជាក់បន្ថែមថា "អភិបាលកិច្ច" ត្រូវបានបង្ហាញដោយព្យាករណ៍បើកចំហ និងការបង្កើតគោលនយោបាយបំភ្លឺ (នោះគឺតម្លាភាព)។ ឆ្នាំ១៩៩៨ កម្មវិធីអភិបាលកិច្ចអាស៊ីប្រែពីវិបត្តិទៅជាឱកាស ។ ការបោះពុម្ពផ្សាយប្រចាំឆ្នាំរបស់ធនាគារពិភពលោកពេលនោះ "អភិបាលកិច្ច" មានសមាសធាតុបួនធំៗគឺ៖ (១) គណនេយ្យភាព (២) តម្លាភាព (៣) អាចប៉ាន់ប្រមាណបាន និង (៤) ការចូលរួមពីភាគីពាក់ព័ន្ធ (Tripathi, ២០១៧)។

ឆ្នាំ២០១០ តាមធនាគាពិភពលោក "អភិបាលកិច្ច" មានសមាសភាពបួនដដែលតែមានការកែប្រែតិចតួចគឺ៖ (១) សេវាគ្រប់គ្រងសាធារណៈ (២) គណនេយ្យភាព (៣) នីតិរដ្ឋ និងការអភិវឌ្ឍ និង (៤) តម្លាភាពនិងប្រព័ន្ធព័ត៌មាន (Maldonado, 2010)។ម្យ៉ាងទៀត "អភិបាលកិច្ច" អាចមានសមាសភាពច្រើនជាងនេះគឺ៖ (១) ការចូលរួម (២) ភាពស៊ីសង្វាក់គ្នាក្នុងអង្គភាព (៣) គណនេយ្យភាព (៤) តម្លាភាព (៥) ទំនួលខុសត្រូវ (៦) ប្រសិទ្ធភាព និងភាពស័ក្តិសិទ្ធិ (៧) សមធម៌និងបរិយាប័ន្ន (៨) អនុវត្តតាមនីតិរដ្ឋ (Arulrajah, 2016) ។ ដោយឡែកបញ្ញត្តិនៃអភិបាលកិច្ចល្អនៅប្រទេសអង់គ្លេសត្រូវបានវាស់ដោយឧបករណ៍ធំៗពីរគឺ៖ (១) តម្លាភាព និង (២) គណនេយ្យភាពបែបប្រជាធិបតេយ្យតាមរយៈការប្រើប្រាស់ថវិកាកម្មវិធី (PB) ក្នុងទីក្រុង និងរដ្ឋបាលក្រុង ។ ឧទាហរណ៍ទាំងពីរនោះត្រូវបានប្រើដើម្បីវាស់ឱ្យដឹងថា៖ (១) តើថវិកាកម្មវិធីអាចធ្វើឱ្យប្រសើរឡើងនូវតម្លាភាព គណនេយ្យភាព និងលទ្ធិប្រជាធិបតេយ្យក្នុងក្រុង និងរដ្ឋបាលក្រុងឬទេ? (២) តើថវិកាកម្មវិធីជាឧបករណ៍សម្របសម្រួលរវាងការគ្រប់គ្រង តម្លាភាព និងលទ្ធិប្រជាធិបតេយ្យក្នុងក្រុង និងរដ្ឋបាលក្រុងឬទេ? (Maria Isabel Brun-Martos et al, ២០១៦)។

ចំណែកកម្មវិធីអភិវឌ្ឍធនធានមនុស្សសកល អភិបាលកិច្ចមានសមាសភាគចំនួន១០គឺ៖

(១) ការចូលរួម (២) គណនេយ្យភាព (៣) ការមិនរើសអើង (៤) សមភាព (៥) សហប្រតិបត្តិការ (៦) តម្លាភាព (ភាពជាម្ចាស់ ភាពត្រឹមត្រូវ) (៧) ប្រព័ន្ធបច្ចេកវិទ្យា (៨) ការផ្តល់ឱកាសដល់ផ្នែកសេវាសាធារណៈ (៩) ភាពស្របច្បាប់ (១០) រដ្ឋអធិបតេយ្យ/នីតិរដ្ឋ ដែលទាំងអស់នេះរដ្ឋាភិបាលត្រូវបានបង្កើតឡើងដើម្បីឱ្យមានអភិបាលកិច្ចធនធានមនុស្ស ឬអភិបាលកិច្ចសកល (Weiss, 2010)។

លើសពីនេះទៅទៀត "អភិបាលកិច្ច" ជាពាក្យចេញពីរដ្ឋាភិបាលតែម្តង គឺជាអ្នកគ្រប់គ្រង អ្នកបីបាច់រក្សា អ្នកថែរក្សា ការគ្រប់គ្រង ការបីបាច់ ការរក្សា ។ ម្យ៉ាងទៀតក្រសួងមហាផ្ទៃនៃព្រះរាជាណាចក្រកម្ពុជាក៏បានយកចិត្តទុកដាក់ចំពោះបញ្ញត្តិនេះផងដែរថា "អភិបាលកិច្ចល្អ" គឺជាបុរេលក្ខខណ្ឌសំខាន់បំផុតមួយ ដើម្បីធានាឱ្យមានការអភិវឌ្ឍសេដ្ឋកិច្ចសង្គម ប្រកបដោយចីរភាព សមធម៌ និងយុត្តិធម៌ក្នុងសង្គម (ក្រសួងមហាផ្ទៃ, ២០១០) ។

ធនធានមនុស្សប្រកបដោយសមត្ថភាពកំពុងដើរតួនាទីសំខាន់ក្នុងអង្គភាពនិរន្តរភាព ដោយមានការចូលរួមចំណែកទូទៅ ។ ការរីកចម្រើននៃអភិបាលកិច្ចល្អក៏មានសារៈសំខាន់ផងដែឬសម្រាប់និរន្តរភាពនៃអង្គភាព ។ ប្រសិនបើការគ្រប់គ្រងធនធានមនុស្សមានតួនាទីសំខាន់ចំពោះនិរន្តរភាពរបស់អង្គភាពការស្វែងរកព័ត៌មានអង្គភាព និងការពិនិត្យឡើងវិញអំពីរបៀបដែលធនធានមនុស្សអាចដល់ការបង្កើតឱ្យមានអភិបាលកិច្ចល្អក្នុងអង្គភាពមួយប្រាកដជាអាចធ្វើទៅបាន។ គោលគំនិតនៃអភិបាលកិច្ចល្អបង្ហាញពីគោលគំនិត និងទំនាក់ទំនងរវាងអភិបាលកិច្ចល្អនិងធនធានមនុស្សនៅក្នុងវិជ្ជាជីវៈគ្រប់គ្រងអង្គភាពបច្ចុប្បន្ន ។ ឆ្នាំ២០១៨ យុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៤ របស់រាជរដ្ឋាភិបាល នីតិកាលទី៦នៃរដ្ឋសភា បន្តកំណែទម្រង់អភិបាលកិច្ចល្អដែលជាស្នូលក្នុងការធ្វើកំណែទម្រង់ ដោយបង្កើនល្បឿននៃកំណែទម្រង់អភិបាលកិច្ចល្អ (រាជរដ្ឋាភិបាល, ២០១៨) ។

## ២.២. ស្នូលនៃយុទ្ធសាស្ត្របញ្ចកោណ

យុទ្ធសាស្ត្របញ្ចកោណ គឺជាយុទ្ធសាស្ត្រអភិវឌ្ឍសង្គម-សេដ្ឋកិច្ចរយៈពេលវែង ដែលនឹងត្រូវអនុវត្តជា ៥ ដំណាក់កាលសម្រាប់រយៈពេល ២៥ឆ្នាំទៅមុខ ។ ជារួមរាជរដ្ឋាភិបាល (២០២៣)បានកំណត់

រចនាសម្ព័ន្ធនៃយុទ្ធសាស្ត្រនេះមាន ៖ (១). ស្នូលនៃយុទ្ធសាស្ត្រគឺ : ការកែទម្រង់ និងការពង្រឹងអភិបាលកិច្ច (២). បរិស្ថានគ្របដណ្ដប់សម្រាប់ធានាបរិយាកាសអំណោយផលដល់ការអនុវត្តយុទ្ធសាស្ត្រទាំងមូល និង (៣). បញ្ចកោណយុទ្ធសាស្ត្រសម្រាប់ជំរុញកំណើនសេដ្ឋកិច្ច និងវឌ្ឍនភាពសង្គម ។ ដោយឡែកយុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១ ក៏មានបញ្ចូលផងដែរនូវ "កម្មវិធីគោលនយោបាយអាទិភាពចំនួន៦ នៃកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាល នីតិកាលទី ៧ នៃរដ្ឋសភា" ដែលត្រូវចាប់ផ្តើមអនុវត្តភ្លាមក្នុងឆ្នាំ២០២៣ ។ ស្នូលនៃយុទ្ធសាស្ត្របញ្ចកោណផ្តោតលើការកែទម្រង់ និងការពង្រឹងអភិបាលកិច្ច និងការធ្វើទំនើបកម្មស្ថាប័នរដ្ឋឱ្យក្លាយជារដ្ឋបាលសាធារណៈទំនើបប្រកបដោយសមត្ថភាពខ្ពស់ ខ្លាំង វៃឆ្លាត និង ស្អាតស្អំ តាមរយៈការអនុវត្តសិទ្ធិអំណាចរដ្ឋខាងផ្នែកនយោបាយ សេដ្ឋកិច្ច និងរដ្ឋបាល ក្នុងការដឹកនាំ ការគ្រប់គ្រង និងការចាត់ចែងកិច្ចការប្រទេសជាតិពិសេសការធានានិរន្តរភាពតួនាទី និងដំណើរការរដ្ឋបាលសាធារណៈដោយយកចិត្តទុកដាក់លើផលប្រយោជន៍ប្រជាជនព្រមជាមួយនឹងការកសាងជាតិ និងការពង្រឹងនីតិរដ្ឋ សំដៅគាំទ្រដល់ការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច ប្រកបដោយបរិយាបន្ន និងចីរភាព ។ ទោះបីសម្រេចបានសមិទ្ធផលជាច្រើនយ៉ាងណាក្តី រាជរដ្ឋាភិបាលនៅបន្តមានបញ្ហាប្រឈមមួយចំនួនដូចជា ការត្រួតមុខងារ និងដែនសមត្ថកិច្ច ការបែងចែកច្បាស់លាស់នូវមុខងារសិទ្ធអំណាច និងការទទួលខុសត្រូវរបស់ស្ថាប័នរដ្ឋ សមត្ថភាពស្ថាប័ន និងធនធានមនុស្ស ការសម្របសម្រួលអន្តរស្ថាប័ន ក្របខ័ណ្ឌគណនេយ្យភាព តម្លាភាព និងការចែករំលែកព័ត៌មាន និងទិន្នន័យ ការងារត្រួតពិនិត្យ អធិការកិច្ច និង សវនកម្ម ការធ្វើទំនើបកម្មកងកម្លាំងប្រដាប់អាវុធ និងក្របខណ្ឌអភិបាលកិច្ចវិស័យឯកជន ។ ក្នុងន័យនេះរាជរដ្ឋាភិបាលបន្តផ្តោតលើ (១). ការពង្រឹង និង ការកែទម្រង់ស្ថាប័ន (២). ការលើកកម្ពស់សមត្ថភាពធនធានមនុស្ស និង ការពង្រឹងប្រសិទ្ធភាពនៃការអនុវត្តការងារ (៣). ការលើកកម្ពស់ និង ការពង្រឹងភាពស្អាតស្អំ នៅក្នុងរដ្ឋបាលសាធារណៈ (៤). ការលើកកម្ពស់ និង ការពង្រឹងប្រសិទ្ធភាពនៃ ច្បាប់ និងប្រព័ន្ធយុត្តិធម៌ និង (៥). ការពង្រឹងអភិបាលកិច្ច វិស័យឯកជន និង ធុរកិច្ច (រាជរដ្ឋាភិបាល, ២០២៣)។

## ២.៣. គោលការណ៍នៃអភិបាលកិច្ចល្អ

អភិបាលកិច្ចល្អ ជាវិធីសាស្ត្រ ឬមធ្យោបាយដែលរដ្ឋ ស្ថាប័ន អង្គភាព ប្រើប្រាស់ក្នុងការគ្រប់គ្រងសេដ្ឋកិច្ច និងសន្តិសុខ ដើម្បីបម្រើផលប្រយោជន៍រួមរបស់ប្រជាពលរដ្ឋដើម្បីបំពេញគោលការណ៍ទាំង៩ ដូចខាងក្រោមនេះ (ក្រសួងមហាផ្ទៃ, ២០១០)៖

1) **ការចូលរួម** ៖ ក្នុងបរិបទនេះការចូលរួម សំដៅទៅលើការចូលរួមរបស់ អង្វាធរ មាតាបិតា ឬអាណាព្យាបាលសិស្ស ។ សារៈសំខាន់នៃការចូលរួមគឺដើម្បីធានាថាព័ត៌មានទាំងឡាយស្តីពីបញ្ហាតម្រូវការ និងបំណងប្រាថ្នារបស់អង្វាធរ មាតាបិតា ឬអាណាព្យាបាលសិស្សទាំងឡាយត្រូវបានប្រមូល និងវិភាគបានគ្រប់ជ្រុងជ្រោយ មុននឹងធ្វើការសម្រេចចិត្ត ។

2) **នីតិរដ្ឋ** ៖ ក្នុងន័យអភិបាលកិច្ចល្អផ្តោតសំខាន់ទៅលើ
   - ឯកសារក្របខណ្ឌច្បាប់
   - ការការពារសិទ្ធមនុស្ស
   - ប្រព័ន្ធទទួលខុសត្រូវ
   - ប្រព័ន្ធយុត្តិធម៌
   - សមត្ថកិច្ចពង្រឹងការអនុវត្តច្បាប់ដោយមិនលំអៀង និងមិនពុករលួយ។

3) **តម្លាភាព** ៖ ក្នុងន័យអភិបាលកិច្ចល្អ មានន័យថារាល់ការសម្រេចចិត្ត និងការអនុវត្តសេចក្តីសម្រេចនោះត្រូវធ្វើឡើង ៖
   - ដោយអនុឡោមទៅតាមច្បាប់ និងបទដ្ឋាននានា
   - ព័ត៌មានពាក់ព័ន្ធនឹងការសម្រេចចិត្ត និងអនុវត្តសេចក្តីសម្រេចចិត្ត ត្រូវផ្សព្វផ្សាយជាចំហតាមរយៈប្រព័ន្ធសមស្រប និងស្វែងរកបានជាពិសេសចំពោះអ្នកដែលទទួលរងនូវផលប៉ះពាល់ពីការសម្រេចចិត្តនិងការអនុវត្តសេចក្តីសម្រេចចិត្តទាំងនោះ

4) **ការព្រមព្រៀងឯកភាពគ្នា** ៖ ក្នុងន័យអភិបាលកិច្ចល្អ គឺជាការពិចារណាទូលំទូលាយ និងវែងឆ្ងាយលើផលប្រយោជន៍ និងតម្រូវការរបស់អ្នកពាក់ព័ន្ធផ្សេងៗគ្នានៅក្នុងសង្គមហើយឈានទៅរកការសម្រេចចិត្ត ដោយមានការព្រមព្រៀងឯកភាពលើជំរើស និងវិធីសាស្ត្រណាមួយដែលបម្រើផលប្រយោជន៍សាធារណៈ

5) **សមធម៌** ៖ ក្នុងន័យអភិបាលកិច្ចល្អមានន័យថា ក្រុម ឬជនគ្រប់រូបទាំងអស់ជាពិសេសក្រុមភាគតិច និងក្រុមដែលងាយរងគ្រោះមានឱកាសគ្រប់គ្រាន់នៅក្នុងការចូលរួមបញ្ចេញយោបល់លើកឡើងនូវតម្រូវការពិត អនុវត្តសកម្មភាព និងទទួលផលប្រយោជន៍សមស្របដើម្បីកែលម្អ និងថែរក្សាសុខុមាលភាពរបស់ពួកគេ ។ លើសពីនេះទៀត ពួកគេមានអារម្មណ៍ថាខ្លួនជាសមាជិកពិតប្រាកដរបស់សង្គម និងមិនត្រូវបានសង្គមបោះបង់ចោលនោះទេ ។

6) **ប្រសិទ្ធភាព និងភាពស័ក្តិសិទ្ធិ** ៖ ក្នុងន័យអភិបាលកិច្ចល្អ ដំណើរការ និងរចនាសម្ព័ន្ធគ្រប់គ្រងក្នុងការប្រើប្រាស់ធនធានឱ្យអស់លទ្ធភាព និងសន្សំសំចៃខ្ពស់ ដើម្បីបង្កើតលទ្ធផលនិងមានគុណភាពខ្ពស់ បរិមាណច្រើនអាចបម្រើផលប្រយោជន៍ជាអតិប្បរមា និងឆ្លើយតបទៅតម្រូវការពិតរបស់សង្គម ។ ដើម្បីឱ្យមានប្រសិទ្ធភាព និងស័ក្តិសិទ្ធក្នុងការអនុវត្តត្រូវពិចារណាលើចំណុចមួយចំនួនដូចខាងក្រោម ៖

   - ការប្រើប្រាស់ធនធានឱ្យបានត្រឹមត្រូវ (ធនធានមនុស្ស ហិរញ្ញវត្ថុ ពេលវេលា)
   - ការអនុវត្តសកម្មភាពដែលជាអទិភាពខ្ពស់
   - ជៀសវាងការអនុវត្តនូវការិយាធិបតេយ្យ
   - ការគិតគូររយៈពេលវែងលើការប្រើប្រាស់ធនធានធម្មជាតិ
   - គ្មានអំពើពុករលួយ
   - ការសម្រេចចិត្តតាមបែបចូលរួម ។ល។

7) **គណនេយ្យភាព** ៖ ក្នុងន័យអភិបាលកិច្ចល្អ មានន័យថាជាការអនុវត្តតួនាទី និងភារកិច្ចក្នុងដំណើរការ និងអនុវត្តសេចក្តីសម្រេចចិត្ត ហើយទទួលខុសត្រូវចំពោះទង្វើរបស់ខ្លួន ដោយរាយការណ៍ ព្រមទាំងបញ្ជាក់ពីមូលហេតុនូវអ្វីដែលខ្លួនបានសម្រេច និងអនុវត្ត។ គណនេយ្យភាពមិនត្រឹមតែជាការទទួលខុសត្រូវចំពោះមុខអ្នកណាម្នាក់ដែលបានស្នើសុំឱ្យធ្វើអ្វីមួយនៅទេ ប៉ុន្តែជាការទទួលខុសត្រូវនូវសកម្មភាពដែលបានអនុវត្តចំពោះមុខអ្នកពាក់ព័ន្ធទាំងអស់ផងដែរ ។ គណនេយ្យភាពរួមមាន គណនេយ្យភាពចំពោះមុខថ្នាក់ដឹកនាំ និងគណនេយ្យភាពចំពោះមុខសាធារណជន។

8) **ការឆ្លើយតប** ៖ ក្នុងន័យអភិបាលកិច្ចល្អ មានន័យថាជាការព្យាយាមខិតខំប្រឹងប្រែងរបស់អង្គភាពស្ថាប័ន ដើម្បីបម្រើប្រជាពលរដ្ឋ និងអ្នកពាក់ព័ន្ធទាំងអស់ដោយស្មើភាពគ្នា និងមិនរើសអើងក្នុងក្របខណ្ឌពេលវេលាណាមួយដ៏សមហេតុផល ។

9) **ចក្ខុវិស័យជាយុទ្ធសាស្ត្រ** ៖ អ្នកដឹកនាំទាំងអស់ និងស្ថាប័នសាធារណៈនានាត្រូវមានទស្សនៈទូលំទូលាយរយៈពេលវែងអំពីអភិបាលកិច្ចល្អ និងការអភិវឌ្ឍធនធានមនុស្សដោយយកចិត្តទុកដាក់អំពីតម្រូវការចាំបាច់នានា ដែលត្រូវអភិវឌ្ឍន៍លើការងារនេះ។ ជាងនេះទៅទៀតអ្នកដឹកនាំទាំងអស់ត្រូវមានការយល់ដឹងឱ្យបានច្បាស់អំពីទិដ្ឋភាពនានា ផ្នែកប្រវត្តិសាស្ត្រ វប្បធម៌ និងសង្គមដែលពាក់ព័ន្ធនឹងអភិបាលកិច្ចល្អ ។

តាមរយៈការស្រាវជ្រាវរាល់ឯកសារពីនិយមន័យនៃពាក្យ **“អភិបាលកិច្ច”** ដែលរៀបរាប់ខាងលើរួចមកអ្នកស្រាវជ្រាវអាចសង្ខេបជាតារាងមួយដើម្បីងាយយល់មានដូចខាងក្រោម៖

តារាង 1 ២.៣.១ និយមន័យពាក្យអភិបាលកិច្ច

| **ល.រ** | **ពាក្យ** | **និយមន័យ** | **ប្រភពឯកសារ** |
|---|---|---|---|
| ១ | **អភិបាលកិច្ច** | ជាដំណើរការ ឬការធ្វើសេចក្តីសម្រេចចិត្តផ្សេងៗ ដែលកំណត់ពីសកម្មភាពនៃការអនុវត្ត ឬតាមរយៈអំណាចដែលត្រូវបានគេផ្តល់ឱ្យដើម្បីអនុវត្តកិច្ចការប្រភេទណាមួយ ។ | (ពុទ្ធសាសនបណ្ឌិត ,១៩៦៧) |
| ២ | | ជាការប្រើប្រាស់អំណាចខាងនយោបាយ សេដ្ឋកិច្ច និងរដ្ឋបាល ដើម្បីគ្រប់គ្រងរដ្ឋបាលរបស់ប្រទេស ។ | (UNDP, ១៩៩៧) |
| ៣ | | សំដៅទៅលើសេវាសាធារណៈដែលមានប្រសិទ្ធភាពប្រព័ន្ធតុលាការដែលអាចទុកចិត្តបាន និងរដ្ឋបាលដែលមានគណនេយ្យភាពចំពោះសេវាសាធារណៈនោះ។ | Barber Conable (១៩៨៦-១៩៩១) អតីតប្រធានធនាគាពិភពលោក |
| ៤ | | ជាអំណាចដែលបានអនុវត្តក្នុងការគ្រប់គ្រងស្ថាប័នមួយ និងការបែងចែកធនធានសេដ្ឋកិច្ចនិងសង្គមសម្រាប់ការអភិវឌ្ឍ ត្រូវបានបង្ហាញដោយព្យាករណ៍បើកចំហ និងការបង្កើតគោលនយោបាយបំភ្លឺ (នោះគឺតម្លាភាព) ។ | (WB, ១៩៩៤) |
| ៥ | | ជាអ្នកគ្រប់គ្រង អ្នកបីបាច់រក្សា អ្នកថែរក្សា ការគ្រប់គ្រង ការបីបាច់ ការរក្សា ។ | រាជរដ្ឋាភិបាល |
| | | ជាវិធីសាស្ត្រដែលរដ្ឋ ស្ថាប័ន អង្គភាព ប្រើប្រាស់ក្នុងការគ្រប់គ្រងសេដ្ឋកិច្ច សង្គមកិច្ច និងសន្តិសុខ ដើម្បីបម្រើផលប្រយោជន៍រួមរបស់ប្រជាពលរដ្ឋ។ | (ក្រសួងមហាផ្ទៃ, ២០១០) |
| **អត្ថន័យរួម** | | | |
| **អភិបាលកិច្ច** | ជាដំណើរការនៃការគ្រប់គ្រងស្ថាប័នមួយ ដែលកំណត់ពីសកម្មភាពនៃការអនុវត្តតួនាទី ក្នុងការបម្រើសេវាសាធារណៈប្រកបដោយប្រសិទ្ធភាព គណនេយ្យភាព។ អ្នកស្រាវជ្រាវកំណត់សមាសភាគអភិបាលកិច្ចចំនួនបួនដើម្បីធ្វើការសិក្សាស្រាវជ្រាវ គឺ **តម្លាភាព គណនេយ្យភាព នីតិរដ្ឋ និងការចូលរួម** ។ | | |

## ២.៤. កំណែទម្រង់អភិបាលកិច្ច

យោងតាមផែនទីបង្ហាញផ្លូវ ការអប់រំកម្ពុជា ឆ្នាំ២០៣០ បានលើកឡើងថា កំណែទម្រង់អភិបាលកិច្ច គឺជាសមាសភាគស្នូលនៃផែនការយុទ្ធសាស្ត្រវិស័យអប់រំ (ក្រសួង.អ.យ.ក, ២០១៩) ។ បច្ចុប្បន្នវិធានការកំណែទម្រង់សំខាន់ៗបាននឹងកំពុងអនុវត្តដើម្បីបង្កើនសមត្ថភាព និងគណនេយ្យភាពរបស់គ្រូបង្រៀនដូចជា ការអនុវត្តយ៉ាងតឹងរ៉ឹងនូវក្រមសីលធម៌គ្រូបង្រៀនជាដើម។ ការគ្រប់គ្រងវិស័យអប់រំកាន់តែមានប្រសិទ្ធភាព តម្លាភាព និងផ្តោតលើលទ្ធផលតាមរយៈការកែលម្អការគ្រប់គ្រងថវិកាដោយផ្សារភ្ជាប់ធនធានហិរញ្ញវត្ថុជាមួយនិងលទ្ធផល ការអភិវឌ្ឍបុគ្គលិក ការពង្រឹងស្តង់ដាគុណផល ការអភិវឌ្ឍសមត្ថភាពរបស់មន្ត្រីនៅគ្រប់កម្រិតថ្នាក់ និងការកែលម្អភាពជាដៃគូរវាងរដ្ឋាភិបាល និងសហគមន៍ និងមាតាបិតាសិស្ស ដៃគូអភិវឌ្ឍន៍ វិស័យឯកជន និងអង្គការមិនមែនរដ្ឋាភិបាល។ ជាងនេះទៅទៀត វិស័យរដ្ឋបាលសាធារណៈត្រូវកំណែទម្រង់ជាទ្រង់ទ្រាយធំដើម្បីបង្កើតប្រព័ន្ធរដ្ឋបាលផ្អែកតាមលទ្ធផលការងារដើម្បីឱ្យមន្ត្រីសាធារណៈកាន់តែមានគណនេយ្យភាពនិងឆ្លើយតបតាមតម្រូវការ និងការរំពឹងទុករបស់សាធារណជនទូទៅ។

កម្មវិធីកំណែទម្រង់វិស័យអប់រំព្យាយាមបង្កើតឱ្យបានគំរូមួយ ដែលគេឱ្យឈ្មោះថាសាលារៀនជំនាន់ថ្មី ។ ក្នុងការប្រើពាក្យ **សាលារៀនជំនាន់ថ្មីនេះ** យើងចាំបាច់ត្រូវញែកឱ្យដាច់ពីគ្នារវាងសាលារៀនជំនាន់ថ្មី និងអ្វីដែលគេធ្លាប់ស្គាល់កន្លងមកថា **សាលាគំរូ** ដែលក្នុងប្រទេសកម្ពុជាសាលារៀនគំរូនេះមានប្រវត្តិជះមិនស្មើគ្នាទេ ។ ក្នុងករណីជាច្រើន សាលារៀនគំរូត្រូវបានគេប្រដូចទៅនឹងការកែលម្អសោភណ្ឌភាពបរិស្ថានសិក្សា ដែលដំបូងបង្ហាញពីភាពល្អគាប់ចិត្តផ្នែកសំបកក្រៅតែគ្មានភាពស៊ីជម្រៅ និងខ្លឹមខាងក្នុងទេ ។ អន្តរាគមន៍នានារបស់សាលារៀនគំរូ ជាទូទៅមិនបានដោះស្រាយមូលដ្ឋានគ្រឹះនានា សម្រាប់ការធ្វើឱ្យសាលារៀនមួយក្លាយទៅជាសាលារៀនល្អនោះទេ (ឧទាហរណ៍៖ គោលការណ៍អភិបាលកិច្ច) ហើយជារឿយៗសាលារៀនបែបនេះបានវិលទៅរកស្ថានភាពដើមវិញពេលអស់ជំនួយពីខាងក្រៅ។ សាលារៀនដែលទទួលបានការគាំទ្រពីគំនិតផ្តួចផ្តើមថ្មីនេះនឹងឈានឱ្យផុតពីវិធីសាស្ត្រសាលារៀនគំរូដោយធ្វើឱ្យ

មានការផ្លាស់ប្តូរពេញលេញល្អិតល្អន់មួយតាមរយៈការផ្តល់ឱ្យសាលានូវស្វ័យភាព រចនាសម្ព័ន្ធអភិបាលកិច្ចរឹងមាំ គណនេយ្យភាព និងឱកាសគន្លងអាជីពកាន់តែច្រើនដល់គ្រូបង្រៀន និងនាយកសាលាដែលមានការប្តេជ្ញាចិត្តខ្ពស់បំផុត (ក្រសួង.អ.យ.ក, ២០២០)។ ដូចនេះ សាលារៀនជំនាន់ថ្មីនឹងមិនត្រឹមតែបង្កើតបានជាគំរូនៃបរិស្ថានសិក្សាកុមារមេត្រីកម្រិតខ្ពស់ប្រកបដោយប្រសិទ្ធភាពប៉ុណ្ណោះទេ តែវានឹងដើរតួនាទីជាប្រទីបឆ្ពោះទៅរកការអនុវត្តល្អប្រសើរសម្រាប់សាលារៀនដ៏ទៃទៀតក្នុងរាជធានី និងខេត្ត។

មន្ទីរអប់រំ យុវជន និងកីឡា ទទួលស្គាល់ថាមិនមែនគ្រប់សាលារៀនទាំងអស់អាចក្លាយជាសាលារៀនជំនាន់ថ្មីនោះទេ បើមិនបានឆ្លងកាត់ដំណាក់កាលសំខាន់ៗក្នុងការកែទម្រង់ការងារអភិបាលកិច្ចសាលារៀនសាធារណៈ ។ គោលដៅនៃការកែទម្រង់អភិបាលកិច្ចនេះ គឺទាមទារវិធីសាស្ត្រពិសេសមួយដែលមិនធ្លាប់បានអនុវត្តនៅក្នុងសាលាធារណៈពីមុនមក ។ មន្ទីរនឹងផ្តល់ស្វ័យភាពកម្រិតខ្ពស់ដល់សាលារៀនដែលគាំទ្រដោយកម្មវិធី និងរចនាសម្ព័ន្ធអភិបាលកិច្ចថ្មី ដែលសាលាត្រូវស្ថិតក្រោមការគ្រប់គ្រងដោយផ្ទាល់ ពីក្រុមប្រឹក្សាភិបាលថ្នាក់រាជធានី/ខេត្ត ដែលមានតំណាងពីភាគីទាំងពីរ គឺរដ្ឋ( ឧ.មន្ត្រីអប់រំមូលដ្ឋាន)និងវិស័យឯកជន (ឧ. តំណាងសង្គមស៊ីវិល និងក្រុមហ៊ុនឯកជន។ល។) (ក្រសួង.អ.យ.ក, ២០២០) ។

នៅកម្រិតសាលារៀន សាលារៀនជំនាន់ថ្មីបានអនុវត្តនូវសកម្មភាពជាច្រើនដោយឆ្លើយតបទៅនឹងគោលនយោបាយរបស់ក្រសួង ។ ការអនុវត្តនោះរួមមាន៖ (១) សាលាបានបង្កើនគណនេយ្យភាពរបស់សាលារៀនដោយបិទផ្សាយជាសាធារណៈនូវលទ្ធផលតេស្តស្វ័យវាយតម្លៃលទ្ធផលប្រចាំឆ្នាំ ថវិកាចំណូលថវិកាចំណាយរបស់សាលារៀនកម្រិតជាប់ស្តង់ដាសាលារៀនជារៀងរាល់ចុងខែនីមួយៗ (របាយការណ៍ចំណូលចំណាយ, ២០២២)។ (២)ការបង្កើនស្វ័យភាព និងសិទ្ធអំណាច ក្នុងការសម្រេចចិត្តនៅកម្រិតសាលារៀនតាមរយៈគណៈកម្មការគ្រប់គ្រងសាលារៀន ទៅលើការដេញថ្លៃសាងសង់អាហារដ្ឋានវិទ្យាល័យព្រះស៊ីសុវត្ថិ (របាយការណ៍លទ្ធកម្ម, ២០២១) ។ ក្នុងការបង្កើនស្វ័យភាព និងសិទ្ធអំណាចនេះសាលាបានបង្កើនគណៈកម្មការលទ្ធកម្មមួយដើម្បីបង្ហាញពីសិទ្ធអំណាចក្នុងការធ្វើសេចក្តីសម្រេចចិត្ត

ដោយមានការចូលរួមដេញថ្លៃទិញសម្ភារៈផ្សេងៗ និងសាងសង់ដោយមានការចូលរួមពីគ្រប់គាគីដែលពាក់ព័ន្ធក្នុងសាលារៀន ដោយសមាសភាពក្នុងគណៈកម្មការលទ្ធកម្មរួមមានគណៈគ្រប់គ្រងសាលារៀន គណៈកម្មការទ្រប់គ្រងសាលារៀន និងលោកគ្រូអ្នកគ្រូ។ (៣)ការបង្កើនការចូលរួមរបស់មាតាបិតា ៖ សាលារៀនជំនាន់ថ្មីកន្លងមកបានអនុវត្តជារៀងរាល់ឆ្នាំម្តង ឬពីរដង គឺបានអញ្ជើញអ្នកអាណាព្យាបាលសិស្សចូលរួមប្រជុំដើម្បីដឹងពីរបៀបនៃការតាមដានព័ត៌មាននៃការសិក្សារបស់កូនៗរបស់ខ្លួននៅសាលារៀន (របាយការណ៍ប្រជុំមាតាបិតាសិស្ស, ២០២១)។ យោងតាមរបាយការណ៍នៃការប្រជុំរបស់សាលារៀនជំនាន់ថ្មីវិទ្យាល័យព្រះស៊ីសុវត្ថិបានបង្ហាញថា ប្រធានគណៈកម្មការគ្រប់គ្រងសាលារៀន គឺលោក តុង សុប្រាជ្ញ បានចូលរួមដោយស្ម័គ្រចិត្តក្នុងការបើកវគ្គសិក្ខាសាលា "ការគិតបែបស៊ីជម្រៅ" ដោយធ្វើបទបង្ហាញដោយលោកផ្ទាល់ទៅកាន់លោកគ្រូអ្នកគ្រូទាំងអស់រៀងរាល់ថ្ងៃសៅរ៍រយៈពេល១ខែ នៃការបណ្តុះបណ្តាលនេះ (របាយការណ៍ប្រជុំPLC, ២០២១)។ ទាំងនេះសបញ្ជាក់ឱ្យឃើញថាភាពសកម្មនៃការចូលរួមរបស់គណៈកម្មការគ្រប់គ្រងសាលារៀនមានទំនាក់ទំនងយ៉ាងជិតស្និទ្ធក្នុងការចូលរួមអភិវឌ្ឍន៍សាលារៀន។

សាលារៀនជំនាន់ថ្មី ដោយផ្តោតលើការផ្តល់ស្វ័យភាពក្នុងការអនុវត្តកម្មវិធីសិក្សាដើម្បីបណ្តុះបណ្តាលធនធានមនុស្សមានបំណិនសតវត្សទី២១ ក្នុងនោះគណៈគ្រប់គ្រងសាលារៀន និងគ្រូបង្រៀនមាន៖ (១) សីលធម៌ និងស្តង់ដាវិជ្ជាជីវខ្ពស់៖ គ្រូបង្រៀននៅសាលារៀនជំនាន់ថ្មី មានសីលធម៌ល្អ និងស្តង់ដាវិជ្ជាជីវៈខ្ពស់ ដូចជាការមិនគៀងគរសិស្សបង្រៀនគួរ បង្រៀនគោរពេលវេលាច្បាស់លាស់ (របាយការណ៍វាយតម្លៃប្រចាំឆ្នាំ, ២០២១)។

## ២.៥. គោលការណ៍ស្នូលនៃគំរូអភិបាលកិច្ចថ្មី

យោងតាមគោលការណ៍ណែនាំប្រតិបត្តិកម្មវិធីសាលារៀនជំនាន់ថ្មី (២០២០) បានកំណត់គោលការណ៍ស្នូលនៃគំរូអភិបាលកិច្ចថ្មីមួយដែលបានសង្ខេបជាគោលការណ៍ទាំងនេះដូចខាងក្រោម ៖

១. ស្តង់ដាថ្មីនៃអភិបាលកិច្ចដោយមានគណនេយ្យភាពតឹងរ៉ឹងក្នុងការបំពេញភារកិច្ច

២. ស្តង់ដាវិជ្ជាជីវៈខ្ពស់

៣. ស្វ័យភាពក្នុងការប្រតិបត្តិ

៤. ប្រព័ន្ធវាយតម្លៃទទួលស្គាល់គុណភាព

៥. ក្របខណ្ឌនៃការបែងចែកធនធានប្រកបដោយសនិទានភាព

គោលការណ៍ស្នូលបង្កប់នៅក្នុងសាលារៀនជំនាន់ថ្មី ទាក់ទងនឹងរចនាសម្ព័ន្ធអភិបាលកិច្ចថ្មី។ រចនាសម្ព័ន្ធនេះផ្តល់ស្វ័យភាពលើដំណើរការដល់នាយកសាលាដើម្បីច្នៃប្រឌិត និងធានាស្តង់ដាវិជ្ជាជីវៈខ្ពស់នៅគ្រប់កម្រិត (ក្រសួង.អ.យ.ក, ២០២០)។ ទោះជាយ៉ាងណាក៏ដោយ តម្លៃស្វ័យភាពនេះគឺថាគេត្រូវតែមានការទទួលខុសត្រូវតឹងរ៉ឹងបំផុតសម្រាប់ការបំពេញភារកិច្ចរបស់សាលាដែលទាក់ទងនឹងការប្រកាន់ភ្ជាប់សេចក្តីណែនាំដំណើរការដែលកំណត់និយមន័យសាលារៀនជំនាន់ថ្មី ។ ការប្រកាន់ខ្ជាប់បែបនេះពាក់ព័ន្ធនឹងទិដ្ឋភាពគណនេយ្យភាពសំខាន់ៗដូចជា៖

- ❖ ធានាថាគ្រូទាំងអស់បានបំពេញភារកិច្ចត្រឹមត្រូវតាមភារកិច្ចដែលបានព្រមព្រៀងសម្រាប់ការទទួលបានប្រាក់លើកទឹកចិត្ត។
- ❖ ធានាថាគ្រូនឹងមិនបង្រៀនគួរដល់សិស្សរបស់ខ្លួន ។
- ❖ ធានាថាគ្រូអនុវត្តតាមលក្ខណៈវិនិច្ឆ័យគន្លងអាជីពគ្រូបង្រៀន។
- ❖ ធានាថាសិស្សទាំងអស់ទទួលបានសេវាកម្មចាំបាច់នានាដូចជា សេវាសិក្សាចល័ត សេវាប្រឹក្សាអាជីពជាដើម។ល។
- ❖ ធានាថាមានការថែទាំ និងជួសជុលត្រឹមត្រូវចំពោះសម្ភារៈដែលបានវិនិយោគ និងធានាថាបានបើកទ្វារបម្រើសេវាជាប្រចាំ (ដូចជា៖ បណ្ណាល័យ បន្ទប់កុំព្យូទ័រ ជាដើម។ល។)

តាមរយៈការអនុវត្តជាក់ស្តែងនៅសាលារៀនជំនាន់ថ្មីទាំងពីរ នៃវិទ្យាល័យព្រះស៊ីសុវត្ថិ និងវិទ្យាល័យព្រែកលៀបឃើញថា ស្តង់ដាថ្មីនៃអភិបាលកិច្ចដោយមានគណនេយ្យភាពតឹងរ៉ឹងក្នុងការបំពេញភារកិច្ចគឺមានភាពច្បាស់លាស់ នៃការគោរពម៉ោងពេលវេលាចូលធ្វើការរបស់បុគ្គលិកការិយាល័យ និងការ

គោរពពេលវេលាបង្រៀនតាមកាលវិភាគរបស់លោកគ្រូអ្នកគ្រូនៅទៅនោះមានអត្រាភាគរយខ្ពស់ (របាយការណ៍វត្តមានគ្រូ, ២០២២)។ ចំពោះស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀននៅទីនោះមានស្តង់ដាវិជ្ជាជីវៈខ្ពស់ គឺគ្រូមិនបង្រៀនគួរជាដាច់ខាត ។ យោងតាមរបាយការណ៍ចុះស្រាវជ្រាវផ្ទាល់បានបង្ហាញថាសញ្ញាបត្រគ្រូនៅវិទ្យាល័យព្រែកលៀប និងវិទ្យាល័យព្រះស៊ីសុវត្ថិ គ្រូមានបរិញ្ញាបត្រចំនួន ៧២.៩៧% និង បរិញ្ញាបត្រជាន់ខ្ពស់ចំនួន ១៨.៩២% នៃចំនួនគ្រូសរុប១១១នាក់ ដែលបង្ហាញពីផ្នែកមួយនៃស្តង់ដាវិជ្ជាជីវៈខ្ពស់របស់គ្រូបង្រៀនផងដែរ។

ស្វ័យភាពក្នុងការប្រតិបត្តិ សាលារៀនមានឯករាជ្យភាគច្រើនក្នុងការសម្រេចចិត្តធ្វើអ្វីមួយទៅតាមគោលការណ៍សាលារៀនជំនាន់ថ្មីដែលបានកំណត់ ។ ស្វ័យភាពក្នុងការប្រតិបត្តិនោះរួមមាន ៖ (១) ស្វ័យភាពលើកម្មវិធីសិក្សា (២)ការគ្រប់គ្រងបុគ្គលិក (៣)ការគ្រោងថវិកា ការរៀបចំផែនការចំណាយ និងការដាក់ស្នើគម្រោងថវិកា ។

(១)ស្វ័យភាស្វ័យភាពលើកម្មវិធិសិក្សា៖ ក្នុងការប្រតិបត្តិនេះគឺមានភាពខ្លាំងជាងសាលាធម្មតាត្រង់ថាសាលាមានភាពទទួលខុសត្រូវខ្ពស់ចំពោះភាគីដែលពាក់ព័ន្ធគឺចំពោះមុខ ក្រុមប្រឹក្សាភិបាលថ្នាក់ជាតិ ថ្នាក់រាជធានី គណៈកម្មការគ្រប់គ្រងសាលារៀន និងអ្នកអាណាព្យាបាលសិស្សគ្រប់រូប។ ជាក់ស្តែងសាលាមានស្វ័យភាពក្នុងការបន្ថែមកម្មវិធីសិក្សាថ្នាក់ភាសាអង់គ្លេសខុសប្លែកពីសាលារដ្ឋធម្មតា ដោយឱ្យសិស្សគ្រប់កម្រិតថ្នាក់ធ្វើតេស្តរៀនទៅតាមសមត្ថភាពរបស់ខ្លួន ។ បន្ទាប់ពីធ្វើតេស្តភាសាអង់គ្លេសដឹងពីកម្រិតសមត្ថភាពរបស់ខ្លួនហើយ សាលានឹងរៀបចំជាកាលវិភាគសម្រាប់ពួកគេ។ ការធ្វើបែបនេះដើម្បីងាយស្រួលក្នុងការបង្រៀន និងរៀនរបស់សិស្ស (របាយកាណ៍តេស្តភាសាអង់គ្លេស, ២០២២) ។ មួយវិញទៀតគឺលើកម្មវិធីសិក្សា មុខវិជ្ជាព័ត៌មានវិទ្យា សាលាបានដាក់បង្រៀនកម្មវិធីមួយចំនួនដូចជា Code.org, កម្មវិធី C++, កម្មវិធី Python ខណៈដែលកម្មវិធីសិក្សានៅសាលារៀនធម្មតា បង្រៀនសិស្សលើកម្មវិធី Microsoft Office (កម្មវិធីសិក្សា, ២០២២) ។

(២) ការគ្រប់គ្រងបុគ្គលិកៈ សាលារៀនជំនាន់ថ្មីមានស្វ័យភាពក្នុងការប្រកាសជ្រើសរើសគ្រូពីគ្រូពីគ្រប់ស្ថានប័នរដ្ឋដើម្បីចូលបម្រើការងារ (ក្រសួង.អ.យ.ក, ២០១៦a)។ ជារៀងរាល់ឆ្នាំសាលារៀនជំនាន់ថ្មីតែងតែប្រកាសជ្រើសរើសគ្រូដើម្បីធ្វើការសម្ភាសន៍ពីគ្រប់ស្ថាប័នរដ្ឋ។ រាល់លោកគ្រូអ្នកគ្រូដែលបានសម្ភាសន៍ជាប់នៅសាលារៀនជំនាន់ថ្មី សាលានិងធ្វើកិច្ចសន្យាការងារជាមួយគ្នារយៈពេលមួយឆ្នាំ និងស្នើធ្វើលិខិតឧទ្ទេសនាមឱ្យចូលបម្រើការងាររយៈពេល១ឆ្នាំពីក្រសួងអប់រំ យុវជន និងកីឡា។ នៅក្នុងលិខិតឧទ្ទេសនាមនោះបានចែងថា សមីជនត្រូវបានរក្សា ក្របខណ្ឌ បៀវត្ស ការតំឡើងថ្នាក់ ឋានន្តរស័ក្តិ និងអតីតភាពការងារសម្រាប់ទទួលសោធននិវត្តន៍ ។ មួយទៀត "សមីជនត្រូវដាក់ពាក្យសុំចូលបម្រើការងារវិញនៅអង្គភាពដើម ឬសុំបន្តក្នុងការមានតម្រូវការពីសាលារៀនជំនាន់ថ្មី" (លិខិតឧទ្ទេសនាមចូលបម្រើការងារនៅសាលារៀនជំនាន់ថ្មី, ២០១៧)។ ក្រោយពីបញ្ចប់កិច្ចសន្យារយៈពេល១ឆ្នាំ ក្នុងករណីលោកគ្រូអ្នកគ្រូនៅបន្តកិច្ចកិច្ចសន្យាទៀត សាលានឹងស្នើធ្វើប្រកាសដើម្បីផ្លាស់ចូលបម្រើការងារនៅសាលារៀនជំនាន់ថ្មី ដែលនៅក្នុងប្រកាសនោះចែងថា "សមីជនមានសិទ្ធទទួលប្រាក់បៀវត្ស និងប្រាក់ឧបត្ថម្ភផ្សេងៗនៅអង្គភាពថ្មី ក្រោយពេលផ្តាច់ប្រាក់បៀវត្សជាស្ថាពរពីអង្គភាពចាស់។ សមីជនត្រូវទៅបម្រើការងារនៅអង្គភាពដើមវិញក្រោយពីបញ្ចប់ភារកិច្ចនៅសាលារៀនជំនាន់ថ្មី" (ប្រកាស, ២០១៩)។

(៣) ការគ្រោងថវិកា ការរៀបចំផែនការចំណាយ និងការដាក់ស្នើគម្រោងថវិកាៈ សាលារៀនជំនាន់ថ្មីទាំងពីរជារៀងរាល់ឆ្នាំ ដើមឆ្នាំសិក្សាជានិច្ចកាលតែងតែធ្វើការប្រជុំលើការគ្រោងថវិកា (Budget Plan) ដើម្បីធ្វើបង្ហាញពីទិន្នន័យថវិកាសាលារៀន ទាំងថវិកាចំណូល និងថវិកាចំណាយ ។ ការគ្រោងថវិកានេះក្នុងគោលបំណងមាននិរន្តរភាពសាលារៀន បង្ហាញពីតម្លាភាព គណនេយ្យភាព ជូនភាគីដែលពាក់ព័ន្ធ ។ រាល់ការប្រជុំគ្រោងធ្វើផែនការថវិកាសាលារៀននេះមានការចូលរួមដឹងលឺពីគ្រប់ភាគីពាក់ព័ន្ធ ដូចជា គណៈគ្រប់គ្រងសាលារៀន លោកគ្រូអ្នកគ្រូ តំណាងចូលរួមរបស់គណៈកម្មការគ្រប់គ្រងសាលារៀន ក្រុមប្រឹក្សាកុមារ ដើម្បីលើកពីធាតុចូល ការលើកឡើងពីបញ្ហាដែលគ្រោងចំណាយដើម្បីដោះស្រាយបញ្ហានានា ដែលសាលាកំពុងជួបប្រទះ (របាយការណ៍ប្រជុំ, ២០២២) ។

ប្រព័ន្ធវាយតម្លៃគុណភាពដើម្បីទទួលស្គាល់គុណភាពរបស់សាលារៀនជំនាន់ថ្មី តែងតែវាយតម្លៃរៀងរាល់មួយឆ្នាំម្តងដើម្បីទទួលបានវិញ្ញាបនបត្រទទួលស្គាល់សាលារៀនជំនាន់ថ្មី ។ ដើម្បីឈានដល់ការវាយតម្លៃរបស់គណៈកម្មការវាយតម្លៃទទួលស្គាល់គុណភាព សាលារៀនត្រូវមានការធ្វើស្វ័យវាយតម្លៃខ្លួនឯងជាមុនសិន ។ ស្វ័យវាយតម្លៃសាលារៀនគឺជាកិច្ចការមួយដែលមានសារៈសំខាន់បំផុត ក្នុងការជួយដល់គណៈគ្រប់គ្រងក្នុងការជួយធ្វើផែនការអភិវឌ្ឍសាលារៀន ដើម្បីឆ្លើយតបទៅនិងតម្រូវការ និងបញ្ហាជាក់ស្តែងរបស់មូលដ្ឋាន (ក្រសួងអ.យ.ក, ២០១៧) ។ ស្វ័យវាយតម្លៃក៏បានប្រាប់ពីបញ្ហាប្រឈម ដែលកើតមកពីនាយកសាលា លោកគ្រូអ្នកគ្រូ សិស្សានុសិស្ស គណៈកម្មការសាលា និងសហគមន៍ សម្រាប់អ្នកទាំងអស់គ្នាមានវិធានការដោះស្រាយ គាំទ្រដល់ការសិក្សារបស់សិស្សឱ្យទទួលលទ្ធផលសិក្សាកាន់តែប្រសើរឡើង ។

ការវាយតម្លៃទទួលស្គាល់គុណភាពរបស់សាលារៀនជំនាន់ថ្មីត្រូវបានចូលរួមពីសំណាក់ ក្រុមប្រឹក្សាភិបាលថ្នាក់ជាតិ ក្រុមប្រឹក្សាថ្នាក់រាជធានី ព្រមទាំងសមាជិកគណៈកម្មការវាយតម្លៃដែលមកពីបណ្តាស្ថាប័ន និងអង្គការខេបផងដែរ ។ ការទទួលស្គាល់គុណភាពអប់រំនេះត្រូវផ្អែកលើលក្ខណៈវិនិច្ឆ័យដាច់ខាត១០០% និងលក្ខណៈវិនិច្ឆ័យជម្រើស ៥០% (ក្រសួង.អ.យ.ក, ២០២០)។

### ២.៥.១. អំពីម៉ោងធ្វើការនៅសាលារៀនជំនាន់ថ្មី

ម៉ោងធ្វើការរបស់និយោជិតនៅក្នុងសាលាមានចំនួន ៤៨ ម៉ោងក្នុងមួយសប្តាហ៍សម្រាប់ម៉ោងធ្វើការ(២០ម៉ោងបង្រៀនសិស្ស និង២៨ម៉ោងការងារគាំទ្រ) លើកលែងក្នុងករណីពិសេស។ សាលារៀនចាប់ផ្តើមដំណើរការពីថ្ងៃចន្ទដល់ថ្ងៃសៅរ៍ ចាប់ពីម៉ោង៧ព្រឹកដល់ម៉ោង១១:៣០នាទីព្រឹក និងពីម៉ោង១រសៀលដល់ម៉ោង៥ល្ងាច (ថ្ងៃសៅរ៍ពីម៉ោង១រសៀលដល់ម៉ោង៥ ល្ងាចប្រជុំរួម និងបច្ចេកទេសបើចាំបាច់) ។

និយោជិតទទួលបានច្បាប់ឈប់សម្រាកកាន់ទុក្ខចំនួន៣ថ្ងៃ ក្នុងករណីឪពុកម្តាយ ប្រពន្ធ កូនទទួលមរណភាព(រួមទាំងឪពុកម្តាយក្មេក)។ និយោជិតមានសិទ្ធិសុំច្បាប់ឈប់សម្រាកពេលមានជម្ងឺ ឬមានធុរៈបានចំនួន ១៥ថ្ងៃក្នុង១ឆ្នាំ ។ បើនិយោជិតមិនជូនដំណឹងសាលារៀនជំនាន់ថ្មី អំពីការខកខាន

របស់ខ្លួនក្នុងការចូលរួមបំពេញការងារដោយសារជម្ងឺទេ រឺសុំច្បាប់ឈប់លើសការកំណត់ សាលារក្សាសិទ្ធិកាត់ប្រាក់ឧបត្ថម្ភតាមអត្រាពេលវេលាជាក់ស្តែង ។

និយោជិតអាចឈប់សម្រាកតាមថ្ងៃឈប់សម្រាករបស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា។ ថ្ងៃឈប់សម្រាកនឹងអនុវត្តតាមថ្ងៃឈប់សម្រាកកំណត់ដោយរាជរដ្ឋាភិបាល (ក្រសួង.អ.យ.ក, ២០២០)។

### ២.៥.២. ស្វ័យភាពប្រតិបត្តិការសាលារៀន

សាលារៀនជំនាន់ថ្មីនឹងទទួលបានសិទ្ធិជាស្ថាប័នស្វយ័តដើម្បីអនុវត្តសកម្មភាព ខាងក្រៅក្របខណ្ឌគោលនយោបាយមានស្រាប់របស់ក្រសួង សកម្មភាពជាក់ស្តែងត្រូវតែកែតម្រូវដើម្បីបង្ហាញការផ្សារភ្ជាប់ទៅនឹងការច្នៃប្រឌិតថ្មីក្នុងវិស័យអប់រំ និងលើកកម្ពស់គុណភាពអប់រំ (ដូចជា៖ ការកាត់បន្ថយកម្រិតផលធៀប សិស្ស ថ្នាក់រៀន ដើម្បីកែលម្អគុណភាពអប់រំជាដើម។ល។ ការប្រើកម្មវិធីសុសវែរ (software) មានអាជ្ញាបណ្ណដើម្បីបង្កើនការច្នៃប្រឌិតថ្មី និងប្រសិទ្ធភាព។ល។ (ក្រសួង.អ.យ.ក, ២០២០)។ ស្វ័យភាពប្រតិបត្តិការគឺអាស្រ័យលើសមត្ថភាពរបស់សាលារៀនជំនាន់ថ្មី ដើម្បីបង្ហាញនវានុវត្តន៍អប់រំស្តង់ដាអប់រំខ្ពស់ និងលទ្ធផលសិក្សាសិស្សខ្ពស់។ ផ្នែកស្វ័យភាពប្រតិបត្តិការ សាលារៀនអាចបញ្ចូល និងបន្ថែមលើសពីចំណុចដែលបានលើកឡើងខាងក្រោម៖

សាលារៀនំនាន់ថ្មីមានស្វ័យភាពក្នុងការពង្រីកកម្មវិធីសិក្សាដូចជា កម្មវិធីកុំព្យូទ័រ ដោយការបង្រៀននិងរៀនខុសពីសាលារៀនធម្មតាគឺ សាលារៀនជំនាន់ថ្មី បានពង្រីកកម្មវិធីសិក្សាគឺការសរសេរកូដ code.org កម្មវិធី C++, កម្មវិធី Python (កម្មវិធីសិក្សា, ២០២២) ។ មួយវិញទៀតគឺកម្មវិធីបំណិនជីវិតដោយសាលារៀនបានបញ្ចូលកម្មវិធីមួយចំនួនដូចជា ការដាំបន្លែ ការចិញ្ចឹមកង្កែប ការដុតនំ(ដុតនំប៉័ង) ជាដើម (របាយការណ៍គ្រូបំណិនជីវិត, ២០២៣)។

- ការបន្ថយផលធៀបសិស្ស ថ្នាក់រៀន (មិនឱ្យលើស៣៦នាក់)
- ការជ្រើសរើសគ្រូ និងបុគ្គលិកផ្សេងទៀតពីខាងក្រៅអង្គភាពបាន
- ការរៀបចំការប្រឡងចំពោះសិស្សដែលចូលរៀនក្នុងកម្មវិធីជំនាន់ថ្មី

- ❖ ការធ្វើកិច្ចតែងការបង្រៀន និងកំណត់ត្រាថ្នាក់រៀនតាមទម្រង់អេឡិចត្រូនិក
- ❖ ការទិញកម្មវិធីកុំព្យូទ័រដែលមានអាជ្ញាបណ្ណ
- ❖ ការយកវិភាគទានថ្លៃសិក្សាដោយស្ម័គ្រចិត្ត ពីឪពុកម្តាយដោយមាន ការព្រមព្រៀងជាមួយសហគមន៍។

ការត្រួតពិនិត្យសាលារៀនជំនាន់ថ្មី នឹងស្ថិតក្រោមការទទួលខុសត្រូវដោយផ្ទាល់របស់ក្រសួងនៅថ្នាក់ជាតិ។ មន្ត្រីអប់រំនៅថ្នាក់មូលដ្ឋាន ត្រូវមានព័ត៌មានអំពីវឌ្ឍនភាពសាលារៀនជំនាន់ថ្មី នៅក្នុងដែនអំណាចរបស់ខ្លួន និងចូលរួមអនុវត្តតាមលក្ខណៈវិនិច្ឆ័យសាលារៀនជំនាន់ថ្មី។ ក្រុមប្រឹក្សាភិបាលថ្នាក់ជាតិ នឹងធ្វើការទទួលខុសត្រូវសាលារៀនជំនាន់ថ្មីលើការត្រួតពិនិត្យចំពោះលទ្ធផលសម្រេចបាន ដោយពិនិត្យមើល ការវាស់វែងខាងក្រៅនៃលទ្ធផលសិក្សាដូចជា ការប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ ការប្រឡង PISA ជាដើម។ល។ ស្វ័យភាពស្ថាប័នរបស់សាលារៀនជំនាន់ថ្មី អាស្រ័យទាំងស្រុងទៅលើសមត្ថភាពរបស់សាលាដែលបង្ហាញពីភាពខ្លាំងលើផ្នែកលទ្ធផលសិក្សា។

**២.៦. សាលាធម្មនុញ្ញ** (Charter School)

សាលារៀនជំនាន់ថ្មីអនុវត្តតាមគំរូពីប្រទេសផ្សេងៗ ដែលសាលារៀនរដ្ឋមួយចំនួនទទួលបានស្វ័យភាពពេញលេញពីរដ្ឋក្នុងការច្នៃប្រឌិតកម្មវិធីអប់រំ។ ចំណុចនេះគឺ សំដៅពិសេសទៅលើចលនា **"សាលារៀនធម្មនុញ្ញ" ឬ Charter School** នៅសហរដ្ឋអាមេរិក និងប្រទេសដទៃទៀត (ខេប, ២០១៨)។ យោងតាមអត្ថបទស្រាវជ្រាវបានបង្ហាញថា សាលារៀនធម្មធនុញ្ញជាសាលាដែលមានស្វ័យភាព និងមានភាពបទបែនច្រើនជាងសាលារដ្ឋបែបប្រពៃណីដែលមានឯករាជ្យរបស់សាលា (Wohlstetteret al, 1995)។ បន្ថែមជាងនេះទៅទៀត សាលារៀនដែលមានស្វ័យភាពគឺជាសាលាដែលមានភាពច្នៃប្រឌិតខ្ពស់ និងមានគុណភាពខ្ពស់ជាងសាលារដ្ឋបែបប្រពៃណី ដូចជាការបង្រៀន និងរៀន កម្មវិធីសិក្សា ការរៀបចំអភិបាលកិច្ចសាលារៀន គុណវុឌ្ឍិគ្រូបង្រៀន និងការចូលរួមរបស់ក្រុមគ្រូបង្រៀន (Arsen, Plank, & Sykes, 1999)។ ការរួមបញ្ចូលគ្នានៃស្វ័យភាព ការច្នៃប្រឌិត និងទំនួលខុសត្រូវនឹងនាំទៅដល់ការធ្វើឱ្យ

ប្រសើរឡើង នូវសមិទ្ធិផលរបស់សិស្សផ្តល់សិទ្ធអំណាចខ្ពស់ទៅកាន់គ្រូបង្រៀនក្នុងការអប់រំសិស្ស ការពេញចិត្តខ្ពស់ពីសំណាក់អាណាព្យាបាលសិស្ស និងជះឥទ្ធិពលវិជ្ជមានលើប្រព័ន្ធអប់រំសាធារណៈ ។

បើគ្មានស្វ័យភាពទេ សាលាធម្មនុញ្ញក៏មិនអាចផ្តល់ជម្រើសអប់រំពិសេសដល់សិស្សានុសិស្សបានឡើយ។ សិស្សានុសិស្សពុំមាន "បន្ទប់ពិសោធន៍" សម្រាប់គ្រូ និងសិស្សងាយស្រួលក្នុងការបង្រៀនបានទេ (Hassel, 1999)។

### ២.៦.១. អភិបាលកិច្ច និងការគ្រប់គ្រង

ការគ្រប់គ្រងលើប្រតិបត្តិការសាលារៀនភាគច្រើនតាមរយៈការពង្រឹងស្វ័យភាព និងសារៈសំខាន់បំផុតជាងនេះទៀតរបស់សាលារៀនធម្មនុញ្ញគឺជាច្នៃប្រឌិតថ្មី (Arsen et al, 1999)។ អភិបាលកិច្ចនៃសាលារៀនធម្មនុញ្ញការគ្រប់គ្រងគឺមានភាពចម្រុះ ដែលបានចូលរួមយ៉ាងសកម្មពីសំណាក់ គណៈគ្រប់គ្រងសាលារៀន គ្រូបង្រៀន និងអ្នកអាណាព្យាបាលសិស្ស (Wells et al., 1998; WestEd & University of Southern California, 1998)។

តើសាលារៀនធម្មនុញ្ញមានគណនេយ្យភាពដែរឬទេ? គណនេយ្យភាពរបស់សាលារៀនធម្មនុញ្ញពាក់ព័ន្ធនឹងទំនួលខុសត្រូវខ្ពស់ចំពោះទាំងរដ្ឋាភិបាលផង អាណាព្យាបាលសិស្ស និងសិស្ស (Garn & Cobb, 2001)។

យោងតាមការស្រាវជ្រាវរបស់លោក Kolderie, 1990 បានបង្ហាញថាសាលារៀនធម្មនុញ្ញគឺជាសាលាដែលបានធ្វើឱ្យប្រសើរឡើងនូវសមិទ្ធិផលការសិក្សារបស់សិស្ស ការកែលម្អការរៀនសូត្ររបស់សិស្ស កែលម្អសាលារៀនសាធារណៈបែបប្រពៃណីទៅជាសាលារៀនដែលឆ្លើយតបទៅនឹងការប្រកួតប្រជែងថ្មី ដែលទទួលបានការពេញចិត្តខ្ពស់ពីអ្នកអាណាព្យាបាលសិស្ស សហគមន៍ និងគ្រូបង្រៀនជាច្រើនទៀត ។

## ២.៧. សាលារៀនល្អ

សាលារៀន គឺជាកោសិកាស្នូលនៃប្រព័ន្ធអប់រំ។ នាយក គឺជាអ្នកដឹកនាំការរៀន និងការបង្រៀន។ សាលារៀនល្អ គឺសាលាដែលគណៈគ្រប់គ្រង និងគ្រូទាំងអស់គោរពបានយ៉ាងពេញលេញនូវតម្លៃជាមូលដ្ឋាន (Strong core values) មានបេសកកម្មច្បាស់លាស់ កំណត់នូវលទ្ធផលខ្ពស់ (High Expectations) ដែលគ្រូ និងសិស្សត្រូវសម្រេចឱ្យបាន និងត្រូវមាននាយកដែលមានសមត្ថភាពក្នុងការដឹកនាំអនុវត្តនូវទស្សនវិស័យនេះ (ណារ៉ុន, ២០២០)។ ក្នុងន័យនេះនាយកដើរតួនាទីមិនអាចខ្វះបានក្នុងការជានាឱ្យសិស្សទទួលជោគជ័យក្នុងការសិក្សា។ ការសិក្សាបង្ហាញឱ្យឃើញថា នាយកល្អនឹងបង្កើនលទ្ធផលសិក្សារបស់សិស្សបាន២០ភាគរយ បើប្រៀបធៀបទៅនឹងនាយកធម្មតា។ លទ្ធផលសិក្សារបស់សិស្សចំណុះឱ្យកត្តាធំៗចំនួន៤ គឺ ៖ គ្រូល្អដែលមានគុណវុឌ្ឍខ្ពស់យកចិត្តទុកដាក់ និងមានវិធីសាស្ត្របង្រៀនល្អ។ គ្រូល្អអាចបម្រើការងារនៅក្នុងសាលាបានដោយសារមាននាយកល្អ។

## ២.៨. ស្តង់ដាសាលារៀនមានគុណភាព

សាលាល្អ គឺជាសាលាដែលសម្រេចបានតាមស្តង់ដារ។ ក្រសួងអប់រំ យុវជន និងកីឡាបានអនុមតិស្តង់ដារសាលារៀននេះឡើង ដើម្បីលើកទឹកចិត្តដល់ភាគីពាក់ព័ន្ធទាំងអស់ឱ្យចូលរួមអភិវឌ្ឍសាលារៀន និងគ្រប់គ្រងសាលារៀនប្រកបដោយប្រសិទ្ធភាព ក្នុងគោលដៅលើកកម្ពស់គុណភាពអប់រំ។ ស្តង់ដារសាលារៀនចែកចេញជា៩ផ្នែកគឺ៖

**១) វត្ថុបំណងគោលនយោបាយ**

- ការចូលរៀនតាមថ្នាក់ ត្រួតថ្នាក់ បោះបង់ ឡើងថ្នាក់
- លទ្ធផលតេស្តមុខវិជ្ជាសិក្សាគោល
- លទ្ធផលតេស្តមុខវិជ្ជាវិទ្យាសាស្ត្រនិងព័ត៌មានវិទ្យា (P,C,B,E,ICT)
- លទ្ធផលតេស្តសមត្ថភាពអានភាសាខ្មែរ "លើស២០០ពាក្យ/នាទី"

**២) ការបង្រៀន និងការបែងចែកកម្មវិធី**

- ធ្វើបំណែងចែកកម្មវិធីសិក្សាតាមមុខវិជ្ជា និងតាមកម្រិតថ្នាក់
- កិច្ចតែងការបង្រៀនតាមមេរៀន និងតាមកម្រិតថ្នាក់

**៣) មាតាបិតា និងសហគមន៍ជួយដល់ការរៀនសូត្រ**

- ការជួបប្រជុំពិគ្រោះយោបល់ជាមួយមាតាបិតា «មុនបវេសនកាល-ដំណាច់ឆមាសទី១»
- ការប្រជុំរបស់គណៈកម្មការគ្រប់គ្រងសាលា
- មាតាបិតាសន្យាជួយសិស្សមករៀនមិនទាន់ពេល (ត្រីមាស.១-២-៣)
- មាតាបិតាសិស្សសន្យាជួយសិស្សធ្វើកិច្ចការផ្ទះ (ត្រីមាស.១-២-៣)

**៤) សិស្ស និងសេវាជួយសិស្ស**

- សិស្សប្រើបណ្ណាល័យ (ចំនួនដងប្រើក្នុងត្រីមាស.១-២-៣)
- សិស្សប្រើបន្ទប់ពិសោធន៍វិទ្យាសាស្ត្រ កុំព្យូទ័រ ភាសាបរទេស (ត្រីមាស.១-២-៣)
- ទស្សនកិច្ចសម្រាប់គ្រូបង្រៀន
- ទស្សនកិច្ចសម្រាប់សិស្ស
- ប្រអប់សង្គ្រោះបឋម

**៥) ការដឹកនាំ និងគ្រប់គ្រង**

- ការរៀបចំរដ្ឋបាលសាលារៀន
- ផែនការអធិការកិច្ចគ្រូបង្រៀនរបស់នាយក
- ការប្រជុំបច្ចេកទេសរបស់សាលារៀន
- គ្រូបង្រៀនទទួលការវាយតម្លៃប្រចាំឆ្នាំលើការអនុវត្តការងារ
- ការទទួលបានការចុះជួយរបស់ការិយាល័យអប់រំ យុវជន និងកីឡា និងមន្ទីរអប់រំយុវជន និងកីឡាខេត្ត/ក្រុង

៦) ធនធានមនុស្ស

- ស្ថានភាពបុគ្គលិកអប់រំក្នុងសាលារៀន "គ្រូតាមមុខវិជ្ជា និងគុណវុឌ្ឍិ"
- គ្រូបង្រៀនសុទ្ធសាធ និងគុណវុឌ្ឍិ (បឋមភូមិ-ទុតិយភូមិ)
- ផលធៀបសិស្ស-គ្រូ សិស្ស-ថ្នាក់ សិស្ស-បន្ទប់ គ្រូ-ថ្នាក់ (បឋមភូមិ-ទុតិយភូមិ)
- នាយក-នាយិកា បណ្ណារក្ស គណនេយ្យករ បេឡាករ លេខាធិការ និងគុណវុឌ្ឍិ (កម្រិតវប្បធម៌ ជំនាញ ឯកទេស ក្របខណ្ឌ អតីតភាពការងារ)
- នាយក-នាយិកា បណ្ណារក្ស គណនេយ្យករ បេឡាករ លេខាធិការ និងការបំប៉ន

៧) សម្ភារៈបង្រៀន និងរៀន

- ចំនួនសៀវភៅសិក្សាគោល (តាមមុខវិជ្ជា និងតាមកម្រិតថ្នាក់)
- ចំនួនសៀវភៅគ្រូ (តាមមុខវិជ្ជា និងតាមកម្រិតថ្នាក់)
- បណ្ណាល័យមានសៀវភៅតាមស្តង់ដា
- បន្ទប់ភាសាបរទេសនិងសម្ភារ និងឧបករណ៍
- បន្ទប់បំណិនជីវិតមូលដ្ឋាន និងអប់រំវិជ្ជាជីវៈជម្រើស

៨) ហេដ្ឋារចនាសម្ព័ន្ធ និងបរិស្ថានសាលារៀន

- ថ្នាក់រៀន និងបន្ទប់រៀន
- អគារស្នាក់នៅរបស់គ្រូ និងអន្តេវាសិកដ្ឋានសម្រាប់សិស្ស
- បន្ទប់រដ្ឋបាលសាលារៀន
- បន្ទប់អនាម័យ
- បរិស្ថានសាលារៀន

៩) ហិរញ្ញប្បទាន និងការគ្រប់គ្រងហិរញ្ញវត្ថុ

- ថវិកា និងការទទួល

- ការចាត់ចែង និងការប្រើប្រាស់ថវិកាប្រចាំឆ្នាំ
- ការគ្រោងថវិកា និងការចំណាយប្រចាំឆ្នាំ

## ២.៩. ការគ្រប់គ្រងសាលារៀនមានប្រសិទ្ធភាព

### ២.៩.១. កំណែទម្រង់កម្រិតសាលារៀនតាមរយៈគោលការណ៍ ៤A

ក្នុងគោលដៅធ្វើកំណែទម្រង់ការគ្រប់គ្រងសាលារៀន ក្រសួងអប់រំ យុវជន និងកីឡាបានសហការជាមួយធនាគារពិភពលោក ដើម្បីដាក់ឱ្យអនុវត្តគម្រោងការគ្រប់គ្រងសាលារៀនមានប្រសិទ្ធភាព (School-Based Management) នៅតាមអនុវិទ្យាល័យចំនួន១០០ នៅក្នុងទូទាំងព្រះរាជាណាចក្រកម្ពុជា។ ទស្សនាទាននៃ«ការគ្រប់គ្រងសាលារៀន (SBM)» ផ្តោតលើសមាសភាគចំនួន៣គឺ ៖

**(១) ស្វ័យភាព «Autonomy» ការសម្រេចចិត្តនៅមូលដ្ឋានផ្អែកលើភស្តុតាង**

- ស្វ័យភាពក្នុងការធ្វើផែនការ និងការគ្រប់គ្រងសាលារៀន
- ក្របខណ្ឌការងារសាលារៀន និងមានប្រសិទ្ធភាព
- ការអនុវត្តស្វ័យភាពក្នុងការធ្វើផែនការ និងការគ្រប់គ្រងថវិកាសាលារៀន
- ការគ្រោងថវិកា ការរៀបចំ និងការដាក់ស្នើគម្រោងថវិកា
- ការគ្រប់គ្រងបុគ្គលិក

**(២) គណនេយ្យភាព «Accountability» ការទទួលខុសត្រូវចំពោះការអនុវត្តរបស់សាលារៀន និងសិស្ស**

- ប្រភេទគណនេយ្យភាព
- ការវិភាគ ការអនុវត្តការងាររបស់សាលារៀន
- ការគ្រប់គ្រងហិរញ្ញវត្ថុ

**(៣) ការវាយតម្លៃ «Assessment» ការអនុវត្តរបស់សាលារៀន និងលទ្ធផលសិក្សារបស់សិស្ស**

- ការវាយតម្លៃសាលារៀន និងការវាយតម្លៃសិស្ស
- ប្រភេទ និងការវាយតម្លៃសាលារៀន

- ការពិនិត្យឡើងវិញពាក់កណ្តាលឆ្នាំ

- ការប្រើប្រាស់លទ្ធផលវាយតម្លៃ ដើម្បីកែលម្អសាលារៀន

- ការវាយតម្លៃដំណើរការអនុវត្តនៅដំណាច់ឆ្នាំ

- ការអភិវឌ្ឍវិជ្ជាជីវៈ៖ ការបំប៉ននៅនឹងកន្លែង

- ការវាយតម្លៃលទ្ធផលសិក្សារបស់សិស្ស

- ការប្រើលទ្ធផលតេស្តសិក្សា




**( ៤ ) ការចូលរួម «P-Articipation» របស់មាតាបិតា និងសហគមន៍ក្នុងគណៈកម្មការគ្រប់គ្រងសាលារៀន**

- តួនាទីរបស់សហគមន៍ក្នុងការគ្រប់គ្រងសាលារៀន ៖ គឺធ្វើការសម្របសម្រួលធានាដំណើរការដោយរលូននូវការអនុវត្តសកម្មភាពជាតួនាទីរបស់សហគមន៍និងអភិបាលកិច្ចសាលារៀន ព្រមទាំងពិនិត្យឡើងវិញនិងដាក់ស្នើការកែសម្រួលដើម្បីធានានូវតម្លាភាពក្នុងការចូលរួមរបស់សហគមន៍។

- មាតាបិតា និងសិស្សចូលរួមក្នុងគណៈកម្មការគ្រប់គ្រងសាលារៀន

ការបង្កើតគណៈកម្មការគ្រប់គ្រងសាលារៀន និងការចូលរួមរបស់មាតាបិតានិងអាជ្ញាធរមូលដ្ឋានក្នុងការគ្រប់គ្រងសាលារៀន ៖ សមាសភាគមួយដ៏សំខាន់មិនអាចខ្វះបានក្នុងការពង្រឹងការគ្រប់គ្រងសាលារៀនប្រកបដោយប្រសិទ្ធភាព គឺការបង្កើតគណៈកម្មការគ្រប់គ្រងសាលារៀនដោយមានការចូលរួមពីមាតាបិតា និងអាជ្ញាធរមូលដ្ឋាន។ គោលដៅនៃការបង្កើតគណៈកម្មការគ្រប់គ្រងសាលារៀនគឺដើម្បីពិភាក្សារួមគ្នារវាងគណៈគ្រប់គ្រងសាលារៀនជាមួយនឹងមាតាបិតា និងអាជ្ញាធរមូលដ្ឋានក្នុងការជានាឱ្យសាលារៀនបំពេញបេសកកម្មរបស់ខ្លួនប្រកបដោយជោគជ័យ។ ភារកិច្ចដ៏សំខាន់នៃគណៈកម្មការគ្រប់គ្រងសាលារៀន គឺការសិក្សាពីតម្រូវការសាលារៀន និងការដាក់ចេញនូវវិធានការដើម្បីបំពេញតាមតម្រូវការរបស់សាលារៀន។

## ២.១០. ប្រសិទ្ធភាព និងគណនេយ្យភាព

### ២.១០.១. ប្រសិទ្ធភាពសាលារៀន

ទោះបីជាសាលារៀនដែលស្ថិតនៅក្នុងស្រុកតែមួយ មានគ្រូដែលរៀនចប់នៅសាលាគរុកោសល្យតែមួយទទួលនូវធនធានថវិកាដូចគ្នាតែប្រសិទ្ធភាព និងលទ្ធផលសិក្សារបស់សាលារៀនមិនដូចគ្នាទេ (ណារ៉ុន, ២០២០)។ ដូច្នេះហើយទើបគេធ្វើការសិក្សាពីប្រសិទ្ធភាពសាលារៀន។ ក៏ប៉ុន្តែ និយមន័យនៃប្រសិទ្ធភាពសាលារៀនក៏ប្រែប្រួលឥតឈប់ឈរ។ នៅក្នុងទសវត្សរ៍ទី៧០ សាលារៀនផ្តោតជាសំខាន់លើការរីកលូតលាស់ខាងផ្នែកសង្គម និងអារម្មណ៍ និងសមធម៌សម្រាប់សិស្សទាំងអស់។ នៅក្នុងទសវត្សរ៍ទី៨០ សាធារណជន មាតាបិតាចាប់ផ្តើមទាមទារប្រសិទ្ធភាពលទ្ធផលសិក្សារបស់សិស្ស និងបំណិនការងារ (Cuban, 1990)។ នៅក្នុងទសវត្សរ៍ទី៩០ និងទសវត្សរ៍ឆ្នាំ ២០០០ មាតាបិតាផ្តោតជាសំខាន់លើលទ្ធផលសិក្សារបស់សិស្ស និងការទទួលខុសត្រូវរបស់សាលារៀន។ ម៉្យាងវិញទៀត តួអង្គផ្សេងៗដូចជាមាតាបិតា គណៈគ្រប់គ្រង សិស្ស គ្រូ គណៈកម្មការគ្រប់គ្រងសាលា ធុរជន អ្នករៀបចំគោលនយោបាយ អ្នកសារព័ត៌មាន និងអ្នកបង់ពន្ធផ្តោតការយក ចិត្តទុកដាក់លើធនធានជាធាតុចូល និងសូចនាករប្រសិទ្ធភាព ដូចជា ហេដ្ឋារចនាសម្ព័ន្ធធនធានហិរញ្ញវត្ថុនិងការបំពេញការងាររបស់បុគ្គលិក។

ផ្ទុយទៅវិញ គ្រូសង្កត់ធ្ងន់លើដំណើរការរៀននិងបង្រៀនដោយគេយល់ថា ប្រសិទ្ធភាព គឺជាគុណភាពការប្រើប្រាស់វិធីសាស្ត្របង្រៀនសមស្របបរិស្ថាននិងបរិយាកាសក្នុងថ្នាក់រៀន និងទំនាក់ទំនងជាមួយសិស្សជាដើម។ សិស្ស និងអ្នកនយោបាយយល់ឃើញថា ប្រសិទ្ធភាព គឺជាលទ្ធផលសិក្សា និងការចំណាយថវិកាសម្រាប់សិស្សម្នាក់ៗ។

### ២.១០.២. សូចនាករប្រសិទ្ធភាព

សូចនាករប្រសិទ្ធភាពមានច្រើនប្រភេទទៅតាមដំណាក់កាលនៃដំណើរការសិក្សាៈ (១) ធាតុចូល (ធនធានមនុស្ស និងហិរញ្ញវត្ថុ) (២) ការកែច្នៃ (ដំណាក់កាលផ្ទៃក្នុង និងរចនាសម្ព័ន្ធ និង (៣) ធាតុចេញ (សមិទ្ធផលការងារ)។

**(១) ធាតុចូល (Input) ៖** ធាតុចូលសម្រាប់សាលារៀនរួមមាន ធនធានមនុស្ស ធនធានហិរញ្ញវត្ថុ និងបរិស្ថាន ដែលមានឥទ្ធិពលលើប្រសិទ្ធភាពរបស់អង្គភាព។ ធាតុចូលដែលជាធនធានហិរញ្ញវត្ថុសម្រាប់សាលារៀនដែលគេត្រូវយកលុយទៅទិញ គឺគុណវុឌ្ឍិរបស់គ្រូ និងគណៈគ្រប់គ្រង សៀវភៅបណ្ណាល័យ បច្ចេកវិទ្យា និងហេដ្ឋារចនាសម្ព័ន្ធ។ ធាតុចូលមិនមែនហិរញ្ញវត្ថុ គឺគោលនយោបាយអប់រំ ស្តង់ដារ រចនាសម្ព័ន្ធ នយោបាយ ការគាំទ្រពីមាតាបិតា និងសមត្ថភាពរបស់សិស្ស (Cohen, Raudenbush, and Ball, 2003)។ ធាតុចូលដាក់សម្ពាធទៅលើសមត្ថភាពកែច្នៃរបស់សាលារៀន និងសមិទ្ធផលការងាររបស់សាលារៀន។

**(២) ការកែច្នៃ (Transformation) ៖** ការកែច្នៃ គឺជាបរិមាណគុណភាព និងសង្គតិភាពនៃដំណើរការផ្ទៃក្នុង និងរចនាសម្ព័ន្ធដែលកែច្នៃធាតុចូលឱ្យទៅជាធាតុចេញដូចជារចនាសម្ព័ន្ធនៃកម្មវិធីសិក្សា សុខភាពទំនាក់ទំនងបុគ្គល ការខិតខំប្រឹងប្រែងរៀនសូត្ររបស់សិស្ស និងការប្តេជ្ញាចិត្តក្នុងការបង្រៀនរបស់គ្រូ ការដឹកនាំរបស់នាយកសាលា គុណភាពនិង ចំនួនម៉ោងសិក្សា ការធានាគុណភាពតាមរយៈការធ្វើតេស្តវាយតម្លៃការរៀននិងបង្រៀន ការប្រើប្រាស់បច្ចេកវិទ្យា និងវាយតម្លៃលទ្ធផលការងាររបស់បុគ្គលិកអប់រំ (Hoy, W., & Miskel, C., 2008)។ ក្នុងន័យនេះ ការកែច្នៃត្រូវតែដំណើរការយ៉ាង

សុខដុម តាមរយៈការបង្កើនប្រសិទ្ធភាពសាលារៀន ការរៀននិងបង្រៀន ការគ្រប់គ្រង ការកែលម្អវប្បធម៌សាលារៀនការដាក់ចេញនូវគោលដៅច្បាស់លាស់ និងការបំពេញតម្រូវការរបស់បុគ្គល និង តួអង្គពាក់ព័ន្ធក្នុងគោលដៅទទួលបាននូវសមិទ្ធផលដែលបានដាក់ចេញ។

តាមរយៈគំរូអភិបាលកិច្ចថ្មីរបស់សាលារៀនជំនាន់ថ្មី គឺការច្នៃប្រឌិតថ្មីមានដូចជា ៖ (i)ការពង្រីកកម្មវិធីសិក្សា (ii)ចំនួនម៉ោងសិក្សា (iii)ការធ្វើតេស្តវង្វាយតម្លៃការរៀន និងបង្រៀន (iv)ការប្រើប្រាស់បច្ចេកវិទ្យា និង(v)វង្វាយតម្លៃលទ្ធផលការងាររបស់បុគ្គលិកអប់រំ (vi)សេវាបណ្ណាល័យសតវត្សទី២១។

(i) ការពង្រីកកម្មវិធីសិក្សា ៖ សាលារៀនជំនាន់ថ្មីមានការពង្រីកកម្មវិធីសិក្សាមួយចំនួនដូចជា៖ កម្មវិធីសិក្សាបំណិនជីវិត (ការចញ្ចឹមសត្វ វិជ្ជាមេផ្ទះផ្សេងៗ) កម្មវិធីកុំព្យូទ័រ (ការសរសេរកូដកម្មវិធី, 3D Printing, Robotic Coding) (របាយការណ៍គ្រូប្រឹក្សាអាជីព, ២០២២)។

(ii) ចំនួនម៉ោងសិក្សា៖ សាលារៀនជំនាន់ថ្មីបានច្នៃប្រឌិតម៉ោងសិក្សាខុសពីសាលារដ្ឋធម្មតា (ទម្រង់ពាក្យសុំចូលរៀនសាលារៀនជំនាន់ថ្មី, ២០១៩)។ យោងតាមកាលវិភាគគ្រូបង្រៀនឆ្នាំ២០១៩ បានបង្ហាញថា សិស្សណាដែលចូលចិត្តរៀនមុខវិជ្ជាណាមួយទាំងបីនេះដូចជា រូបវិទ្យា (Physics),គីមីវិទ្យា (Chemistry) និងជីវវិទ្យា (Biology) ជាងគេត្រូវបន្ថែម ១ម៉ោងដោយស្វ័យប្រវត្តិលើសពីមុខវិជ្ជាផ្សេងទៀតដោយគិតតាមនិយាមម៉ោងសិក្សា។ ការច្នៃប្រឌិតបែបនេះគឺធ្វើឡើងក្នុងគោលបំណងតម្រង់ទិសការសិក្សារបស់ឱ្យត្រូវនឹងជំនាញដែលពួកគេចង់រៀន និងចង់ក្លាយជាអ្វីមួយនាថ្ងៃអនាគត (កំណត់ហេតុគ្រូប្រឹក្សាអាជីព, ២០១៩)។

(iii) ការធ្វើតេស្តវង្វាយតម្លៃការរៀន និងបង្រៀន៖ ជារៀងរាល់ខែនីមួយៗការិយាល័យសិក្សាតែងតែប្រកាសអំពីកាលបរិច្ឆេទស្តីពីការប្រឡងប្រចាំខែទៅកាន់លោកគ្រូអ្នកគ្រូ និងសិស្សានុសិស្ស (សេចក្តីជូនដំណឹង, ២០២០)។ ភារកិច្ចរបស់គ្រូត្រូវប្រគល់សំណួរកិច្ចការប្រឡងមកការិយាល័យតាមកាលកំណត់ ។ ចំណែកសិស្សត្រូវមើលឈ្មោះ បន្ទប់ លេខតុ

ដែលការិយាល័យសិក្សាបានប្រកាស និងបិទផ្សាយ។ ឈ្មោះសិស្សការិយាល័យសិក្សាធ្វើការផ្តុំចូលគ្នាចាប់ពីថ្នាក់ទី៧ ដល់ថ្នាក់ទី១២ រួចធ្វើការ Short ចូលគ្នាតាមអក្ខរក្រម ដោយបំបែកទៅតាមបន្ទប់ ដោយមានចំនួន ២៥នាក់/បន្ទប់ (បញ្ជីឈ្មោះសិស្សប្រឡង, ២០២០)។ ការរៀបចំការប្រឡងបែបនេះដើម្បីឱ្យការធ្វើតេស្តវាយតម្លៃការរៀន និងបង្រៀនមានតម្លាភាព និងគណនេយ្យភាព។ ក្រោយពីចេញលទ្ធផលនៃការប្រឡងនេះសាលានិងមានការប្រជុំបង្ហាញមួយស្តីពីក្រាបសរសរនៃលទ្ធផលតេស្តនោះ (ក្រាបសរសរលទ្ធផលសិក្សាសិស្ស, ២០២០)។

(iv) ការប្រើប្រាស់បច្ចេកវិទ្យា ៖ លោកគ្រូអ្នកគ្រូទាំងអស់នៅសាលារៀនជំនាន់ថ្មីដាច់ខាតត្រូវតែមានកុំព្យូទ័រម្នាក់មួយគ្រឿងដើម្បីប្រើប្រាស់ ។ លោកគ្រូអ្នកគ្រូដែលបានឆ្លងកាត់ដំណាក់កាលសម្ភាសន៍ជាប់ចូលបម្រើការងារនៅសាលារៀនជំនាន់ថ្មីមានឱកាសទទួលបានកុំព្យូទ័រយួរដៃចំនួនមួយគ្រឿងពីសាលាដើម្បីប្រើប្រាស់ក្នុងការងារប្រចាំថ្ងៃ (សេចក្តីជូនដំណឹងពីការជ្រើសរើសគ្រូបង្រៀន, ២០២៣)។ ត្រង់ចំណុចនេះសបញ្ជាក់ឱ្យឃើញថាសាលារៀនជំនាន់ថ្មីមានការប្រើប្រាស់បច្ចេកវិទ្យាខ្ពស់ដើម្បីបម្រើដល់ការបង្រៀន និងរៀន។

(v) វាយតម្លៃលទ្ធផលការងាររបស់បុគ្គលិកអប់រំ៖ ជារៀងរាល់ឆ្នាំឆមាសទី២ នៃឆ្នាំសិក្សានីមួយៗសាលាតែងតែធ្វើការវាយតម្លៃលទ្ធផលការងាររបស់ បុគ្គលិកការិយាល័យ គ្រូបង្រៀនជាដើម។

(vi) សេវាបណ្ណាល័យសតវត្សទី២១ ៖ ទាំងសិស្ស និងមិនមែនសិស្សសាលារៀនជំនាន់ថ្មីមានសិទ្ធិចូលអានសៀវភៅ និងស្រាវជ្រាវនៅបណ្ណាល័យសតវត្សទី២១របស់សាលារៀនជំនាន់ថ្មីបាន (អមរា, ២០២៣) ។ បន្ថែមពីនេះទៀតអ្នកគ្រូបណ្ណារក្សបានលើកឡើងថានៅក្នុងបណ្ណាល័យសតវត្សទី២១នេះមានសៀវភៅរាប់រយក្បាលមានច្រើនភាសា ។ ក្នុងបណ្ណាល័យនេះមានដូចជា កុំព្យូទ័រ Mac ចំនួន៤គ្រឿងសម្រាប់ស្រាវជ្រាវ សៀវភៅរឿង សៀវភៅ

ប្រឡោមលោក សៀវភៅជំនួញ សៀវភៅភាពជាអ្នកដឹកនាំ សៀវភៅប្រវត្តិសាស្ត្រ និងសៀវភៅជាច្រើនមុខទៀត ។ បណ្ណាល័យមានទីកន្លែងសម្រាប់អង្គុយអាន និងស្រាវជ្រាវប្រកបដោយផាសុកភាព និងភាពស្ងប់ស្ងាត់។

**(៣) ធាតុចេញ (Performance outcomes)៖** សូចនាករសំខាន់របស់សាលារៀន គឺជាស្តង់ដារដែលជួយវាយតម្លៃគុណភាព និងបរិមាណ នៃសមិទ្ធផលការងាររបស់សាលារៀន ដូចជាបរិមាណនៃសេវាកម្ម និងផលិតផលរបស់សាលារៀនសម្រាប់សិស្ស គ្រូ និងភាគីពាក់ព័ន្ធផ្សេងទៀត។ ក្នុងន័យនេះ ធាតុចេញសំខាន់របស់សាលារៀនមានដូចតទៅ (១) សម្រាប់សិស្ស៖ លទ្ធផលសិក្សារបស់សិស្ស ភាពច្នៃប្រឌិត ការជឿជាក់លើខ្លួនឯង បំណងប្រាថ្នា ការពេញចិត្តនឹងការងារ ការផ្លាស់ប្តូរការងារ (២) សម្រាប់គណៈគ្រប់គ្រង ការពេញចិត្តនឹងការងារ ថវិកាមានតុល្យភាពរវាង ចំណូលនិងចំណាយ ការប្តេជ្ញាចិត្តបម្រើការងារនៅសាលា និង (៣)សម្រាប់សង្គមនិងមាតាបិតា៖ ប្រសិទ្ធភាពរបស់សាលារៀន ។ ក៏ប៉ុន្តែតាមការពិតប្រសិទ្ធភាពសាលារៀនមិនមែនមានត្រឹមតែលទ្ធផលសិក្សារបស់សិស្សនោះទេ។ ជារឿយៗអ្នករៀបចំគោលនយោបាយតែងតែវិភាគពីទំនាក់ទំនងរវាងធាតុចូល និងធាតុចេញ ក្នុងការវិភាគពីប្រសិទ្ធភាពសាលារៀន ពោលគឺគេពិនិត្យមើលការប្រែក្លាយធនធានអប់រំ ធាតុចូល ក្នុងគោលដៅសម្រេចបាននូវធាតុចេញ (Rice, 2002)។

## ២.១១. ការពង្រឹងគណនេយ្យភាពរបស់សាលារៀន

ការពង្រឹងគណនេយ្យភាពរបស់សាលារៀនគឺជាមធ្យោបាយប្រកបដោយប្រសិទ្ធភាព ដើម្បីកែលម្អលទ្ធផលសិក្សារបស់សិស្ស ៖ (១) សាលារៀនត្រូវមានគណនេយ្យភាពចំពោះសមិទ្ធផលការងារខ្ពស់ (២) សាលារៀនត្រូវទទួលបាននូវជំនួយដើម្បីពង្រឹងសមត្ថភាពក្នុងការផ្តល់សេវាអប់រំល្អប្រសើរ និង (៣) សាលាត្រូវបង្កើនគុណភាព និងបរិមាណនៃប្រសិទ្ធផលការងារជាពិសេសលទ្ធផលសិក្សារបស់សិស្ស សាលារៀន ត្រូវមានគណនេយ្យភាពតាមរយៈការចូលរួមរបស់សហគមន៍ និង មាតាបិតានៅក្នុងគណៈគ្រប់គ្រងសាលារៀន (Carnoy and Loeb, 2002)។ Elmore (2002) ចាត់ទុកគណនេយ្យភាព

ជាជំនឿជឿជាក់ជាមូលដ្ឋានរបស់សង្គមថា សាលារៀនត្រូវចូលរួមចំណែកក្នុងការពង្រឹងលទ្ធផលសិក្សារបស់សិស្ស តាមរយៈការកែលម្អដំណើរការកែច្នៃផ្ទៃក្នុងរបស់ខ្លួន។ គណនេយ្យភាព គឺជាប្រព័ន្ធដែលធ្វើឱ្យសិស្ស សាលារៀន និងការិយាល័យអប់រំទទួលខុសត្រូវចំពោះលទ្ធផលសិក្សារបស់សិស្ស។ គណនេយ្យភាពចែកចេញជាបីគឺ ៖ ស្តង់ដារ តេស្ត និង វិធានការឆ្លើយតប។

**១.ស្តង់ដារ ៖** គឺជាអ្វីដែលសិស្សត្រូវចេះ និងចេះធ្វើហើយដែលត្រូវប្រើសម្រាប់វាយតម្លៃលទ្ធផលសិក្សារបស់សិស្ស។ ស្តង់ដារពិពណ៌នាពី ចំណេះដឹង បំណិន អ្វីដែលសិស្សត្រូវរៀន និងសមត្ថភាពរបស់សិស្ស។ ស្តង់ដារត្រូវបញ្ជាក់ពីខ្លឹមសារមេរៀន យុទ្ធសាស្ត្ររៀន និងបង្រៀន និងវង្វាយតម្លៃប្រៀបធៀបនឹងគោលដៅ។ ប៉ុន្តែការបង្កើតស្តង់ដារមានបញ្ហាមួយចំនួនដោយសារតែគ្រូមិនទាន់ច្បាស់ពីការអនុវត្តនៅឡើយ។

**២.វង្វាយតម្លៃ៖** ធម្មតាគ្រូប្រើប្រាស់វង្វាយតម្លៃដើម្បីបែងចែកសិស្សតាមកម្រិតចំណេះដឹង ពិនិត្យមើលបញ្ហារៀនសូត និងវាយតម្លៃជារួមពីភាពជោគជ័យរបស់សាលារៀន (Carnoy and Loeb, 2002)។ ក៏ប៉ុន្តែគេនៅមិនទាន់អាចបង្កើតទំនាក់ទំនងរវាងគណនេយ្យភាព និងតេស្តបានឡើយ។ ក្នុងន័យនេះ នៅក្នុងក្របខណ្ឌនៃចលនាគណនេយ្យភាពបែបថ្មី គោលដៅសំខាន់នៃការធ្វើតេស្ត គឺដើម្បីត្រួតពិនិត្យនិន្នាការកែលម្អ និងពិនិត្យមើលថាតើអន្តរាគមន៍ដូចជាការប្រើប្រាស់ស្តង់ដារថ្មី កម្មវិធីសិក្សា និងកម្មវិធីអភិវឌ្ឍវិជ្ជាជីវៈមានឥទ្ធិពលកម្រិតណាទៅលើលទ្ធផលសិក្សារបស់សិស្ស (Barton, 2001)។

**៣.វិធានការឆ្លើយតប ៖** ការអនុវត្តស្តង់ដារ និងវង្វាយតម្លៃអាចមានបច្ច័យវិជ្ជមានលើលទ្ធផលសិក្សារបស់សិស្ស ដោយគ្រូបង្រៀនសិស្សដើម្បីតែធ្វើតេស្តដោយផ្តោតលើតែលំហាត់សម្រាប់ធ្វើតេស្តមិនបានបង្រៀនតាមកម្មវិធីសិក្សាឱ្យបានពេញលេញបង្រៀនធ្វើយ៉ាងណាឱ្យសិស្សចេះបំណិនកម្រិតទាបដោយផ្តោតលើការទន្ទេញចាំមាត់។ ដើម្បីដោះស្រាយបញ្ហានេះ Smith (2006) បានដាក់ចេញនូវចលនាស្តង់ដារទី២ ដោយពង្រីកគោលដៅសាលារៀនដោយធានានូវសមធម៌ បង្កើនថវិកាសាលារៀន ធ្វើការកែ

លម្អជាប្រចាំគាំទ្រការធ្វើពិសោធនៅក្នុងគ្រឹះស្ថានសិក្សាសាធារណៈការពង្រឹងអភិបាលកិច្ច និងការប្រើប្រាស់បច្ចេកវិទ្យាជាដើម។

## ២.១២. ការពង្រឹងប្រសិទ្ធភាព និងគណនេយ្យភាព

ក្នុងគោលដៅជួយដល់សាលារៀនក្នុងការពង្រឹងប្រសិទ្ធភាព និង គណនេយ្យភាព គេត្រូវចាត់វិធានការសំខាន់ៗពីយ៉ាងគឺ (១) ការអភិវឌ្ឍ វិជ្ជាជីវៈ ៖ ការអភិវឌ្ឍវិជ្ជាជីវៈជួយគ្រូក្នុងការបង្កើនចំណេះដឹង កែលម្អវិធីសាស្ត្របង្រៀន ជួយគ្រូឱ្យចេះគ្រប់គ្រងថ្នាក់រៀន និងទទួលបាននូវអនុសាសន៍ល្អៗក្នុងការបង្រៀន និង (២) កំណែទម្រង់គ្រប់ជ្រុងជ្រោយ (Murphy and Datnow, 2003) (i) ការកែលម្អសាលារៀន ដូចជា ការរៀននិងការបង្រៀន ការអភិវឌ្ឍវិជ្ជាជីវៈ និងវប្បធម៌ជាប្រព័ន្ធ (ii) ការជួយសិស្សឱ្យរៀនមុខវិជ្ជាចាំបាច់ និងសម្រេចបានតាមស្តង់ដារ (iii) រៀបចំផែនការរួមដើម្បីកែលម្អដោយផ្តោតលើលទ្ធផលសិក្សា (iv) រៀបចំកិច្ចសហការរយៈពេលវែងរវាងគ្រូ និងមាតាបិតា និង (v) ពង្រឹងទំនាក់ទំនងរវាងធាតុចូល ការកែច្នៃ និងធាតុចេញ។

## ២.១៣. ការគ្រប់គ្រងរដ្ឋបាលសាលារៀន

រចនាសម្ព័ន្ធនៅក្នុងសាលារៀនកំណត់មុខងារនាយក គណៈគ្រប់គ្រង ក្រុមបច្ចេកទេស គ្រូបង្រៀន បេសកកម្ម និងគោលដៅរបស់សាលារៀន និងការបែងចែកការងាររបស់បុគ្គលិក។ សាលារៀនត្រូវបានបង្កើតឡើងដោយឈរលើមូលដ្ឋានអង្គការផ្លូវការ និងមានការិយាធិបតេយ្យដែលមានលក្ខណៈវិនិច្ឆ័យចាត់តាំងចំនួន៥យ៉ាងដូចដែល Weber បានផ្តល់និយមន័យគឺ ៖ ការបែងចែកការងារ ការតម្រង់ទិសដោយមិនផ្តោតលើបុគ្គល ការកំណត់អំណាចតាមជាន់ថ្នាក់ វិធាននិងលិខិតបទដ្ឋាន និងការតម្រង់ទិសវិជ្ជាជីវៈ។ ដូច្នេះ សាលារៀនមានលក្ខណៈដូចគ្នា និងប្រើប្រាស់យុទ្ធសាស្ត្រដូចនៅក្នុងកងទ័ព ឧស្សាហ-កម្ម និង អង្គភាពរដ្ឋដែរ (Max Abbott, 1965, p.45)។

ក្នុងន័យនេះ គេអាចប្រើម៉ូដែលការិយាធិបតេយ្យ ដើម្បីវិភាគពីបញ្ហាដែលគេជួបប្រទះនៅក្នុងសាលារៀនផងដែរ។ ក៏ប៉ុន្តែសាលារៀនខុសពីអង្គភាពការិយាធិបតេយ្យផ្សេងទៀតត្រង់ថា គ្រូបង្រៀន

ដែលធ្វើការនៅក្រោមនាយកសាលាមានសមត្ថភាព និងចំណេះដឹងបច្ចេកទេសច្រើនជាងនាយកដែលជាមេរបស់ខ្លួន។ ប្រការនេះសាលារៀនខុសពីអង្គការការិយាធិបតេយ្យផ្សេងទៀតដែលអ្នកធំត្រូវតែមានចំណេះដឹងច្រើនជាងនិងមានសមត្ថភាពខ្ពស់ជាងអ្នកតូច។ ដោយសារមូលហេតុនេះហើយទើបបានជានៅក្នុងសាលារៀនគេតែងតែឃើញទំនាស់កើតឡើងរវាងនាយកសាលា និងគ្រូបង្រៀន (Hoy, W., & Miskel, C., 2008)។

គេអាចបែងចែករចនាសម្ព័ន្ធក្នុងសាលារៀនជាបួនប្រភេទ (Hoyand Miskel, 2008) ៖ (១) ប្រភេទ Weber ដែលមានកម្រិតវិជ្ជាជីវៈ និងមានកម្រិតការិយាធិបតេយ្យខ្ពស់ហើយបំពេញឱ្យគ្នាទៅវិញទៅមក (២)ប្រភេទផ្ដាច់ការនិយមដែលមានកម្រិតវិជ្ជាជីវៈទាប និងមានកម្រិតការិយាធិបតេយ្យខ្ពស់ ៖ អំណាចស្ថិតនៅក្នុងកណ្ដាប់ដៃរបស់អ្នកដែលកាន់តំណែងខ្ពស់សាលារៀនដំណើរការតាមការគោរពវិន័យច្បាប់និងលិខិតបទដ្ឋាននិងសេចក្ដីណែនាំ នាយកជាអ្នកសម្រេចចុងក្រោយ និងផ្ដោតលើការដាក់ទោសទណ្ឌពេលមានកំហុស (៣) ប្រភេទវិជ្ជាជីវៈ ដែលមានកម្រិតវិជ្ជាជីវៈខ្ពស់ និងមានកម្រិតការិយាធិប-តេយ្យទាប ៖ ការសម្រេចចិត្តត្រូវបានផ្ទេរសិទ្ធិទៅឱ្យមន្ត្រីជំនាញ ដែលមានបទពិសោធ និងសមត្ថភាពក្នុងការធ្វើសេចក្ដីសម្រេចចិត្ត គ្រូមានអំណាចនៅក្នុងការសម្រេចចិត្តក្នុងអង្គភាពនិង (៤) ប្រភេទគ្មានសណ្ដាប់ធ្នាប់ ដែលមានកម្រិតវិជ្ជាជីវៈ និងមានកម្រិតការិយាធិបតេយ្យខ្ពស់ ៖ ជារចនាសម្ព័ន្ធដែលគ្មានប្រសិទ្ធភាពមានទំនាស់និងវិវាទជាប្រចាំ។

ដូច្នេះ សាលារៀនត្រូវរៀបចំរចនាសម្ព័ន្ធរដ្ឋបាលដែលតម្រូវឱ្យមានការចូលរួមពីភាគីពាក់ព័ន្ធ ជួយសម្រួលដល់សាលារៀន (Enabling school structure) ក្នុងការអនុវត្តបេសកកម្មរបស់ខ្លួនដោយគោរពតាមច្បាប់ និងលិខិតបទដ្ឋានដែលគាំទ្រដល់ការសម្រេចនូវចក្ខុវិស័យនៃការអប់រំ។ គេត្រូវរៀបចំរចនាសម្ព័ន្ធដែលលើកទឹកចិត្តឱ្យនាយក និងគ្រូសហការគ្នា ព្រមទាំងបំពេញការងារដោយមានការទទួលខុសត្រូវតាមភារកិច្ចរៀងៗខ្លួន។ គេត្រូវអនុវត្តច្បាប់ និងលិខិតបទដ្ឋានប្រកបដោយភាពទន់ភ្លន់ក្នុងគោលដៅដោះស្រាយបញ្ហា និងកែលម្អលទ្ធផលសិក្សារបស់សិស្ស។

Charles Bidwell (1965) បានកត់សម្គាល់ថាដើម្បីឱ្យសាលារៀនផ្តោតលើលទ្ធផលសិក្សារបស់សិស្ស និងដោះស្រាយបញ្ហាដ៏សម្បូណ៌បែបរបស់សិស្ស គ្រូត្រូវមានសេរីភាពក្នុងការធ្វើការវិនិច្ឆ័យវិជ្ជាជីវៈ។ ដូច្នេះ សាលារៀនត្រូវផ្តល់ឱ្យគ្រូនូវស្វ័យភាពវិជ្ជាជីវៈ។ គ្រូធ្វើការតែឯកឯងនៅក្នុងថ្នាក់រៀនដោយមិនមានការត្រួតពិនិត្យខ្លាំងក្លាពីគ្រូផ្សេងទៀត ឬពីថ្នាក់លើប៉ុន្មានឡើយហើយអាចសម្រេចចិត្តដោយខ្លួនឯងពាក់ព័ន្ធនឹងសិស្សរបស់ខ្លួន។ ប្រការនេះមានន័យថា សាលារៀនមានរចនាសម្ព័ន្ធដែលធូររលុង។ នៅក្នុងកម្រងសាលារៀន ឬនៅក្នុងស្រុកនីមួយៗទំនាក់ទំនងរវាងនាយកសាលារៀន និងប្រធានការិយាល័យអប់រំស្រុកក៏មានលក្ខណៈធូររលុងដែរ។ ដូច្នេះ ទាំងនាយកសាលាទាំងគ្រូមានស្វ័យភាព និងធ្វើការនៅក្នុងរចនាសម្ព័ន្ធរដ្ឋបាលមួយដែលធូររលុង ហើយពួកគេមានសិទ្ធិខ្លាំងក្នុងការសម្រេចចិត្តក្នុងការអនុវត្តភារកិច្ចរបស់ខ្លួន ដូចជាការអនុវត្តកម្មវិធីសិក្សា ការប្រើវិធីសាស្ត្របង្រៀនជាដើម។

ផ្ទុយទៅវិញ ក្នុងការកំណត់លទ្ធផលសិក្សារបស់សិស្ស គេទាមទារនូវលទ្ធផលដែលដូចគ្នានិងការកែលម្អលទ្ធផលសិក្សារបស់សិស្ស និងលទ្ធផលការងាររបស់សាលារៀនឱ្យបានដូចៗគ្នា។ ក្នុងន័យនេះ Charles Bidwell (1965) បានសន្និដ្ឋានថា សាលារៀនមានរចនាសម្ព័ន្ធដែលមានសមាសភាពពីរគឺៈ ការិយាល័យធិបតេយ្យ និងរចនាសម្ព័ន្ធធូររលុង។

Hoy និង Miskel (2008) ធ្វើសេចក្តីសន្និដ្ឋានថា សាលារៀនមានរចនាសម្ព័ន្ធចាត់តាំង ដែលមានលក្ខណៈពីរយ៉ាងៈ (១) រចនាសម្ព័ន្ធការិយាធិបតេយ្យ ដែលមានតួនាទីស្ថាប័ន និងគ្រប់គ្រងតឹងរ៉ឹង ដឹកនាំដោយនាយកសាលារៀន ដែលត្រូវសម្របសម្រួលរវាងសាលារៀនជាមួយសហគមន៍ អនុវត្តច្បាប់ និងលិខិតបទដ្ឋាន គ្រប់គ្រងការងារផ្ទៃក្នុងសាលារៀន បែងចែកធនធានគ្រប់ប្រភេទ ពិនិត្យមើលទំនាក់ទំនងរវាងគ្រូ និង សិស្ស និង (២) រចនាសម្ព័ន្ធវិជ្ជាជីវៈ ដែលគ្របដណ្តប់ការងារបច្ចេកទេស ការរៀននិងបង្រៀន។ នៅក្នុងរចនាសម្ព័ន្ធវិជ្ជាជីវៈ គ្រូមានស្វ័យភាពវិជ្ជាជីវៈ ធូររលុងជាងរចនាសម្ព័ន្ធការិយាធិបតេយ្យ ដោយគ្រូអាចធ្វើការសម្រេចចិត្តដោយខ្លួនឯងក្នុងការរៀននិងបង្រៀន។ ក្នុងន័យនេះ នាយកសាលា និង

គ្រូបង្រៀនត្រូវមានចំណេះដឹងវិជ្ជាជីវៈរបស់ខ្លួនច្បាស់លាស់។ ក៏ប៉ុន្តែគេឃើញមានវិវាទរវាងមុខងារការិយាធិប្បតេយ្យ និងវិជ្ជាជីវៈ ពោលគឺ រវាងនាយកសាលា និងគ្រូបង្រៀន។

## ២.១៤. ធាតុសំខាន់ៗនៃអភិបាលកិច្ចសាលារៀន

### ២.១៤.១. តម្លាភាព

តម្លាភាពសំដៅលើរាល់វិធាន នីតិវិធី សេចក្តីសម្រេច និងព័ត៌មានពាក់ព័ន្ធទាំងឡាយត្រូវបានបើកចំហជាសាធារណៈ (ក្រសួងអ.យ.ក, ២០១៦ខ)។ម្យ៉ាងទៀតតម្លាភាពកើតឡើងនៅពេលដែលសកម្មភាពទាំងអស់ និងសេចក្តីសម្រេចនោះត្រូវបានធ្វើឡើងយ៉ាងសមស្របដោយបើកចំហមានលក្ខណៈទូលំទូលាយ និងងាយយល់ដល់ប្រជាពលរដ្ឋ។ តម្លាភាពសំដៅដល់ព័ត៌មានស្តីពីការធ្វើសេចក្តីសម្រេចគោលនយោបាយ និងផែនការយុទ្ធសាស្ត្របេសកកម្មជាសកម្មភាពសាធារណៈ និងការអនុវត្តណាមួយត្រូវប្រជាពលរដ្ឋមានលទ្ធភាពទទួលយកបានទាន់ពេលវេលានៅតាមបណ្តាប្រទេសដែលមានអភិបាលកិច្ចល្អប្រជាពលរដ្ឋមានលទ្ធភាពទទួលបានយ៉ាងងាយស្រួលនៅឯកសារស្តីពីវិធានច្បាប់បទបញ្ញត្តិ និងនីតិវិធីអត្រាថ្លៃឈ្នួលសម្រាប់សេវាសាធារណៈ សារពើភ័ណ្ឌទ្រព្យសម្បត្តិសាធារណៈ វិធានបែបបទសម្រាប់លទ្ធកម្មសាធារណៈ ព័ត៌មានស្ថិតិស្តីពីសេដ្ឋកិច្ចនិងសង្គមដែលប្រមូលចងក្រងដោយផ្នែកសាធារណៈនិងព័ត៌មានហិរញ្ញវត្ថុដែលមានសេចក្តីលម្អិតអំពីមុខចំណូល ចំណាយសាធារណៈទាំងឡាយ។ ដូចនេះព័ត៌មានសាធារណៈជាកត្តាដ៏សំខាន់មួយសម្រាប់ឱ្យមានការចូលរួមពីមតិសាធារណៈជនលើការពិនិត្យតាមដានក្នុងការធ្វើសេចក្តីសម្រេចប្រកបដោយតម្លាភាព។ កាលណាមានតម្លាភាពកាន់តែខ្ពស់កម្រិតអភិបាលកិច្ចក៏មានលក្ខណៈកាន់តែប្រសើរដែរ។

វិធីសាស្ត្រមួយចំនួននៃការអនុវត្តការងារប្រកបដោយតម្លាភាព

- ព័ត៌មានត្រូវមានលក្ខណៈបើកចំហនិងងាយស្រួលយល់
- បិទប្រកាសឬបិទផ្សាយ
- កំណត់បញ្ហាទីកន្លែងនិងពេលវេលាឱ្យកាន់តែមានភាពច្បាស់លាស់ជាមុន

- រៀបចំឱ្យមានយន្តការក្រុមការងារគណៈកម្មការពិនិត្យតាមដានវាយតម្លៃជាប្រចាំដោយឯករាជ្យ។

តាមការស្រាវជ្រាវ "តម្លាភាព" មានន័យថាការសម្រេចចិត្តត្រូវបានអនុវត្តឱ្យឆ្លើយទៅនឹងការស្នើសុំក្នុងក្របខណ្ឌច្បាប់ ។ គោលការណ៍តម្លាភាពត្រូវផ្តល់នូវសិទ្ធទទួលបានព័ត៌មានដោយសេរីនិងយុត្តិធម៌ ទទួលបានការចូលរួមសម្រេចចិត្តដោយផ្ទាល់ ឬដោយប្រយោលក្នុងអង្គភាព។ គោលនយោបាយតម្លាភាពក្នុងការគ្រប់គ្រងគឺៈ (១) បង្ហាញពីភាពស្មោះត្រង់ចំពោះអង្គភាពគោលនយោបាយផ្លាស់ប្តូររបស់អង្គភាពសម្រាប់រយៈពេលវែងធ្វើឱ្យគោលនយោបាយនិងលទ្ធផលមានភាពស៊ីចង្វាក់គ្នាសម្រាប់អង្គភាព និងគោលនយោបាយផ្តល់តម្លៃដល់និយោជិត (២) គោរពសិទ្ធនិងស្វ័យភាពរបស់អង្គភាព ផ្តល់សេរីភាពនៃការទទួលព័ត៌មានដល់គ្រប់ភាគីពាក់ព័ន្ធ ផ្តល់ការសម្រេចចិត្តដល់និយោជិតគ្រប់ទីកន្លែងដែលពួកគេនៅមានភាពស៊ីចង្វាក់គ្នារវាងថ្នាក់លើនិងថ្នាក់ក្រោម (Arulrajah, 2016) ។

ដោយឡែក បញ្ញត្តិតម្លាភាពទាំងប្រទេសកំពុងអភិវឌ្ឍ និងទាំងប្រទេសអភិវឌ្ឍ ចាំបាច់ត្រូវមានៈ (១) ការចូលរួម (២) ធនធាន (៣) ភាពជាអ្នកដឹកនាំ (៤) ការបណ្តុះបណ្តាល (៥) វប្បធម៌ការិយាធិបតេយ្យ និង (៦) រដ្ឋបាលសមត្ថភាព (Eccleston, R., & Stubbs, R., 2016)។ តាមព្រឹត្តិប័ត្រ Popular Financial Reports as Fiscal Transparency Mechanisms របៀបធ្វើឱ្យមានតម្លាភាពក្នុងរបាយការណ៍ហិរញ្ញវត្ថុពន្ធដាដើម្បីបង្កើតអភិបាលកិច្ចល្អគឺៈ (១) ធ្វើបច្ចុប្បន្នភាពព័ត៌មាន (២) កំណត់ស្តង់ដារនិងការពន្យល់ពីលំហូររបាយការណ៍ហិរញ្ញវត្ថុនោះ (៣) របាយការណ៍ហិរញ្ញវត្ថុត្រូវផ្តល់ឱ្យដល់អ្នកអានជាសាធារណៈ (៤) បច្ចុប្បន្នភាពទិន្នន័យនិងប្រៀបធៀប (៥) របាយការណ៍ហិរញ្ញវត្ថុត្រូវតែសាមញ្ញនិងទាក់ទាញ និង (៦) ផ្សព្វផ្សាយឱ្យដល់គោលដៅនៃអ្នកពាក់ព័ន្ធ (Jordan, M. M., Yusuf, J. E., Berman, M., & Gilchrist, C., 2017)។

ឆ្នាំ២០០៤ "តម្លាភាព" ត្រូវបានរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាយកធ្វើជាសូចនាករមួយក្នុងកំណែទម្រង់ប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ។ សូចនាករនេះ (តម្លាភាព) ត្រូវបានកំណត់ក្នុងកំណែទម្រង់ប្រព័ន្ធហិរញ្ញវត្ថុសាធារណៈថាៈ "តម្លាភាព" សំដៅដល់រាល់ច្បាប់ បទបញ្ញត្តិ គោលការណ៍ នីតិវិធី

និងការអនុវត្តទាំងឡាយ ត្រូវផ្សព្វផ្សាយឱ្យទូលាយសម្រាប់ក្រសួង ស្ថាប័ន ឬអង្គភាពសាធារណៈ និងសាធារណជន (ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, ២០១៣)។

### ២.១៤.២. គណនេយ្យភាព

គណនេយ្យភាពសំដៅទៅលើការអនុវត្តតួនាទី និងភារកិច្ចក្នុងដំណើរការនៃការសម្រេចចិត្តហើយទទួលខុសត្រូវចំពោះទង្វើរបស់ខ្លួនដោយរាយការណ៍ព្រមទាំងបញ្ជាក់អំពីមូលហេតុដែលខ្លួនបានសម្រេច និងអនុវត្ត (ក្រសួងអ.យ.ក, ២០១៦b) ។

យោងតាម ក្រសួង អ.យ.ក (២០១៦) ស្តីពីការគ្រប់គ្រង និងភាពជាអ្នកដឹកនាំ "គណនេយ្យភាព" គឺមិនមែនត្រឹមតែការទទួលខុសត្រូវចំពោះមុខនរណាម្នាក់ដែលបានស្នើសុំទេ ប៉ុន្តែជាការទទួលខុសត្រូវនូវរាល់សកម្មភាពដែលបានអនុវត្តចំពោះមុខអ្នកពាក់ព័ន្ធទាំងអស់។ គណនេយ្យភាពមានន័យថាមន្ត្រីរាជការ មន្ត្រីសាធារណៈត្រូវមានការទទួលខុសត្រូវនឹងឆ្លើយតបចំពោះប្រជាពលរដ្ឋនៅរាល់សកម្មភាពរបស់រាជរដ្ឋាភិបាលដែលត្រូវចោទសួរឡើង។ នៅប្រទេសមានអភិបាលកិច្ចល្អមន្ត្រីសាធារណៈមានឆន្ទៈឆ្លើយតបទៅនឹងសំណួរ និងផ្តល់នូវដំណោះស្រាយដ៏សមរម្យចំពោះសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋនៅក្នុងប្រទេស។ គណនេយ្យភាពមានន័យម្យ៉ាងទៀតថា ស្ថាប័នសាធារណៈទាំងឡាយនិងថ្នាក់គ្រប់គ្រងស្ថាប័នត្រូវទទួលខុសត្រូវចំពោះសកម្មភាពក្នុងស្ថាប័ននោះ។ កង្វះខាតអភិបាលកិច្ចល្អមានន័យថាមន្ត្រីសាធារណៈមិនមានលទ្ធភាពទទួលខុសត្រូវ និងឆ្លើយតបចំពោះមុខប្រជាពលរដ្ឋលើសេចក្តីសម្រេចចិត្តដែលមន្ត្រីនោះបានអនុវត្តឡើយ ដោយសារកង្វះផ្នែកច្បាប់ ភាពមិនច្បាស់លាស់របស់មន្ត្រីលើវិធានការច្បាប់ កង្វះយន្តការក្នុងការអនុវត្ត កង្វះការពង្រឹងគណនេយ្យភាពឱ្យមានប្រសិទ្ធភាពដោយសារតែអន្តរាគមន៍ជាលក្ខណៈនយោបាយខុសពីការចែងក្នុងច្បាប់ ប៉ុន្តែកត្តាសំខាន់ជាងគេគឺកង្វះតម្លាភាព កង្វះព័ត៌មានគ្រប់គ្រាន់និងច្បាស់លាស់ដែលអំពីសេចក្តីសម្រេចនោះដោយរក្សានូវព័ត៌មានជាសម្ងាត់ឬក៏ការកែព័ត៌មានការស៊ុំក្រលុំនិងកង្វះខាតក្នុងការចូលរួមប្រកបដោយអត្ថន័យនិងខ្លឹមសារ ។ គណនេយ្យភាពមានពីរប្រភេទគឺ៖ គណនេយ្យភាពផ្ទៃក្នុង និងគណនេយ្យភាពខាងក្រៅ ។

ដោយឡែកតាមការស្រាវជ្រាវ "គណនេយ្យភាព" គឺជាការសម្រេចចិត្តនិងទទួលខុសត្រូវគ្រប់សកម្មភាពអង្គភាពប្រកបដោយតម្លាភាព និងស្របតាមនីតិរដ្ឋ។ គោលនយោបាយគណនេយ្យភាពត្រូវធ្វើឡើងចំពោះភាគីពាក់ព័ន្ធ និយោជិត សហជីព និងសង្គមស៊ីវិល ព្រមទាំងកម្លាំងពលកម្មផងដែរ។ សីលធម៌ សុវត្ថិភាព សុខភាព និងសុខមាលភាពរបស់ពួកគេត្រូវបានការពារមុខច្បាប់ និងស្របតាមនីតិរដ្ឋ (Arulrajah, 2016)។ "គណនេយ្យភាព" គឺជាគោលនយោបាយគន្លឹះរបស់រាជរដ្ឋាភិបាលប្រជាធិបតេយ្យ និងជាស្នូលនៃគោលនយោបាយអភិបាលកិច្ចល្អរបស់ខ្លួន។ គណនេយ្យភាពបង្ហាញពី៖ (១) ការទទួលខុសត្រូវរបស់អង្គភាព (២) ការកាត់បន្ថយអំពើពុករលួយក្នុងអង្គភាព/រដ្ឋាភិបាល (៣) ពន្លឿនផ្នែកសេវាសាធារណៈ (៤) ភាពត្រឹមត្រូវនៃមូលដ្ឋានគតិយុត្តិនិងច្បាប់ (Wirtz, B. W., & Birkmeyer, S., 2015) ។

ម៉្យាងវិញទៀត "គណនេយ្យភាព" ជាសមាសភាពនៃអភិបាលកិច្ចល្អគឺ៖ (១) "គណនេយ្យភាព" ជាគុណធម៌ (Accountability as a virtue) ដែលផ្តល់ភាពស្របច្បាប់ទៅមន្ត្រីសាធារណៈ និងអង្គភាពសាធរណៈដែលរួមមានតម្លាភាព ភាពជឿទុកចិត្ត សមត្ថភាពចាត់ចែង ទំនួលខុសត្រូវ និងការឆ្លើយតបទៅនឹងពីរសំណួរជាមូលដ្ឋានគឺ៖ តើនរណាជាតួអង្គបង្ហាញគណនី? និងហេតុអ្វីត្រូវតែបង្កើតគណនី? គណនេយ្យភាពជាយន្តការនៃការសម្រេចចិត្តរបស់អង្គភាព ក្នុងការបង្កើតឱ្យមានអភិបាលកិច្ចល្អ មាននិន្នាការជានាឱ្យមានគណនេយ្យភាពដល់សាធារណជននិងអង្គភាពសាធារណៈប្រកបដោយគុណធម៌ (Bovens, 2010)។

យោងតាមការសិក្សាផ្នែករដ្ឋបាលសាធារណៈ ឧបករណ៍ធំៗចំនួនប្រាំត្រូវបានប្រើក្នុងការវាស់គណនេយ្យភាពគឺ៖

(១) តម្លាភាព តើយន្តការក្នុងអង្គភាពបង្ហាញជាសាធារណៈឬទេ?

(២) ភាពជឿទុកចិត្ត តើយន្តការអង្គភាពមានឧបសគ្គដែរឬទេ?

(៣) សមត្ថភាពគ្រប់គ្រង តើអង្គភាពបានដំណើរការតាមគោលនយោបាយ និងនីតិវិធីឬទេ?

(៤) ទំនួលខុសត្រូវ តើអង្គភាពអនុវត្តតាមច្បាប់ឬទេ?

(៥) ភាពឆ្លើយតបទាន់ពេល តើអង្គភាពសម្រេចបានគោលដៅឬទេ? (Christie, 2018)

ដូចគ្នាដែរ ឆ្នាំ២០០៤ "គណនេយ្យភាព" ត្រូវបានរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា យកធ្វើជាសូចនាករមួយទៀតក្នុងកំណែទម្រង់ប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ។ សូចនាករនេះ (គណនេយ្យភាព) ត្រូវបានកំណត់ក្នុងកំណែទម្រង់ប្រព័ន្ធហិរញ្ញវត្ថុសាធារណៈយ៉ាងដូច្នេះថា "គណនេយ្យភាព" សំដៅលើការទទួលខុសត្រូវរបស់ក្រសួង ស្ថាប័ន ឬអង្គភាពសាធារណៈប្រហាក់ប្រហែល រដ្ឋបាលថ្នាក់ក្រោមជាតិ និងបុគ្គលចំពោះមុខងារ និងភារកិច្ចដែលទទួលអនុវត្តតាមរយៈប្រព័ន្ធរបាយការណ៍ (ក្រសួងសេដ្ឋកិច្ច និងហរិញ្ញវត្ថុ, ២០១៣)។

“គណនេយ្យភាពរបស់សាលារៀនចំពោះសង្គម ពង្រឹងគុណភាពអប់រំនៅកម្ពុជា” នេះជាសារខ្លីរបស់ឯកឧត្តមបណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ក្នុងពិធីសម្ពោធការដាក់ឱ្យអនុវត្តគម្រោងគាំទ្រ ផែនការអនុវត្តគណនេយ្យភាពសង្គម ដំណាក់កាលទី២ នៅថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០២១ និងក្នុងយុទ្ធនាការផ្សព្វផ្សាយការងារគណនេយ្យសង្គម។

### ២.១៤.៣. នីតិរដ្ឋ (ភាពអាចគ្រោងទុកបាន)

ភាពអាចគ្រោងទុកបាន សំដៅទៅលើការធ្វើសេចក្ដីសម្រេចចិត្តដោយផ្អែក លើវិធានច្បាប់ច្បាស់លាស់ ។ ការមានវិធានច្បាប់ច្បាស់លាស់អាចនិងធ្វើការសម្រេច ដោយផ្អែកលើវិធានច្បាប់ជាធរមាន មិនមានផ្អែកលើគំនិត ឬអំណាចបុគ្គលទេ (ក្រសួងអ.យ.ក, ២០១៦ខ)។ ក្រសួង អប់រំ យុវជន និងកីឡា (២០១៦) បានបន្ថែមទៀតថា ដើម្បីធានាឱ្យមានសេចក្ដីសម្រេចប្រកបដោយទំនួលខុសត្រូវលើវិធានច្បាប់ ចាំបាច់គេត្រូវមានតម្លាភាព និងស្វែងយល់យ៉ាងច្បាស់ពីការធ្វើសេចក្ដីសម្រេចចិត្តនោះ ដោយមានការចូលរួមពីមន្ត្រី អង្គការ ក្រសួង ស្ថាប័ននានាដែលពាក់ព័ន្ធ។ បន្ថែមលើតម្លាភាពក្នុងការធ្វើសេចក្ដីសម្រេចនៃភាពអាចគ្រោងទុកបាន និងនីតិរដ្ឋគឺជាកត្តាធ្វើឱ្យកម្រិតអភិបាលកិច្ចកាន់តែប្រសើរ ។

### ២.១៤.៤. ការចូលរួម

ការចូលរួមគឺជាការធ្វើឱ្យមានឥទ្ធិពលលើគោលនយោបាយ និងវិធាន ច្បាប់លើការកំណត់អាទិភាពផែនការ និងយុទ្ធសាស្ត្រ លើសេចក្ដីសម្រេចចិត្តលើលទ្ធផលនៃសកម្មភាពជាក់លាក់ណាមួយ

(ក្រសួងអ.យ.ក, ២០១៦ខ) ។ ការចូលរួមដែលសំខាន់ចាំបាច់ដើម្បីឱ្យមានអភិបាលកិច្ចកាន់តែល្អ គឺការចូលរួមជាយោបល់ និងដោយផ្ទាល់។ អ្នកពាក់ព័ន្ធអាចចូលរួមក្នុងអភិបាលកិច្ចរួមមានសមាសសភាពដូចជាមន្ត្រីសាធារណៈ សមាជិកក្រុមប្រឹក្សា សមាជិក ក្រុមការងារ ឬគណៈកម្មាធិការនានាជាទីប្រឹក្សា ឬអ្នកពិគ្រោះយោបល់ជាអ្នកចូលរួមយ៉ាងសកម្មក្នុងកិច្ចប្រជុំពិភាក្សាពិគ្រោះយោបល់នានា ឬការទំនាក់ទំនង តាមមធ្យោបាយណាជាមួយមន្ត្រី ឬអ្នកធ្វើការសម្រេចនោះ។ ការចូលរួមក្នុងលក្ខណៈប្រជាធិបតេយ្យមានពីរបែបគឺ៖ (១) ការចូលរួមដោយប្រយោលតាមរយៈការជ្រើសរើសអ្នកតំណាង ឬការជ្រើសរើសអ្នកចូលរួមធ្វើសេចក្តីសម្រេច និង (២) ការចូលរួមដោយផ្ទាល់ក្នុងការធ្វើសេចក្តីសម្រេចនានាក្នុងនាមជាសមាជិក ក្រុមការងារ ឬអ្នកផ្តល់យោបល់ និងអនុសាសន៍។

រីឯព្រឹត្តិបត្រចុះផ្សាយអន្តរជាតិស្តីពីរដ្ឋាភិបាលបើកចំហ ( Open Government: Origin, Development, and Conceptual Perspectives) បានលើកឡើងនឹងដកស្រង់បានមូលដ្ឋានចំនួនបួនធំៗក្នុងការចូលរួម ៖ (១) ផ្តល់ការលើកទឹកចិត្ត (២) ផ្តល់ឱកាសស្មើៗគ្នា និង(៣)ផ្តល់សេរីភាពក្នុងការសម្រេចចិត្តដោយផ្ទាល់និងប្រយោល និង (៤) ផ្តល់សេរីភាពក្នុងការបញ្ចេញមតិជាសាធារណៈ (Wirtz, B. W., & Birkmeyer, S., 2015)។

ដោយសង្ខេបយោងតាម សៀវភៅការគ្រប់គ្រង និងភាពជាអ្នកដឹកនាំ សម្រាប់បំប៉ននាយកសាលាបឋម និងមធ្យមសិក្សា នៃនាយកដ្ឋានបណ្តុះបណ្តាល និងវិក្រឹតការ របស់ ក្រសួង អប់រំ យុវជន និងកីឡា (២០១៦) បានលើកឡើងនៃអភិបាលកិច្ចសាលារៀនចំនួនបួន ដូចបានខាងក្រោម ៖

តារាង 2 ២.១៤ សមាសធាតុអភិបាលកិច្ច

| ល.រ | ធាតុសំខាន់ៗ | និយមន័យរួម | សមាសធាតុតូចៗ |
|---|---|---|---|
| ១ | តម្លាភាព | សំដៅរាល់វិធាន  នីតិវិធី សេចក្តីសេចក្តីសម្រេច និងព័ត៌មានពាក់ព័ន្ធទាំងឡាយត្រូវបានបើកចំហជាសាធារណៈ ។ | -ព័ត៌មានមានលក្ខណៈបើកចំហ និងងាយស្រួលយល់<br>-បិទប្រកាសឬបិទផ្សាយ<br>-ឆ្លើយទៅនឹងការស្នើសុំក្នុងក្របខណ្ឌច្បាប់<br>-ផ្តល់ការសម្រេចចិត្តដល់និយោជិត<br>-ធ្វើបច្ចុប្បន្នភាពព័ត៌មាន<br>-តម្លាភាពផ្នែកហិរញ្ញវត្ថុ |
| ២ | គណនេយ្យភាព | សំដៅទៅលើការអនុវត្តតួនាទី និងភារកិច្ចក្នុងដំណើរការនៃការសម្រេចចិត្តហើយទទួលខុសត្រូវចំពោះទង្វើរបស់ខ្លួនដោយរាយការណ៍ព្រមទាំងបញ្ជាក់អំពីមូលហេតុដែលខ្លួនបានសម្រេច និងអនុវត្ត។ | -ការទទួលខុសត្រូវរាល់សកម្មភាពដែលបានអនុវត្ត<br>-ការទទួលខុសត្រូវរបស់អង្គភាព<br>-ការទទួលខុសត្រូវចំពោះមុខថ្នាក់ដឹកនាំ<br>-ទទួលខុសត្រូវនឹង មានឆន្ទៈឆ្លើយតបទៅនឹងសំណួរ និងផ្តល់នូវដំណោះស្រាយសមស្រប<br>-ភាពជឿទុកចិត្តបាន<br>-គណនេយ្យភាពសិក្សា<br>-គណនេយ្យភាពពីដំណើរការសាលារៀន<br>-គណនេយ្យភាពហិរញ្ញវត្ថុ<br>-គណនេយ្យភាពក្នុងអង្គភាព<br>-គណនេយ្យភាពខាងក្រៅ |
| ៣ | នីតិរដ្ឋ (ភាពអាចគ្រោងទុកបាន) | សំដៅទៅលើការធ្វើសេចក្តីសម្រេចចិត្តដោយផ្អែក លើវិធានច្បាប់ច្បាស់លាស់ ។ ការមានវិធានច្បាប់ច្បាស់លាស់អាចនិងធ្វើការសម្រេច ដោយផ្អែកលើវិធានច្បាប់ជាធរមាន មិនមានផ្អែកលើគំនិត ឬអំណាចបុគ្គលទេ | -ទំនួលខុសត្រូវលើវិធានច្បាប់<br>-សេចក្តីសម្រេចមានការចូលរួមពីមន្ត្រី អង្គការ ក្រសួង ស្ថាប័ន នានាដែលពាក់ព័ន្ធ<br>-ប្រព័ន្ធយុត្តិធម៌<br>-ឯកសារក្របខណ្ឌច្បាប់<br>-អនុវត្តមិនលំអៀងនិងមិនពុករលួយ |

| | | | |
|---|---|---|---|
| ៤ | ការចូលរួម | គឺជាការធ្វើឱ្យមានឥទ្ធិពលលើគោលនយោបាយ និងវិធាន ច្បាប់លើការកំណត់អាទិភាពផែនការ និងយុទ្ធសាស្ត្រ លើសេចក្តីសម្រេចចិត្ត លើលទ្ធផលនៃសកម្មភាពជាក់លាក់ណាមួយ | -ចូលរួមក្នុងលក្ខណៈប្រជាធិបតេយ្យ<br>-ការចូលរួមធ្វើសេចក្តីសម្រេច<br>-ការចូលរួមជាយោបល់ និងជាអនុសាសន៍<br>-ការចូលរួមប្រជុំរបស់អ្នកពាក់ព័ន្ធ<br>-ការចូលរួមអភិវឌ្ឍសមត្ថភាព |

## ២.១៥. គណនេយ្យភាពសាលារៀន

គណនេយ្យភាពសាលារៀនជាផ្នែកសំខាន់ទី៣នៃប្រព័ន្ធ ៣អា បិទជិត ។ វារួមមាន (១) គណនេយ្យភាពពីដំណើរការសាលារៀន (២) គណនេយ្យភាពសិក្សា (៣) និងគណនេយ្យភាពហិរញ្ញវត្ថុ (ក្រសួង អ.យ.ក, ២០១៨) ។

### ២.១៥.១. គណនេយ្យភាពពីដំណើរការសាលារៀន

លទ្ធផលបានពីការវាយតម្លៃសិស្ស និងសាលារៀនត្រូវបានយកមកប្រើប្រាស់ដើម្បីបញ្ជាក់គណនេយ្យភាពពីប្រតិបត្តិការណ៍សាលារៀន ។ ភស្តុតាងជាតារាងទិន្នន័យចំនួរពីរបិទផ្សាយជាសាធារណៈនៅដើមឆ្នាំសិក្សាដែលបញ្ជាក់នូវគណនេយ្យភាពសាលារៀន ៖ (១) ផែនការកែលម្អសាលារៀននិងថវិកាប្រចាំឆ្នាំ និង (២) ចំណូលរបស់សាលារៀនពីគ្រប់ប្រភេទធនធាន ។

### ២.១៥.២. គណនេយ្យភាពសិក្សា

គណនេយ្យភាពសិក្សាបីកម្រិត៖ កម្រិតទី១ មានគ្រូបង្រៀន មាតាបិតា និងសិស្ស កម្រិតទី២ មានគណៈកម្មការគ្រប់គ្រងសាលារៀន និងមន្ត្រីអប់រំស្រុក/ខណ្ឌ និងកម្រិតទី៣ មានក្រុមការងារគ្រប់គ្រងតាមសាលារៀន និងមន្ត្រីអប់រំរាជធានីនិងខេត្ត។

ភស្តុតាងគណនេយ្យភាពសិក្សាបង្ហាញដោយតារាងទិន្នន័យចំនួន៣ ដែលត្រូវបិទផ្សាយជាសាធារណៈនៅដំណាច់ឆ្នាំសិក្សា ៖

កម្រិតទី១ តារាងពិន្ទុតេស្តប្រចាំត្រីមាសប្រចាំថ្នាក់ និងតាមមុខវិជ្ជាគោល

កម្រិតទី២ តារាងទិន្នន័យនៅដំណាច់ឆ្នាំសិក្សា វត្ថុបំណងគោលនយោបាយសាលារៀននិងផលសម្រេច និងក្រុមគោលដៅរយៈពេល៣ឆ្នាំ

កម្រិតទី៣ តារាងទិន្នន័យពីរបាយការណ៍ប្រៀបធៀបសូចនាករសំខាន់ៗរបស់សាលារៀន (ប្រចាំឆ្នាំ)។

### ២.១៥.៣. គណនេយ្យភាពហិរញ្ញវត្ថុ

តាមទិន្នន័យហិរញ្ញវត្ថុ ថវិកាសាលារៀន និងការគ្រប់គ្រងហិរញ្ញវត្ថុ ត្រូវបិទផ្សាយជាសាធារណៈនៅចុងឆ្នាំសិក្សានីមួយៗ ។

## ២.១៦. ស្វ័យភាពភាពប្រតិបត្តិការរបស់សាលារៀនជំនាន់ថ្មី

គោលបំណងរបស់សាលារៀនជំនាន់ថ្មី គឺការបង្កើតសាលារដ្ឋដែលរក្សាបានស្តង់ដារនៃការអប់រំបានខ្ពង់ខ្ពស់បំផុតតាមរយៈការវិនិយោគថវិកាច្រើន និងផ្តោតទៅលើការពង្រឹងតម្លាភាព និងទទួលខុសត្រូវដោយការផ្លាស់ប្តូរវិធីគ្រប់គ្រងសាលា។ នេះគឺជាការខុសប្លែកពីវិធីសាស្ត្រប្រពៃណីរបស់រដ្ឋាភិបាលដែលរមែងតែងតែបែងចែកមូលនិធិស្មើៗគ្នាទាំងអស់ (ឌី ខាំបូលី, ២០១៨) ។

សាលារៀនជំនាន់ថ្មីជាកម្មវិធីកំណែទម្រង់ថ្មី ដាក់ចេញដោយក្រសួងអប់រំ យុវជន និងកីឡាកាលពីឆ្នាំ២០១៥ ដើម្បីបង្កើតឱ្យមានសាលារៀនរដ្ឋ "ស្វយ័ត" មានសិទ្ធិច្នៃប្រឌិតបង្កើតថ្មី និងលើកកម្ពស់គុណភាពអប់រំ (ខេប, ២០១៨)។ សាលារៀនជំនាន់ថ្មីមានបុព្វសិទ្ធិទទួលបានមូលនិធិវិនិយោគខ្ពស់អាស្រ័យលើស្តង់ដាអភិបាលកិច្ច និងវិជ្ជាជីវៈខ្ពស់។ គន្លងអភិវឌ្ឍន៍ថ្មីនេះព្យាយាមជំរុញគ្រឹះស្ថានសិក្សាសាធារណៈឱ្យឈានខ្ពស់មួយកម្រិតទៀតដើម្បីសម្រេចបាននូវស្តង់ដាអប់រំអតិប្បរមាជាពិសេសចំពោះមុខវិជ្ជាស្ទែម (STEM)។ ស្ថិតក្រោមគោលនយោបាយថ្មីដែលកំណត់និយមន័យសាលារៀនជំនាន់ថ្មី ក្រសួងបានធ្វើការប្តេជ្ញាចិត្តខ្លាំង ដើម្បីធ្វើការវិនិយោគប្រកបដោយប្រសិទ្ធភាពខ្ពស់ដល់សាលារៀនបែបនេះក្រោមលក្ខខណ្ឌដែលសាលាត្រូវធានាឱ្យបាននូវស្តង់ដាអភិបាលកិច្ចល្អ។ សាលារៀនជំនាន់ថ្មីនីមួយៗនឹងត្រូវអង្កេត និងវាយតម្លៃដោយក្រុមប្រឹក្សាភិបាលដែលនឹងធ្វើឱ្យការបំពេញភារកិច្ចប្រកបដោយស្តង់ដាខ្ពស់ ។ ជាមួយ

តម្រូវការប្រព័ន្ធវាយតម្លៃទទួលស្គាល់គុណភាពអប់រំយ៉ាងតឹងរ៉ឹងផ្សារភ្ជាប់នឹងការវិនិយោគបន្ត គោលនយោបាយថ្មីបានលើកទឹកចិត្តដល់សាលាឱ្យប្រកាន់ខ្ជាប់នូវបទដ្ឋានអប់រំខ្ពស់។ សាលារៀនជំនាន់ថ្មីអនុវត្តតាមគំរូពីប្រទេសផ្សេងៗដែលសាលារៀនរដ្ឋមួយចំនួនទទួលបានស្វ័យភាពពេញលេញពីរដ្ឋក្នុងការច្នៃប្រឌិតកម្មវិធីអប់រំ។ ចំណុចនេះគឺ សំដៅពិសេសទៅលើចលនា "**សាលារៀនធម្មនុញ្ញ**" **ឬ** Charter School នៅសហរដ្ឋអាមេរិក និងប្រទេសដទៃទៀត។ ក្រសួងមានគោលបំណងបង្កើតសាលារៀនជំនាន់ថ្មីយ៉ាងតិចចំនួន៥០សាលាក្នុងរយៈពេល១០ឆ្នាំទៀត។

កម្មវិធីសាលារៀនជំនាន់ថ្មីគឺជាសមាសភាគដ៏សំខាន់មួយនៃកម្មវិធីកំណែទម្រង់វិស័យអប់រំដែលបានគាំទ្រដោយ ក្រសួងអប់រំ យុវជន និងកីឡា។ កម្មវិធីនឹងបង្កើតលំនាំមួយដែលនឹងនាំឱ្យមានការបង្កើតសាលារៀនរដ្ឋស្វយ័តដែលនឹងទទួលបានការវិនិយោគពិសេសភ្ជាប់ទៅនឹងស្តង់ដារថ្មីមួយនៃគណនេយ្យភាព និងអភិបាលកិច្ចសាលារៀន (ខេប, ២០១៨) ។ សាលាដែលមិនឆ្លើយតបនឹងស្តង់ដារជាសាលារៀនជំនាន់ថ្មីនឹងបាត់បង់ឋានៈជាសាលារៀនជំនាន់ថ្មី ហើយសាលារៀននឹងនេះនៅតែដើរតាមកម្មវិធីក្រសួងដែលមានការវិនិយោគធម្មតាលើវិស័យអប់រំ។ សាលារៀនជំនាន់ថ្មីនឹងផ្តល់ស្តង់ដារអប់រំថ្មីមួយនៅក្នុងសាលារដ្ឋដើម្បីរៀបចំយុវជនកម្ពុជាសម្រាប់សតវត្សទី២១។

## ២.១៧. គោលនយោបាយសាលារៀនជំនាន់ថ្មី

ការបង្កើតសាលារៀនជំនាន់ថ្មី គឺជាលំនាំបន្តពីកិច្ចខិតខំប្រឹងប្រែងនៃកម្មវិធីសាលាកុមារមេត្រីដោយយកលំនាំតាមការនុវត្តនៅក្នុងបណ្តាប្រទេសមួយចំនួន ដែលសាលារៀនសាធារណៈមួយចំនួនទទួលបានស្វ័យភាពយ៉ាងច្រើនពីរដ្ឋាភិបាលដើម្បីជំរុញនវានុវត្តអប់រំ (ក្រសួង.អ.យ.ក, ២០១៦a)។ ចំណុចនេះសំដៅដល់ចលនាសាលារៀនធម្មនុញ្ញ (Charter School Movement)។ សាលារៀនបែបនេះបានជួយស្តារវិធានការនានាដែលធានាបាន អភិបាលកិច្ចល្អ និងជួយពង្រឹងភាពល្បីល្បាញរបស់សាលារៀនសាធារណៈលើផ្នែកមួយចំនួនដែលសាលាខិតខំប្រឹងប្រែងធ្វើឱ្យសម្រេចបាន។

### ការត្រួតពិនិត្យសាលារៀនជំនាន់ថ្មីដោយផ្ទាល់ពីថ្នាក់ជាតិ

- ត្រួតពិនិត្យដោយផ្ទាល់ពីថ្នាក់ជាតិទៅលើសាលារៀនសាធារណៈស្វយ័ត ដែលបានរៀបចំជាសាលារៀនជំនាន់ថ្មី តាមរយៈក្រុមប្រឹក្សាភិបាលថ្នាក់ជាតិ បង្កើតឡើងដោយក្រសួងអប់រំ យុវជន និងកីឡា។
- ប្រគល់អំណាចគ្រប់គ្រងទៅឱ្យក្រុមប្រឹក្សាភិបាលថ្នាក់មូលដ្ឋាន នៅពេលដែលសាលារៀនជំនាន់ថ្មីកើនឡើងនៅឆ្នាំបន្តបន្ទាប់។

### ប្រាក់លើកទឹកចិត្តគ្រូ

ផ្តល់ប្រាក់លើកទឹកចិត្តពិសេសដល់គ្រូបង្រៀន ដើម្បីលើកកម្ពស់ការបំពេញភារកិច្ចឈានទៅលុបបំបាត់ការបង្រៀនឯកជនសិស្ស (បង្រៀនគួរ) របស់ខ្លួនដែលប៉ះពាល់ដល់វិជ្ជាជីវៈនិងសេចក្តីថ្លៃថ្នូរគ្រូបង្រៀន។

### ដំណើរការស្វ័យភាពផ្សារភ្ជាប់នឹងការច្នៃប្រឌិតថ្មី

- អនុញ្ញាតឱ្យប្រតិបត្តិការក្រៅក្របខណ្ឌគោលនយោបាយដែលបានអនុវត្តនៅក្នុងសាលារៀនធម្មតាដរាបណាសាលានោះអាចបង្ហាញឱ្យឃើញសកម្មភាពដែលបានស្នើសុំលើកកម្ពស់ការច្នៃប្រឌិតថ្មីដើម្បីបង្កើនគុណភាពអប់រំមានសិទ្ធិជ្រើសរើសគ្រូមកពីសាលានានា
- កែលម្អកម្មវិធីសិក្សា ការប្រើប្រាស់បច្ចេកវិទ្យាដើម្បីបង្កើនប្រសិទ្ធភាពអប់រំ ដូចជាការធ្វើកិច្ចតែងការបង្រៀនអេឡិចត្រូនិក ការសិក្សាតាមឧបករណ៍ចល័តជាដើម។ល។ និងទម្រង់ផ្សេងៗទៀតនៃការច្នៃប្រឌិតថ្មីក្នុងការសិក្សា ព្រមទាំងការផ្តល់ឱ្យដំណើរការស្វ័យភាពនិង ផ្អែកលើភ័ស្តុតាងនៃការច្នៃប្រឌិតថ្មី

### ការប្រើប្រាស់បច្ចេកវិទ្យាឱ្យបានទូលំទូលាយដើម្បីជំរុញការច្នៃប្រឌិតថ្មី

ប្រើប្រាស់បច្ចេកវិទ្យាដែលនឹងក្លាយជាធាតុគន្លឹះនៅក្នុងសាលារៀនជំនាន់ថ្មី ដោយមិនគ្រាន់តែរាប់បញ្ចូលការទទួលបានការប្រើប្រាស់ឧបករណ៍រឹងប៉ុណ្ណោះទេ ប៉ុន្តែសិស្សត្រូវចេះប្រើកម្មវិធីទន់ក្នុងការអប់រំ

ទំនើបទៀតផង ដែលនឹងជួយពង្រឹងការសិក្សា ការបង្រៀន និងការវាយតម្លៃ (ឧទាហរណ៍ កម្មវិធី literatu, 3D Classroom ។ល។)

### ការធ្វើទំនើបកម្មបរិស្ថានសិក្សា

ប្រើគំនិតច្នៃប្រឌិតថ្មីក្នុងស្ថាបត្យកម្មអប់រំដើម្បីកែប្រែបន្ទប់រៀន និងបន្ទប់ផ្សេងៗទៀតក្នុងសាលារៀនឱ្យសមស្របទៅនឹងស្តង់ដាសាលារៀននាសតវត្សទី២១ ។

### ការបង្កើនម៉ោងបង្រៀន និងរៀន

- បង្កើនម៉ោងបង្រៀនដល់ ៣៤ ម៉ោងសិក្សាក្នុងមួយសប្តាហ៍នៅកម្រិតបឋមសិក្សា និង៤០ ម៉ោងសិក្សាក្នុងមួយសប្តាហ៍សម្រាប់មធ្យមសិក្សា
- តម្រូវឱ្យគ្រូប្រកាន់ខ្ជាប់វិន័យតាមសេចក្តីណែនាំផ្លូវការដែលតម្រូវឱ្យគាត់បង្រៀនពេញម៉ោង (១៨ម៉ោងក្នុងមួយសប្តាហ៍សម្រាប់គ្រូបង្រៀនមធ្យមសិក្សាបឋមភូមិ និង១៦ម៉ោងក្នុងមួយសប្តាហ៍សម្រាប់គ្រូបង្រៀនមធ្យមសិក្សាទុតិយភូមិ)។

### មូលនិធិសមធម៌សង្គម

- តម្រូវឱ្យបង្ហាញការឆ្លើយតបនឹងតម្រូវការសមាជិកសហគមន៍ក្រីក្រ ផ្តល់ការលើកទឹកចិត្តដល់គ្រួសារក្រីក្រក្នុងការរក្សាកូនឱ្យមកទទួលការអប់រំ បង្កើតមូលនិធិសមធម៌សង្គម ដែលនឹងអាចឱ្យសាលាទទួលបានមូលនិធិបន្ថែមដើម្បីជួយដល់សិស្សក្រីក្រ
- លុបបំបាត់ចោលឱ្យបានដាច់ខាតការយកតម្លៃក្រៅផ្លូវការដែលប៉ះពាល់ដល់សិស្សក្រីក្រ។

### ការគាំទ្រហិរញ្ញវត្ថុ

- សាលារៀនជំនាន់ថ្មីអាចទទួលបានធនធានហិរញ្ញវត្ថុពីប្រភពនានារួមទាំងការផ្តល់ហិរញ្ញវត្ថុ ដោយផ្ទាល់ពីរាជរដ្ឋាភិបាល ស្ថាប័នពហុភាគី និងទ្វេភាគី និងអង្គការមិនមែនរដ្ឋាភិបាល ព្រមទាំងមូលនិធិឯកជនជាដើម

- សាលារៀនជំនាន់ថ្មីអាចចរចាស្នើសុំថវិកាបដិភាគពីមាតាបិតាសិស្សដោយស្ម័គ្រចិត្តបន្ទាប់ពីអនុវត្តបាន៣ឆ្នាំ តែត្រូវភ្ជាប់ជាមួយលក្ខខណ្ឌដែលសាលារក្សាបាននូវការទទួលស្គាល់
- ក្រសួងនឹងរៀបចំបង្កើតមូលនិធិសមធម៌សង្គម ដើម្បីធានាថាការចរចាជាមួយមាតាបិតា សិស្សឱ្យចូលរួមបដិភាគថវិកាដោយមិនឱ្យមានផលប៉ះពាល់អវិជ្ជមានដល់គ្រួសារសិស្សក្រីក្រឡើយ
- សាលារៀនជំនាន់ថ្មីអាចស្វែងរកប្រាក់ចំណូលអង្គភាពតាមរយៈការជួលអាហារដ្ឋានសាលារៀន ការវិនិយោគប្រាក់អំណោយ និងទម្រង់ផ្សេងៗទៀតនៃសកម្មភាពរកប្រាក់ចំណូលក្នុងមូលដ្ឋានដើម្បីធានានិរន្តរភាព
- សាលារៀនជំនាន់ថ្មីនឹងរៀបចំផែនការវិនិយោគក្នុងឆ្នាំនីមួយៗដើម្បីជួសជុល និងកែលម្អ ដោយប្រើទម្រង់ស្តង់ដាដែលមានផ្តល់ជូនក្នុងគោលការណ៍ប្រតិបត្តិសម្រាប់សាលារៀនជំនាន់ថ្មី។

## ២.១៨. ស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀន

ស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀននៅកម្ពុជាយើងបានកំណត់ជាបួនសមាសភាពគឺ ចំណេះដឹងវិជ្ជាជីវៈ ការប្រតិបត្តិវិជ្ជាជីវៈ ការសិក្សាវិជ្ជាជីវៈ និងសីលធម៌វិជ្ជាជីវៈ (ក្រសួង.អ.យ.ក, ២០១០)។ ភ្ជាប់ជាមួយគ្នានេះផងដែរក្រសួងអប់រំ យុវជន និងកីឡាក៏បានកំណត់បញ្ញត្តិធំៗបីនៃស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀនគឺៈ

- ជាសេចក្តីអធិប្បាយសង្ខេប និងច្បាស់លាស់នូវទិដ្ឋភាពទាំងឡាយណាដែលគ្រូបង្រៀនត្រូវយល់ដឹង និងធ្វើ
- ជាការបញ្ជាក់ប្រាប់ពីអំពើ ឬសកម្មភាពរបស់គ្រូបង្រៀនដែលអាចអនុវត្តបាន ហើយមានឥទ្ធិពលទៅលើសិស្ស។
- ជាឧបករណ៍សម្រាប់វាស់សមត្ថភាពដែលស្តែងចេញរបស់គ្រូបង្រៀន។

គ្រូបង្រៀនមិនត្រូវរៃអង្គាសប្រាក់ ឬ ប្រមូលប្រាក់ក្រៅផ្លូវការ ឬ ធ្វើអាជីវកម្មនានាក្នុងថ្នាក់រៀនឡើយ ។ គ្រូបង្រៀនត្រូវជៀសវាងការប្រកបមុខរបរផ្សេងក្នុងបរិវេណគ្រឹះស្ថានសិក្សា ( រាជរដ្ឋាភិបាល, ២០០៨)។

## ២.១៩. កំណែទម្រង់អប់រំនៃការគ្រប់គ្រងគំរូអភិបាលកិច្ច

### ២.១៩.១ ការគ្រប់គ្រងគំរូអភិបាលកិច្ចថ្មី ដំណាក់កាលទី១

ការធ្លាក់ចុះគុណភាពអប់រំក្នុងសាលារៀនសាធារណៈបានកើតឡើងដោយមានចូលរួមពីកត្តាជាច្រើនផ្សេងៗពីគ្នា។ កត្តាមួយនៅក្នុងចំណោមកត្តាជាច្រើនដែលបានធ្វើឱ្យប្រព័ន្ធអប់រំធ្លាក់ចុះខ្លាំងនោះគឺការបាត់បង់រចនាសម្ព័ន្ធអភិបាលកិច្ច (ខេប , ២០១១) ។ ដោយឃើញពីបញ្ហាដែលបានកើតឡើង នៅក្នុងឆ្នាំ២០១១ គម្រោងសាលារៀនដៃគូបានគិតគូធ្វើយ៉ាងណាបង្កើតឡើងវិញនូវគំរូរចនាសម្ព័ន្ធអភិបាលកិច្ច ក្នុងគោលបំណងដើម្បីដោះស្រាយបញ្ហានេះឱ្យខានតែបាន។ ដំណោះស្រាយលើការរៀបចំរចនាសម្ព័ន្ធអភិបាលកិច្ចថ្មី នៅក្នុងសាលារៀនសាធារណៈ គឺសំខាន់ទាមទារឱ្យមានការបង្កើតតួនាទីដល់វិស័យឯកជនក្នុងដំណើរការគ្រប់គ្រងសាលារៀនដែលផ្សារភ្ជាប់ទំនាក់ទំនងយ៉ាងរឹងមាំជាមួយវិស័យសាធារណៈ ដែលមិនធ្លាប់មានពីមុននៅកម្ពុជា។ ទម្រង់នេះមានក្នុងបណ្តាប្រទេសមួយចំនួន ដែលគេអនុវត្តន៍ប្រកបដោយភាពជោគជ័យមានន័យថា គម្រោងបានធ្វើការកសាងភាពជាដៃគូរវាងរដ្ឋ និងវិស័យឯកជន (ខេប, ២០១៤) ក្នុងការរៀបចំ ដឹកនាំគ្រប់គ្រងទូទៅនៅក្នុងសាលារៀនរដ្ឋ។

ដូច្នេះក្នុងដំណើរការគាំទ្រចំពោះគំរូអភិបាលកិច្ចថ្មីក្នុងប្រព័ន្ធអប់រំសាធារណៈ ពិតជាបានចូលរួមចំណែកយ៉ាងច្រើនដល់ការកសាងគុណភាពអប់រំសម្រាប់សិស្សកម្ពុជា ដើម្បីសម្រេចលទ្ធផលរូបីយ៍នានានៅតាមសាលារៀនរដ្ឋផ្ទាល់។ ដោយឡែក អ្វីដែលសាលារៀនសម្រេចបានលើការអនុវត្តគំរូអភិបាលកិច្ចថ្មីនៅដំណាក់កាលទី១រួមមាន ការរៀបចំដំណើរការការជ្រើសរើសគ្រូ ប្រកបដោយគុណភាពវិជ្ជាជីវៈ និងឆន្ទៈមោះមុត ការគ្រប់គ្រងប្រកបដោយប្រសិទ្ធភាព គំរូស្តង់ដាសិក្សាខ្ពស់ ការប្រើប្រាស់ធនធានបានត្រឹមត្រូវ ប្រាក់លើកទឹកចិត្តបន្ថែមលើការបំពេញភារកិច្ច គណនេយ្យភាព និងមិនអនុញ្ញាតឱ្យលោកគ្រូ អ្នកគ្រូប៉ះពាល់ថវិកាសិស្សក្រៅផ្លូវការគ្រប់រូបភាព ដូចជា បង្រៀនគួរ លក់ចំណីអាហារ លក់ក្រដាសប្រឡង។ លោកគ្រូ អ្នកគ្រូ ត្រូវធានារក្សាសមភាពសម្រាប់សិស្សគ្រប់គ្នា គ្រប់ទិដ្ឋភាព និងផ្តល់អាទិភាពលើសកម្មភាពរៀនសូត្រ មិនត្រូវប្រើអំពើហិង្សាផ្តល់ព័ត៌មានពីការសិក្សា និងអវត្តមានដល់អាណាព្យាបាល។

### ២.១៩.២ ការគ្រប់គ្រងគំរូអភិបាលកិច្ចថ្មី ដំណាក់កាលទី២

ដំណើរការរៀបចំគំរូអភិបាលកិច្ចថ្មី ដែលគម្រោងសាលារៀនដៃគូបានអនុវត្តន៍កន្លងមក ក្នុងដំណាក់កាលទី១ ពីឆ្នាំ២០១១ ដល់ឆ្នាំ២០១៤ និងត្រូវបានបន្តអនុវត្តន៍ក្នុងដំណាក់កាលទី២ ពីឆ្នាំ ២០១៤ ដល់ឆ្នាំ២០១៦ ចំណុចមួយចំនួនត្រូវពង្រឹងបន្ថែមឱ្យមានភាពកាន់តែល្អប្រសើរ ឡើងជាងមុន និងបន្ថែមលើខ្លឹមសារសំខាន់មួយគឺការពង្រឹងការចូលរួមរបស់មាតាបិតាសិស្ស មានន័យថាគម្រោងព្យាយាមឱ្យមានការចូលរួមពីសំណាក់អាណាព្យាបាលសិស្សដែលត្រូវបានលើកទឹកចិត្តឱ្យចូលរួមគ្រប់សកម្មភាពសាលារៀន ដូចជាចូលរួមកិច្ចប្រជុំជាទៀងទាត់ជាមួយសាលារៀនដើម្បីស្តាប់របាយការណ៍ប្រើប្រាស់ថវិកាចំណូលសាលារៀនពីគ្រប់ប្រភព។

ជាពិសេសប្រភពថវិកាដែលស្នើសុំការជួយគាំទ្រពីអាណាព្យាបាលសិស្សដោយស្ម័គ្រចិត្ត លើការចូលរួមបង់វិភាគទាន ៦៥$ ក្នុងមួយឆ្នាំសិក្សាសម្រាប់សិស្សម្នាក់ (ខេប, ២០១៥) ។ ការស្នើសុំនេះធ្វើឡើងសម្រាប់ពង្រឹងចំណូលក្នុងមូលដ្ឋាន និងធ្វើឱ្យកម្មវិធីកាន់តែមាននិរន្តរភាព (ខេប, ២០១៧)។ ថវិកាវិភាគទានត្រូវបែងចែកលើប្រាក់ឧបត្ថម្ភបន្ថែមជូនគ្រូបង្រៀន ការថែទាំសាលារៀន និងការចំណាយលើសម្ភារៈបរិក្ខាររូបវន្ត។ គួរបញ្ជាក់ដែរថា ការស្នើសុំការបង់វិភាគទានពីអាណាព្យាបាលបានទទួលស្គាល់ពីក្រសួងអប់រំ យុវជន និងកីឡា តាមរយៈក្របខណ្ឌគោលនយោបាយមូលនិធិសមធម៌ស្ម័គ្រចិត្ត។ សិស្សក្រីក្រលើកលែងលើលក្ខខណ្ឌនេះ ដើម្បីឱ្យពួកគេមានឱកាសទទួលបានការអប់រំដែលមានគុណភាពខ្ពស់ដោយឥតគិតថ្លៃ។

### ២.១៩.៣ ការគ្រប់គ្រងគំរូអភិបាលកិច្ចថ្មី ដំណាក់កាលទី៣

នាពេលកន្លងមកអ្នកគ្រប់គ្រងនៅក្នុងវិទ្យាល័យព្រះស៊ីសុវត្ថិ គឺបានលាក់កំបាំងលើបញ្ហា ជាច្រើនដែលពាក់ព័ន្ធនឹងអភិបាលកិច្ចរបស់ខ្លួនយ៉ាងធ្ងន់ធ្ងរក្នុងដំណើការសាលា។ ដោយឃើញពីភាពអសកម្មក្នុងការងារដឹកនាំគ្រប់គ្រង ក្រសួងអប់រំ យុវជន និងកីឡាក៏ចង់ធ្វើការកែទម្រង់ថ្មីនៅក្នុងវិទ្យាល័យព្រះស៊ីសុវត្ថិ ក្រសួងអប់រំក៏សម្រេចចិត្តដាក់ឱ្យដំណើការសាលារៀនជំនាន់ថ្មីនៅក្នុងវិទ្យាល័យនេះ។ ក្រោយពីសាលា

រៀនបានដំណើរការអនុវត្តកម្មវិធីសាលារៀនជំនាន់ថ្មី ក្នុងទម្រង់ជាសាលាក្នុងសាលាបានធ្វើឱ្យវិទ្យាល័យព្រះស៊ីសុវត្ថិ កែប្រែមុខមាត់ជាខ្លាំងលើគំរូអភិបាលកិច្ច។ បច្ចុប្បន្ននេះ វិទ្យាល័យព្រះស៊ីសុវត្ថិបានក្លាយជាសាលារៀនមួយដែលមានអភិបាលកិច្ចល្អ និងមានស្តង់ដាអប់រំខ្ពស់។ ពិសេសជាងនេះគឺសាលារៀនបានលុបបំបាត់រាល់ទម្រង់បង្រៀនឯកជនក្រៅផ្លូវការ ឬការបង្រៀនគួរ និងការបង់ថ្លៃសេវាកម្មក្រៅផ្លូវការផ្សេងៗដែលបង្កបញ្ហាដល់សិស្សក្រីក្រ។

ក្រៅពីនេះ សាលារៀនបានធ្វើការជ្រើសរើសគ្រូបង្រៀនថ្មីៗជាច្រើននាក់ ដោយមានការផ្សារភ្ជាប់ជាមួយការប្រគួតប្រជែងខ្ពស់ និងមានសមត្ថភាពល្អប្រកបដោយស្តង់ដាវិជ្ជាជីវៈ។ សាលាបានបំពេញការងារយ៉ាងល្អប្រសើរឆ្លើយតបនឹងស្តង់ដាអប់រំសតវត្សរ៍ទី២១ ស្របតាមកម្មវិធីសាលារៀនជំនាន់ថ្មី កំពុងត្រូវការជាខ្លាំងក្នុងការធ្វើកំណែទម្រង់ការអប់រំ (ស៊ីមហួន, ២០២១) ។ ការផ្លាស់ប្តូរមុខមាត់ថ្មីនេះ គឺជាការខិតខំប្រឹងប្រែងរបស់ថ្នាក់ដឹកនាំថ្មី ដែលជ្រើសរើសក្នុងនាមជាអ្នកដឹកនាំកម្មវិធីសាលារៀនជំនាន់ថ្មី ដើម្បីធ្វើឱ្យប្រសើរលើការងារ។ វិទ្យាល័យព្រះស៊ីសុវត្ថិ ធ្លាប់តែមានបញ្ហាប្រឈមលើប្រព័ន្ធអភិបាលកិច្ច បានក្លាយជាមានប្រព័ន្ធអភិបាលកិច្ចល្អឡើងវិញ។ នេះដោយសារការខិតខំប្រឹងប្រែងក្នុងការរៀបចំក្នុងនាមកម្មវិធីសាលារៀនជំនាន់ថ្មី រហូតទទួលបានជោគជ័យធំធេងលើការងារ។

## ២.១៩.៤ ការគ្រប់គ្រងគំរូអភិបាលកិច្ចថ្មី ដំណាក់កាលទី៤

មិនខុសអ្វីពីវិទ្យាល័យព្រះស៊ីសុវត្ថិនោះទេ សាលារៀនជំនាន់ថ្មី វិទ្យាល័យព្រែកលៀប ក៏បានសម្រេចការអភិវឌ្ឍគំរូសាលារៀនជំនាន់ថ្មី ក្នុងទម្រង់កែលម្អសាលារៀនទាំងមូលឱ្យទៅជាកម្មវិធីសាលារៀនជំនាន់ថ្មីផងដែរ។ ក្រោយពេលដែលសាលារៀនបានអនុវត្តន៍កម្មវិធីសាលារៀនជំនាន់ថ្មី វិទ្យាល័យព្រែកលៀប បានរៀបចំឱ្យមានការផ្លាស់ប្តូរពីសាលារៀនធម្មតាដែលធ្លាប់តែមានបញ្ហាប្រឈមពាក់ព័ន្ធនឹងប្រព័ន្ធអភិបាលកិច្ចរបស់ខ្លួនយ៉ាងធ្ងន់ធ្ងរនាពេលកន្លងមក បានកែប្រែឱ្យទៅជាសាលារៀនមួយដែលមានគំរូអភិបាលកិច្ច។

បច្ចុប្បន្ននេះ វិទ្យាល័យព្រែកលៀប បានក្លាយជាសាលារៀនមួយមានអភិបាលកិច្ចល្អ មានស្តង់ដាអប់រំខ្ពស់ ហើយបានលុបបំបាត់ចោលនូវរាល់ទម្រង់បង្រៀនឯកជនក្រៅផ្លូវការ ឬការបង្រៀនគួរ និងសេវាកម្មក្រៅផ្លូវការផ្សេងៗទាំងស្រុង។ ម្យ៉ាងទៀតនោះ សាលារៀនបានធ្វើការជ្រើសរើសគ្រូបង្រៀនថ្មីៗពីមួយឆ្នាំទៅមួយឆ្នាំ ដោយមានការប្រគួតប្រជែង និងមានសមត្ថភាពប្រកបដោយស្តង់ដាវិជ្ជាជីវៈ ព្រមទាំងបានបំពេញការងារយ៉ាងល្អប្រសើរឆ្លើយតបនឹងស្តង់ដាអប់រំបែបសតវត្សរ៍ទី២១ដែលកម្មវិធីសាលារៀនជំនាន់ថ្មីកំពុងត្រូវការជាចាំបាច់។ ស្របគ្នានេះគណៈគ្រប់គ្រងសាលារៀន លោកគ្រូ អ្នកគ្រូ បុគ្គលិករដ្ឋបាល និងសិស្សានុសិស្សបានយល់ដឹងពីតួនាទីកាតព្វកិច្ចរៀងៗខ្លួន ស្របតាមគោលនយោបាយរបស់កម្មវិធី។

សរុបមកសាលាទាំងអស់ដែលអនុវត្តកម្មវិធីសាលារៀនជំនាន់ថ្មី ពិតជាមានលក្ខណៈប្លែកតែមួយដោយបង្ហាញឱ្យឃើញពីការផ្លាស់ប្តូរយ៉ាងខ្លាំងលើប្រព័ន្ធអភិបាលកិច្ចសាលារៀន។ សាលាមានការរំលេចកាន់តែច្បាស់នូវតួនាទីវិស័យឯកជន និងរដ្ឋនៅក្នុងដំណើការគ្រប់គ្រង និងអភិវឌ្ឍន៍សាលារៀនជាមួយគ្នា។ អ្វីដែលខុសប្លែកនៅពេលនេះ គឺគំរូអភិបាលកិច្ចត្រូវបានយកមកប្រើប្រាប់យ៉ាងមានប្រសិទ្ធភាពក្នុងកម្មវិធីសាលារៀនជំនាន់ថ្មី។ កិច្ចខិតខំប្រឹងប្រែងនេះក្នុង គោលបំណងដើម្បីធានាថាដំណើរការកម្មវិធីទទួលជោគជ័យក្នុងការអនុវត្ត ។ សាលារៀននឹងក្លាយជាសាលាដែលមានស្វ័យភាពក្នុងការដឹកនាំការងារគ្រប់គ្រង និងជាសាលារៀនដែលមាន គណនេយ្យភាព ហ៊ានទទួលខុសត្រូវលើលទ្ធផលសិក្សាសិស្សយ៉ាងពិតប្រាកដ។ ជាក់ស្តែងនៅក្នុងកម្មវិធីសាលារៀនជំនាន់ថ្មី គឺមានបង្ហាញពីការទាក់ទងជាមួយនឹងគំរូអភិបាលកិច្ចថ្មីចំនួន៥ ដែលជាគោលការណ៍ស្នូលក្នុងការឱ្យនិយមន័យកម្មវិធីសាលារៀនជំនាន់ថ្មីក្នុងនោះរួមមាន (ក្រសួង.អ.យ.ក, ២០២០) (១)ស្តង់ដាថ្មី អភិបាលកិច្ចដោយមានគណនេយ្យភាពតឹងរ៉ឹងនៅក្នុងការបំពេញភារកិច្ច (២)ស្តង់ដាវិជ្ជាជីវៈខ្ពស់ (៣)ស្វ័យភាពក្នុងការប្រតិបត្តិការងារ (៤)ប្រព័ន្ធវាយតម្លៃទទួលស្គាល់គុណភាព និង(៥)ក្របខ័ណ្ឌបែងចែកធនធានប្រកបដោយសនិទានភាព ដែលអនុវត្តន៍ក្នុងកាលៈទេសៈជាក់ស្តែងនៅតាមសាលាគោលដៅ។ បច្ចុប្បន្នកម្មវិធីសាលារៀនជំនាន់ថ្មីទាំងអស់មិនថាកម្រិតបឋម និងមធ្យមសិក្សា ពួកគេបានដំណើរការអនុវត្តខ្ជាប់ខ្ជួនលើគោលការណ៍ស្នូលគំរូអភិបាលកិច្ចថ្មី។

## ២.២០ ការកែទម្រង់កម្រិតសាលារៀន

នៅកម្រិតសាលារៀន ក្រសួងនឹងពង្រឹងការគ្រប់គ្រងតាមសាលារៀនឆ្ពោះទៅលើកកម្ពស់លទ្ធផលសិក្សារបស់សិស្ស និងផ្លាស់ប្តូរវប្បធម៌សាលារៀន ដោយផ្តោតលើ ១). វង្វាយតម្លៃសមត្ថភាពសិស្សតាមរយៈការធ្វើតេស្តដោយតម្លាភាពគាំទ្រដល់ការរៀននិងបង្រៀន និងការរៀបចំថ្នាក់ជួយសិស្សរៀនយឺតផ្តោតលើសិស្សមិនសូវចេះអាន សរសេរ និងគិតលេខ ២). ការបង្កើនគណនេយ្យភាពរបស់សាលារៀនបិទផ្សាយជាសាធារណៈនូវលទ្ធផលតេស្តស្ង់យវាយតម្លៃលទ្ធផលប្រចាំឆ្នាំ ចំណូល ចំណាយរបស់សាលារៀនកម្រិតជាប់ស្តង់ដារបស់សាលារៀន ៣).ការបង្កើនស្វ័យភាព និងសិទ្ធអំណាច ក្នុងការសម្រេចចិត្តនៅកម្រិតសាលារៀន តាមរយៈគណៈកម្មការគ្រប់គ្រងសាលារៀន និងគណៈកម្មការគ្រប់គ្រងថ្នាក់រៀន រៀបចំផែនការកែលម្អសាលារៀន និងថ្នាក់រៀន រៀបចំកិច្ចព្រមព្រាងលទ្ធផលប្រចាំឆ្នាំគ្រូបង្រៀន និងគណៈគ្រប់គ្រងប្រជុំពិនិត្យតាមដានប្រចាំខែ ត្រីមាស ៤). ការបង្កើនការចូលរួមរបស់មាតាបិតា និងភាគីពាក់ព័ន្ធនៅក្នុងការគ្រប់គ្រង និងអភិវឌ្ឍសាលារៀនឱ្យសម្រេចបានជាសាលារៀនគំរូ (ក្រសួង.អ.យ.ក, ២០២៣)។ ក្រសួង អប់រំ យុវជន និងកីឡា (២០២៣) ក៏បានបែងចែកជា៣ប្រភេទផងដែរ សម្រាប់ការកែទម្រង់នៅកម្រិតសាលារៀន ៖

**ប្រភេទទី១ សាលារៀនជំនាន់ថ្មី** ដោយផ្តោតលើការផ្តល់ស្វ័យភាពក្នុងការអនុវត្តកម្មវិធីសិក្សា ដើម្បីបណ្តុះធនធានមនុស្សមានបំណិនសតវត្សទី២១ ក្នុងនោះគណៈគ្រប់គ្រងសាលារៀន និងគ្រូបង្រៀនមាន៖ ក).សីលធម៌ និងស្តង់ដាវិជ្ជាជីវៈខ្ពស់, ខ).គណនេយ្យភាព, នវានុវត្តន៍, គ).ចេះប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន ក្នុងការរៀន និងបង្រៀន, ឃ).ចេះប្រើប្រាស់វិធីសាស្ត្របង្រៀនថ្មី។ សិស្សសាលារៀនជំនាន់ថ្មីមាន៖ ក),ការផ្តួចផ្តើមគំនិត និងសហគ្រិនភាព ខ),ចេះទំនាក់ទំនង និងសរសេរយ៉ាងប៉ិនប្រសប់, គ).ចេះវិភាគវាយតម្លៃព័ត៌មាន, ឃ). ចង់ឃើញ ចង់ដឹង និងមានការស្រមើលស្រមៃ, ច), ចេះគិតបែបវិភាគស៊ីជម្រៅ និងការដោះស្រាយបញ្ហា, ឆ).ចេះសហការ, និងជ).មានភាពរហ័សរហួន និងចេះយកចំណេះដឹងទៅអនុវត្ត។

**ប្រភេទទី២ សាលារៀនគំរូ** ដោយផ្តោតលើ ក).សាលារៀនមានគណនេយ្យភាពជាមួយសហគមន៍ និងសម្រេចបានស្តង់ដាសាលារៀនមានប្រសិទ្ធភាព, ខ).សាលារៀនមានស្វ័យភាពក្នុងការងារផែនការកែលម្អ សាលារៀន ថ្នាក់រៀន និងផ្តល់ការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំដល់គណៈគ្រប់គ្រង និងគ្រូបង្រៀន, គ).សិស្សត្រូវបានធ្វើតេស្តស្តង់ដាប្រកបដោយតម្លាភាព និងយុត្តិធម៌ ដើម្បីបម្រើដល់ការកែលម្អការបង្រៀន និងរៀន, ការជួយសិស្ស រៀនយឺត និងផ្តល់ព័ត៌មានដល់មាតាបិតាឬអ្នកអាណាព្យាបាល និងសហគមន៍ ឃ).គ្រូបង្រៀនប្រើប្រាស់ លទ្ធផលតេស្ត ដើម្បីកែលម្អការបង្រៀន និងទទួលបានការអភិវឌ្ឍគុណវុឌ្ឍិជាប្រចាំ ង),មាតាបិតា ឬអ្នកអាណាព្យាបាលនិងសហគមន៍ចូលរួមគាំទ្រ និងអភិវឌ្ឍសាលារៀន។

**ប្រភេទទី៣ សាលារៀនធម្មតា** ផ្តោតលើ ក).ការកែលម្អលទ្ធផលនៃការសិក្សារបស់សិស្សស្របតាមការរកឃើញនៃលទ្ធផលតេស្តវង្វាយតម្លៃការសិក្សារបស់សិស្សថ្នាក់ជាតិ ថ្នាក់ទី៣ ទី៦ ទី៨ និងទី១១ ខ).ការពង្រឹងវត្តមានគ្រូ និងវត្តមានសិស្ស និង គ).ការពង្រឹងការគ្រប់គ្រងតាមសាលារៀន។

# ជំពូក៣

# វិធីសាស្ត្រស្រាវជ្រាវ

# ជំពូក៣

# វិធីសាស្ត្រស្រាវជ្រាវ

## ៣.១. ព័ត៌មានទូទៅនៃការស្រាវជ្រាវ

ការស្រាវជ្រាវនេះត្រូវបានរៀបចំឡើងដោយប្រើវិធីសាស្ត្រស្រាវជ្រាវបែបបរិមាណវិស័យ ដើម្បីធ្វើការប្រមូលនិងវិភាគទិន្នន័យ និងស្វែងយល់ពីស្ថានភាពនៃការអនុវត្តគោលការណ៍អភិបាលកិច្ចនៅសាលារៀនជំនាន់ថ្មីនៅរាជធានីភ្នំពេញ ។ គោលបំណងនៃការស្រាវជ្រាវគឺសិក្សាស្វែងយល់ពីស្ថានភាពនៃការអនុវត្តគោលការណ៍អភិបាលកិច្ចរបស់សាលារៀនជំនាន់ថ្មីនៅរាជធានីភ្នំពេញ និងសិក្សាពីបញ្ហាប្រឈមនៃការអនុវត្តគោលការណ៍អភិបាលកិច្ច។

## ៣.២. ទីកន្លែងស្រាវជ្រាវ

ដើម្បីឱ្យឆ្លើយតបទៅនឹងប្រធានបទនិក្ខេបបទការសិក្សាស្រាវជ្រាវខាងលើនេះ អ្នកសិក្សាស្រាវជ្រាវបានសម្រេចជ្រើសរើសយករាជធានីភ្នំពេញជាទីតាំងស្រាវជ្រាវ និងការប្រមូលព័ត៌មានទិន្នន័យ។ ហើយត្រូវធ្វើឡើងនៅសាលារៀនជំនាន់ថ្មីចំនួនពីរកន្លែងមានដូចជាៈ  វិទ្យាល័យព្រះស៊ីសុវត្ថិ សាលារៀនជំនាន់ថ្មី និងវិទ្យាល័យព្រែកលៀប ។ មូលហេតុដែលនាំឱ្យអ្នកសិក្សាស្រាវជ្រាវជ្រើសរើសយកវិទ្យាល័យទាំងពីរខាងលើមកសិក្សាព្រោះថាវិទ្យាល័យទាំង២នេះមានទីតាំងឆ្ងាយពីគ្នា វិទ្យាល័យព្រះស៊ីសុវត្ថិ សាលារៀនជំនាន់ថ្មី ស្ថិតនៅចំកណ្តាលនៃរាជធានីភ្នំពេញហើយក៏ជាសាលារៀនជំនាន់ថ្មីដំបូងគេបំផុតនៅកម្ពុជាផងដែរ ចំណែកវិទ្យាល័យព្រែកលៀប សាលារៀនជំនាន់ថ្មីវិញមានទីតាំងស្ថិតនៅជាយរាជធានីភ្នំពេញ ។

## ៣.៣. គម្រោងវិភាគ

ក្នុងនាមជាអ្នកសិក្សាស្រាវជ្រាវ ជាអ្នកអនុវត្តក្នុងកម្មវិធីសាលារៀនជំនាន់ថ្មីផ្ទាល់ សូមអះអាងថាទោះបីអ្នកសិក្សាស្រាវជ្រាវស្ថិតក្នុងកម្មវិធីនោះផ្ទាល់ក៏ដោយក៏រក្សាធ្វើការសិក្សាស្រាវជ្រាវផ្អែកលើនិន្នាការកណ្តាល ។ កម្រងសំណួរដែលអ្នកស្រាវជ្រាវបានដាក់ជូនសាលារៀនជំនាន់ថ្មីទាំងពីរនោះមិនរំលេចនូវអ្វី

បានអនុវត្តល្អៗនោះទេ តែផ្ទុយទៅវិញអ្នកសិក្សាស្រាវជ្រាវបានខិតខំរិះរកចំណុចរួមកណ្ដាលមួយផ្អែកលើគោលការណ៍នៃការអនុវត្តអភិបាលកិច្ច ។

អ្នកស្រាវជ្រាវ បានប្រើប្រាស់កម្រងសំណួរ សម្រាប់ការប្រមូលទិន្នន័យបែបបរិមាណវិស័យ និងប្រភេទកម្រងសំណួរបើកនៃប្រធានបទដែលលើកយកមកសិក្សា ។ ស្របតាមផែនការនៃការបណ្ដុះបណ្ដាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ និងកម្មវិធីសិក្សា ព្រមទាំងនិក្ខេបបទមានរយៈពេលកំណត់ច្បាស់លាស់។ អ្នកស្រាវជ្រាវអាចបញ្ចប់ការសរសេរនិក្ខេបបទ និងឡើងការពារកិច្ចការស្រាវជ្រាវនៅថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០២៣ តាមផែនការដែលបានគ្រោងទុក។ អ្នកសិក្សាស្រាវជ្រាវប្រើប្រាស់ការអនុវត្តការចុះប្រមូលទិន្នន័យដោយប្រើប្រាស់វិធីសាស្ត្របែបបរិមាណវិស័យ និងប្រើប្រាស់ប្រភេទកម្រងសំណួរបើកដោយរៀបចំព័ត៌មានកំណត់ខ្លឹមសារ និងសំយោគក្របខណ្ឌនៃគោលគំនិតរួមសំខាន់ៗ ( Main Indicators) ។ ការប្រមូលទិន្នន័យតាមបែបបរិមាណវិស័យ គឺធ្វើនៅសាលារៀនជំនាន់ថ្មីចំនួនពីរគឺវិទ្យាល័យព្រែកលៀប និងវិទ្យាល័យព្រះស៊ីសុវត្ថិ ពីគណៈគ្រប់គ្រងសាលារៀន លោកគ្រូអ្នកគ្រូដែលបាននឹងកំពុងបង្រៀនតាមមុខវិជ្ជា ។ រីឯកម្រងសំណួរបែបប្រភេទកម្រងសំណួរបើកវិញគឺធ្វើការសម្ភាសន៍ពីរភាគីគឺ គ្រូបង្រៀនចំនួន១៥នាក់ និងគណៈគ្រប់គ្រងសាលារៀនចំនួន០២នាក់ ។

## ៣.៤. ការប្រមូលទិន្នន័យ

អ្នកស្រាវជ្រាវប្រើវិធីសាស្ត្រប្រមូលទិន្នន័យតាមបែបបរិមាណវិស័យ ដោយប្រើប្រាស់ Google Form ជាកម្រងសំណួរជំនួសដោយការប្រើប្រាស់ការថតចម្លង ( Hard Copy) ជូនលោកគ្រូអ្នកគ្រូដើម្បីបំពេញ។ មួយវិញទៀតដោយឃើញថាសាលារៀនជំនាន់ថ្មីទាំងពីរជាសាលារៀនបែបសតវត្សទី២១ គឺលោកគ្រូអ្នកគ្រូទាំងអស់សុទ្ធតែមានកុំព្យូទ័រផ្ទាល់ខ្លួនដើម្បីប្រើប្រាស់ ដូចនេះទើបងាយស្រួលក្នុងការបំពេញកម្រងសំណួរដោយប្រើប្រាស់ Google Form នេះ ។ ក្នុងនោះដែរការប្រមូលទិន្នន័យនេះគឺក្នុងអំឡុងពេលសាលារៀនទាំងពីរមានការប្រជុំផ្ទាល់នៅសាលារៀន ។ អ្នកស្រាវជ្រាវ បានសុំការអនុញ្ញាតពី

គណៈគ្រប់គ្រងសាលារៀនរយៈពេល ១៥នាទី ដើម្បីណែនាំដល់លោកគ្រូអ្នកគ្រូឱ្យបំពេញកម្រងសំណួរតាម Google Form និងពន្យល់ពីចំណុចមួយចំនួននៅក្នុងកម្រងសំណួរនោះ ។

អ្នកស្រាវជ្រាវប្រើវិធីសាស្ត្រប្រមូលទិន្នន័យតាមប្រភេទកម្រងសំណួរបើក ដោយអ្នកស្រាវជ្រាវបានខលណាត់ជួប និងទំនាក់ទំនងតាមប្រព័ន្ធ Telegram ជាមួយគណៈគ្រប់គ្រងទាំងពីរសាលារៀន ដែលគាត់មានពេលវេលាដើម្បីផ្តល់ឱកាសឱ្យអ្នកស្រាវជ្រាវបានធ្វើការសម្ភាន៍ផ្ទាល់ជាមួយគ្នា ។ ការសម្ភាសន៍នេះជាមធ្យោបាយក្នុងការពង្រីក និងរំលេចចេញនូវរឿងរ៉ាវនានាដែលពាក់ព័ន្ធបញ្ហាប្រឈមក្នុងការអនុវត្តគោលការណ៍អភិបាលកិច្ចនៅក្នុងសាលារៀនជំនាន់ថ្មី ។ វិធីសាស្ត្រមួយចំនួននៃការប្រមូលទិន្នន័យត្រូវបានប្រើប្រាស់ក្នុងការសម្ភាន៍គឺសុំការអនុញ្ញាតក្នុងការថតជាសម្លេងរបស់គាត់ទាំងពីរនាក់ ដោយការសន្ទនានោះប្រកបដោយវិជ្ជាជីវៈ និងធ្វើការកត់ត្រា។

## ៣.៥. ឧបករណ៍នៃការស្រាវជ្រាវ

ដើម្បីប្រមូលទិន្នន័យបានជាក់លាក់ អ្នកស្រាវជ្រាវបានបង្កើតកម្រងសំណួរចំនួន ២ប្រភេទ ។ អ្នកស្រាវជ្រាវប្រើប្រាស់កម្រងសំណួរបែបទម្រង់ Google Form សម្រាប់ជាឧបករណ៍ប្រមូលទិន្នន័យក្នុងការស្រាវជ្រាវដែលអាចទាញទិន្នន័យយកមកប្រើប្រាស់បានស្រួលបន្ទាប់ពីលោកគ្រូអ្នកគ្រូបានធ្វើការបំបេញកម្រងសំណួរនោះ ។ កម្រងសំណួរទី១ គឺសម្រាប់គណៈគ្រប់គ្រងសាលារៀន និងកម្រងសំណួរទី២ គឺសម្រាប់លោកគ្រូអ្នកគ្រូ ដែលកំពុងបង្រៀនតាមមុខវិជ្ជា។

ដើម្បីឱ្យការរៀបចំកម្រងសំណួរស្របទៅនឹងប្រធានបទ គោលបំណងស្រាវជ្រាវ និងធានាឱ្យកម្រងសំណួរមានភាពច្បាស់លាស់ អ្នកស្រាវជ្រាវបានរៀបចំកម្រងសំណួរដោយផ្អែកទៅលើទ្រឹស្តីដែលពាក់ព័ន្ធនិងរៀបចំឡើងដោយអ្នកស្រាវជ្រាវយោងតាមឯកសារ ការគ្រប់គ្រង និងភាពជាអ្នកដឹកនាំសម្រាប់បំប៉ននាយកសាលាបឋមសិក្សា និងមធ្យមសិក្សា (ក្រសួងអ.យ.ក, ២០១៦b) ដូចជា ៖ អភិបាលកិច្ចសាលារៀន ត្រូវបានបែងចែកជាបួនគឺ **(១) តម្លាភាព (២) គណនេយ្យភាព (៣) ការចូលរួម និង(៤)នីតិរដ្ឋ** ។

### ៣.៥.១ កម្រិតចង្អុលបង្ហាញ

អ្នកស្រាវជ្រាវបានប្រើកម្រិតចង្អុលបង្ហាញ គឺប្រើប្រាស់ទម្រង់កម្រងសំណួរដើម្បីចុះប្រមូលទិន្នន័យពីភាគីពាក់ព័ន្ធ ទៅតាមការឆ្លើយតបក្នុងកម្រិតតួលេខជាក់លាក់ ។ កម្រិតចង្អុលបង្ហាញអាចបំពេញតាមអនឡាញ (Google Form) ទៅលើកម្រងសំណួរលើប្រធានបទអ្នកស្រាវជ្រាវ ។ ក្នុងការសិក្សាស្រាវជ្រាវលើប្រធានបទខាងលើ គឺមានកម្រិតចង្អុលបង្ហាញចំនួន៥កម្រិត។ តួលេខចង្អុលបង្ហាញតាមបែប Likert Scale គឺនិយមចូលចិត្តប្រើច្រើនលើនិក្ខេបបទស្រាវជ្រាវក្នុងវិស័យអប់រំ។ តួលេខចង្អុលបង្ហាញគឺប្រើប្រាស់ដើម្បីវាស់សូចនាករ **វាយតម្លៃលើកម្រិតនៃការអនុវត្ត** និងដំណើរការបំពេញការងាររបស់គ្រូបង្រៀន និងគណៈគ្រប់គ្រងសាលារៀន ។

ក្នុងការសិក្សាស្រាវជ្រាវនេះ កម្រិតចចង្អុលបង្ហាញនៃកម្រងសំណួរនីមួយៗ មាន៥កម្រិតពីទាបបំផុត (១) ទៅខ្ពស់បំផុត (៥) ។ រូបមន្តនៃកម្រិតចង្អុលបង្ហាញមានដូចខាងក្រោម៖

| | | | |
|---|---|---|---|
| ១ | គឺ | (Never) | មិនដែល |
| ២ | គឺ | (Rarely) | កម្រ |
| ៣ | គឺ | (Sometimes) | ពេលខ្លះ |
| ៤ | គឺ | (Very Often) | ជាញឹកញាប់ |
| ៥ | គឺ | (Always) | ជានិច្ចកាល |

ការបកស្រាយទៅលើការគណនាពិន្ទុ ពីការប្រមូលទិន្នន័យ ដម្បីវិភាគលើពិន្ទុមធ្យមភាគនៃសូចនាករនីមួយៗ គឺមានរូបមន្ត Best (1981) ដូចខាងក្រោម៖

$$\frac{\text{Highest Score - Lowest Score}}{\text{No. of Levels}} = \frac{5\ -\ 1}{5} = \frac{4}{5} = 0.80$$

តារាង 3 ៣.៥.១ Frequency Likert scale

| Frequency Likert scale | Performance Level | កម្រិតអនុវត្តន៍ | មធ្យម |
|---|---|---|---|
| 1 = Never | No performance | មិនអនុវត្ត | 1.00 – 1.22 |
| 2 = Rarely | Low performance | អនុវត្តនៅទាប | 1.23 – 2.28 |
| 3 = Sometimes | Moderate Performance | អនុវត្តមធ្យម | 2.29 – 3.74 |
| 4 = Very Often | High Performance | អនុវត្តខ្ពស់ | 3.75 – 4.74 |
| 5 = Always | Very High Performance | អនុវត្តខ្ពស់បំផុត | 4.75 – 5.00 |

### ៣.៥.២ កម្រងសំណួរ

គោលបំណងនៃកម្រងសំណួរនេះ គឺដើម្បីស្វែងយល់ពីកម្រិតនៃការការអនុវត្តគោលការណ៍អភិបាលកិច្ចសាលារៀនទាំងបួនរួមមាន តម្លាភាព គណនេយ្យភាព នីតិរដ្ឋ និងការចូលរួម និងសិក្សាពីបញ្ហាប្រឈមនៃការអនុវត្តគោលការណ៍អភិបាលកិច្ចសាលារៀននេះ។ ទិន្នន័យប្រមូលបានពីកម្រងសំណួរនេះ មានគោលបំណងយកទៅប្រើប្រាស់ដើម្បីវិភាគកែលម្អ និងលើកកម្ពស់ការអនុវត្តគោលការណ៍អភិបាលកិច្ចសាលារៀនរបស់សាលារៀនជំនាន់ថ្មី ។ ទិន្នន័យដែលប្រមូលបានគឺប្រើប្រាស់សម្រាប់តែការសិក្សាស្រាវជ្រាវតែប៉ុណ្ណោះ។

#### ៣.៥.២.១ កម្រងសំណួរសម្រាប់គណៈគ្រប់គ្រង

កម្រងសំណួរសម្រាប់គណៈគ្រប់គ្រង ត្រូវប្រើប្រាស់សម្រាប់នាយក និងនាយករង /នាយិការង ដែលចែកចេញជា ៣ផ្នែកគឺ៖

**ផ្នែកទី១៖ ព័ត៌មានទូទៅ និងគុណវុឌ្ឍិគណៈគ្រប់គ្រង**

មាន៧សំណួរ គឺអង្គភាពបម្រើការងារ តួនាទី(នាយក នារយករង នាយិការង) ភេទ អាយុ បទពិសោធន៍ការងារ កម្រិតវប្បធម៌ចុងក្រោយ និងក្របខណ្ឌ។

**ផ្នែកទី២៖ ការអនុវត្តអភិបាលកិច្ចតាមសាលារៀន**

មានសមាសភាគចំនួន៤គឺ៖ (១)តម្លាភាព (មាន៩សំណួរ) (២)គណនេយ្យភាពសាលារៀន (មាន១៤សំណួរ) (៣)នីតិរដ្ឋ(មាន៨សំណួរ) និង(៤)ការចូលរួម (មាន៩សំណួរ)

**ផ្នែកទី៣ បញ្ហាប្រឈមនៃការអនុវត្តអភិបាលកិច្ចសាលារៀន**

ក្នុងផ្នែកទី៣នេះជាទម្រង់សំណួរបែបសម្ភាសន៍ សម្រាប់ធ្វើការសម្ភាសន៍គណៈគ្រប់គ្រងសាលារៀនដោយផ្ទាល់អំពីបញ្ហាប្រឈម នៃការអនុវត្តគោលការណ៍អភិបាលកិច្ចសាលារៀន មានចំនួន១០សំណួរ ។

### ៣.៥.២.២ កម្រងសំណួរសម្រាប់គ្រូបង្រៀន

កម្រងសំណួរសម្រាប់គណៈគ្រប់គ្រង ត្រូវប្រើប្រាស់សម្រាប់នាយក និងនាយករង /នាយិការង ដែលចែកចេញជា ៣ផ្នែកគឺ៖

**ផ្នែកទី១៖ ព័ត៌មានទូទៅ និងគុណវុឌ្ឍិគណៈគ្រប់គ្រង**

មាន៧សំណួរ គឺអង្គភាពបម្រើការងារ តួនាទី( នាយក នារយករង នាយិការង) ភេទ អាយុ បទពិសោធន៍ការងារ កម្រិតវប្បធម៌ចុងក្រោយ និងក្របខណ្ឌ។

**ផ្នែកទី២៖ ការអនុវត្តអភិបាលកិច្ចតាមសាលារៀន**

មានសមាសភាគចំនួន៤គឺ៖ (១)តម្លាភាព (មាន៩សំណួរ) (២)គណនេយ្យភាពសាលារៀន (មាន១៤សំណួរ) (៣)នីតិរដ្ឋ(មាន៨សំណួរ) និង(៤)ការចូលរួម (មាន៩សំណួរ)

**ផ្នែកទី៣ បញ្ហាប្រឈមនៃការអនុវត្តអភិបាលកិច្ចសាលារៀន**

ក្នុងផ្នែកទី៣នេះជាទម្រង់សំណួរបែបសម្ភាសន៍ សម្រាប់ធ្វើការសម្ភាសន៍គ្រូបង្រៀនចំនួន១៥នាក់ ដោយផ្ទាល់អំពីបញ្ហាប្រឈម នៃការអនុវត្តគោលការណ៍អភិបាលកិច្ចសាលារៀន មានចំនួន៤សំណួរ ។

## ៣.៦. ការជ្រើសរើសសំណាក

ការប្រមូលទិន្នន័យ តាមបែបបរិមាណវិស័យ គឺធ្វើឡើងនៅសាលារៀនជំនាន់ថ្មីចំនួនពីរ នៅក្នុងទីក្រុងភ្នំពេញ គឺវិទ្យាល័យព្រះស៊ីសុវត្ថិ សាលារៀនជំនាន់ថ្មី និងវិទ្យាល័យព្រែកលៀប សាលារៀនជំនាន់ថ្មី។ ការវិភាគទិន្នន័យ សិក្សាលើចំនួនភាគរយតាមអថេរនីមួយៗ ចំនួនមធ្យមភាគនៃសូចនាករតាមផ្នែក និងគម្លាតស្តង់ដា ចំពោះកម្រិតចង្អុលបង្ហាញមានចំនួន៥កម្រិតដោយគណនាតាមរូបមន្តកំណត់ជាក់លាក់ ។

ចំណែកការប្រមូលទិន្នន័យ តាមបែបប្រភេទកម្រងសំណួរបើក គឺធ្វើឡើងតាមរយៈការសម្ភាសន៍គណៈគ្រប់គ្រង និងលោកគ្រូអ្នកគ្រូដើម្បីរកពីបញ្ហាប្រឈមនៃការអនុវត្ត។ ការវិភាគទិនន័យគឺតាមរយៈការរៀបចំរៀបចំព័ត៌មានកំណត់ខ្លឹមសារ និងសំយោគក្របខណ្ឌនៃគោលគំនិតរួមសំខាន់ៗ ( Main Indicators ) ដោយសំណួរនិងចម្លើយត្រូវបានផ្តោតលើគោលនៅអភិបាលកិច្ចសាលារៀន គឺតម្លាភាព គណនេយ្យភាព នីតិរដ្ឋ និងការចូលរួម។

ចំនួនសំណាកក្នុងការប្រមូលទិន្នន័យ តាមរយៈកម្រងសំណួរ បានជ្រើសសរើសសាលាចំនួន២គឺ វិទ្យាល័យព្រះស៊ីសុវត្ថិ សាលារៀនជំនាន់ថ្មី និងវិទ្យាល័យព្រែកលៀប មានសំណាក់សរុបចំនួន ១១៧នាក់ ដែលបែងចែកជា គណៈគ្រប់គ្រងចំនួន០៦នាក់ គ្រូបង្រៀនចំនួន១១១នាក់ ដោយប្រើរូបមន្តតាមបែប Rea L.M. et al., 1997. ។

$$n = \frac{t_p^2 \times P(1 - P) \times N}{t_p^2 \times P(1 - P) + (N-1) \times y^2}$$

n= ចំនួនសំណាក
N= ចំនួនសរុប
P=សមាមាត្រំរំពឹងទុកនៃការឆ្លើយតប ឬសមមាត្រជាក់ស្តែង
tp=គំរូរំពឹងទុក
y=កំហុសគំរូ

តាមរូបមន្តខាងលើអ្នកស្រាវជ្រាវអាចទាញបានដូចខាងក្រោម

ដោយ N = 209 នាក់

P = 50% = 0.5

tp= 1.65

y=5% = 0.05

$$n = \frac{1.65^2\ X\ 0.5(1-0.5)\ X\ 209}{1.65^2\ X\ 0.5(1-0.5) + (209-1)\ X\ 0.05^2} = 117$$ នាក់

ដូចនេះចំនួនភាគសំណាកដែលបានដែលត្រូវជ្រើសរើស គឺ n=១១៧នាក់

តារាង 4 ៣.៦. ការជ្រើសរើសសំណាក

| ល.រ | ឈ្មោះវិទ្យាល័យ | បុគ្គលិកសរុប | ស្រី | ចំនួនសំណាកបានជ្រើសរើស | | | |
|---|---|---|---|---|---|---|---|
| | | | | គណៈគ្រប់គ្រង | ស្រី | គ្រូបង្រៀន | ស្រី |
| ១ | វិទ្យាល័យព្រះស៊ីសុវត្ថិ | ១១៧នាក់ | ៥៩នាក់ | ០៣នាក់ | ០១នាក់ | ៧០នាក់ | ៣៦នាក់ |
| ២ | វិទ្យាល័យព្រែកលៀប | ៩២នាក់ | ៣១នាក់ | ០៣នាក់ | ០១នាក់ | ៤១នាក់ | ១៧នាក់ |
| | **សរុប** | **២០៩នាក់** | **៩០នាក់** | **០៦នាក់** | **០២នាក់** | **១១១នាក់** | **៥៣នាក់** |
| **សរុបចំនួនសំណាក់សរុប** | | | | **១១៧នាក់** | | | |

ដោយប្រើចម្លើយដែលបានមកពីការបំពេញកម្រងសំណួរ គណៈគ្រប់គ្រងសាលារៀន និងលោកគ្រូអ្នកគ្រូបង្រៀន អ្នកស្រាវជ្រាវយកទិន្នន័យដែលបាននោះមកធ្វើការវិភាគដោយប្រើប្រាស់វិធីសាស្ត្រវិភាគទិន្នន័យបែបបរិមាណវិស័យ ដោយប្រើប្រាស់កម្មវិធី Microsoft Excel ដើម្បីរកភាគរយ មធ្យម និងគម្លាតស្តង់ដា។

## ៣.៧. ការវិភាគទិន្នន័យ

ការវិភាគទិន្នន័យ សិក្សាលើចំនួនភាគរយតាមអថេរនីមួយៗ និងចំនួនមធ្យមភាគនៃសូចនាករតាមផ្នែកនីមួយៗ និងកម្រិតចង្អុលបង្ហាញចំនួន៥កម្រិតដោយគណនាតាមរូបមន្តកំណត់ជាក់លាក់។ អ្នកស្រាវជ្រាវបានប្រើប្រាស់នូវកម្រងសំណួរដែលមានលក្ខណៈជាពហុជ្រើសរើសទៅតាមកម្រិតចង្អុលបង្ហាញនីមួយៗក្នុងទម្រង់បិទ និងសម្ភាស៍គណៈគ្រប់គ្រងចំនួន២នាក់ និងលោកគ្រូអ្នកគ្រូចំនួន១៥នាក់ ដើម្បីរកពីបញ្ហាប្រឈមនៃការអនុវត្តគោលការណ៍អភិបាលកិច្ចសាលារៀន ។ អ្នកស្រាវជ្រាវ បានប្រើប្រាស់កម្មវិធីវិភាគទិន្នន័យ Microsoft Excel ដើម្បីសិក្សាពីភាគរយ ពិន្ទុមធ្យម និងគម្លាតស្តង់ដា ដើម្បីបកស្រាយទិន្នន័យតាមសូចនាករនីមួយៗ។ ចំពោះការវិភាគលើសំណួរដែលបានសម្ភាសន៍វិញ អ្នកស្រាវជ្រាវវិភាគទិន្នន័យគឺតាមរយៈការរៀបចំរៀបចំព័ត៌មានកំណត់ខ្លឹមសារ និងសំយោគក្របខណ្ឌនៃគោលគំនិតរួមសំខាន់ៗ (Main Indicators) ដោយសំណួរនិងចម្លើយត្រូវបានផ្តោតលើគោលការណ៍នៅអភិបាលកិច្ចសាលារៀនទាំងបួន គឺ(១)តម្លាភាព (២)គណនេយ្យភាព (៣)នីតិរដ្ឋ (៤)ការចូលរួម។

# ជំពូក៤

# លទ្ធផល និងការពិភាក្សា

# ជំពូក៤

# លទ្ធផល និងការពិភាក្សា

ក្នុងជំពូកនេះ៤នេះ អ្នកស្រាវជ្រាវនឹងបង្ហាញពីលទ្ធផលនៃការវិភាគទិន្នន័យ ធ្វើការបកស្រាយនិងពិភាក្សា នូវអ្វីដែលត្រូវបានរកឃើញតាមរយៈការបំពេញកម្រងសំណួរ និងសម្ភាសន៍ផ្ទាល់អំពីក្រុមគោលដៅដែលពាក់ព័ន្ធ រួមមាន ៖ គណៈគ្រប់គ្រង និងគ្រូបង្រៀន។ រាល់ចំណុចសំខាន់ៗមួយចំនួនដែលទាក់ទងនឹងស្ថានភាពនៃការអនុវត្តអភិបាលកិច្ចនៅសាលារៀនជំនាន់ថ្មី រួមមាន តម្លាភាព គណនេយ្យភាព នីតិរដ្ឋ និងការចូលរួម នាពេលកន្លងមកត្រូវបានយកមកបកស្រាយ និងពិភាក្សា។

## ៤.១. ទិន្នន័យពីព័ត៌មានទូទៅរបស់គណៈគ្រប់គ្រង និងគ្រូបង្រៀន

ក្នុងការសិក្សាស្រាវជ្រាវនេះ អ្នកស្រាវជ្រាវបានយកសាលារៀនជំនាន់ថ្មីចំនួនពីរ ដែលស្ថិតក្នុងរាជធានីភ្នំពេញរួមមាន ៖ វិទ្យាល័យព្រះស៊ីសុវត្ថិ (NGS) និងវិទ្យាល័យព្រែកលៀប (NGS)។

### ៤.១.១. ព័ត៌មានទូទៅរបស់គណៈគ្រប់គ្រប់គ្រង

ក្រាប 1 ព័ត៌មានទូទៅរបស់គណៈគ្រប់គ្រប់គ្រង




តាមរយៈទិន្នន័យទទួលបានពីគណៈគ្រប់គ្រងលើព័ត៌មានទូទៅ ក្នុងក្រាបខាងលើបង្ហាញថា គណៈគ្រប់គ្រងសរុបចំនួន០៦នាក់ ដែលក្នុងនោះ ១៦.១៧% មានតួនាទីជានាយក រីឯ៥០.០០%ទៀត

មានតួនាទីជានាយករង និង ៣៣.៣៣% មានតួនាទីជានាយិការង ។ ក្នុងនោះដែរកម្រិតវប្បធម៌នៃគណៈគ្រប់គ្រងសុទ្ធតែមាន បរិញ្ញាបត្រជាន់ខ្ពស់ និងជាគ្រូកម្រិតឧត្តមចំនួន១០០% ។

ក្រាប 2 បទពិសោធន៍ការងារគណៈគ្រប់គ្រង




ចំពោះបទពិសោធន៍ក្នុងវិស័យអប់រំវិញ ៥០% ចន្លោះពី១៦ ទៅ២០ឆ្នាំ ជាគណៈគ្រប់គ្រងវិទ្យាល័យព្រែកលៀប និង ៥០% លើសពី២០ឆ្នាំ ជាគណៈគ្រប់គ្រងវិទ្យាល័យព្រះស៊ីសុវត្ថិនៃចំនួនសរុប ០៦នាក់ ។

### ៤.១.២. ព័ត៌មានទូទៅរបស់គ្រូបង្រៀន

ក្រាប 3 ក្របខណ្ឌគ្រូបង្រៀន



តាមរយៈទិន្នន័យទទួលបានពីគ្រូបង្រៀនលើព័ត៌មានទូទៅ ក្នុងក្រាបខាងលើ បានបង្ហាញថា គ្រូបង្រៀនភាគច្រើនជាគ្រូបង្រៀនកម្រិតឧត្តមដែលមានចំនួន ៨៣.៧៨% ហើយក្រៅពីនោះជាគ្រូបង្រៀនកម្រិតមូលដ្ឋាន ១៦.២២% នៃចំនួនសរុប ១១១នាក់ ។

ក្រាប 4 អាយុគ្រូបង្រៀន




ចំពោះអាយុវិញគ្រូបង្រៀននៅសាលារៀនជំនាន់ថ្មីទាំងពីរសាលា គឺសុទ្ធសឹងតែគ្រូដែលមានវ័យអាយុ ចន្លោះពី២០ទៅ ៣០ឆ្នាំ មានចំនួន ៦២.១៦% និងក្រៅពីនេះគឺមានអាយុ ចន្លោះពី៣១ ទៅ ៤០ឆ្នាំ មានចំនួន៣៣.៣៣% ។ ទាំងនេះសបញ្ជាក់ឱ្យឃើញថាគ្រូបង្រៀននៅសាលារៀនជំនាន់ថ្មីជាគ្រូដែលមានវ័យ ចន្លោះពី២០ ទៅ៣០ឆ្នាំ។

ក្រាប 5 បទពិសោធន៍ការងាររបស់គ្រូបង្រៀន



ចំពោះបទពិសោធន៍ការងារជាគ្រូបង្រៀនរបស់គ្រូបង្រៀនសាលារៀនជំនាន់ថ្មីទាំងពីរបានបង្ហាញថាគ្រូមានបទពិសោធន៍ភាគច្រើនគឺ ក្រោម៥ឆ្នាំ មានចំនួន ៤៥.០៥% និងបទពិសោធន៍ពី ៥ទៅ១៥ឆ្នាំ មានចំនួន៤៥.០៥% ហើយភាគតិចបទពិសោធន៍ ចន្លោះពី១៦ ដល់២០ឆ្នាំ មានចំនួន៣.៦០% និងបទពិសោធន៍លើសពី២០ឆ្នាំ មានចំនួន៦.៣១% នៃចំនួនសរុប១១១នាក់។

ក្រាប 6 កម្រិតអប់រំចុងក្រោយរបស់គ្រូបង្រៀន




ចំពោះកម្រិតវប្បធម៌មានគ្រូបង្រៀនភាគច្រើនមានសញ្ញាបត្របរិញ្ញាបត្រមានចំនួន ៧២.៩៧% និងបរិញ្ញាបត្រជាន់ខ្ពស់មានចំនួន ១៨.៩២% និងភាគតិចមានសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិមានចំនួន៧.២១% នៃចំនួនសរុប១១១នាក់ ។

## ៤.២. លទ្ធផលឆ្លើយតបរបស់គ្រូបង្រៀន

### ១. តម្លាភាពសាលារៀន

| ល.រ | បរិយាយ | មធ្យម | គម្លាតស្តង់ដា | កម្រិតការអនុវត្តន៍ |
|---|---|---|---|---|
| ១ | សាលារៀនបានធ្វើការផ្សព្វផ្សាយតារាងតម្លាភាពនៃ *ថវិកាចំណូល* នឹងត្រូវបានបិទផ្សាយនៅចុងខែនីមួយៗប្រចាំខែ | 3.65 | 1.08 | អនុវត្តមធ្យម |
| ២ | សាលារៀនបានធ្វើការផ្សព្វផ្សាយតារាងតម្លាភាពនៃ *ថវិកាចំណាយ* នឹងត្រូវបានបិទផ្សាយនៅចុងខែនីមួយៗប្រចាំខែ | 3.61 | 1.11 | អនុវត្តមធ្យម |
| ៣ | ការចុះឈ្មោះចូលរៀនរបស់សិស្សក្នុងសាលារៀនជំនាន់ថ្មីបានផ្សព្វផ្សាយទៅកាន់សាធារណៈជនទូទៅ | 4.62 | 0.59 | អនុវត្តខ្ពស់ |

| | | | | |
|---|---|---|---|---|
| ៤ | សាលាបានផ្សព្វផ្សាយរាល់ការប្រឡងជ្រើសរើសសិស្សអាហាររូបករណ៍ក្នុងស្រុក និងក្រៅស្រុកទៅកាន់សិស្ស និងអាណាព្យាបាល | 4.50 | 0.57 | អនុវត្តខ្ពស់ |
| ៥ | តារាងពិន្ទុប្រចាំខែ ប្រចាំឆមាស និងប្រចាំឆ្នាំតាមមុខវិជ្ជាគោលនីមួយៗបានផ្សព្វផ្សាយទៅកាន់សិស្ស អ្នកអាណាព្យាបាល និងសហគមន៍ | 4.62 | 0.51 | អនុវត្តខ្ពស់ |
| ៦ | សាលាបានឆ្លើយតបរាល់បញ្ហាប្រកបដោយទំនួលខុសត្រូវទៅកាន់អាណាព្យាបាលសិស្ស | 4.43 | 0.55 | អនុវត្តខ្ពស់ |
| ៧ | សាលាបានធ្វើការប្រជុំផ្សព្វផ្សាយពីការសិក្សារបស់សិស្សទៅកាន់អាណាព្យាបាលរៀងរាល់មួយឆ្នាំម្តង | 4.47 | 0.72 | អនុវត្តខ្ពស់ |
| ៨ | ការបែងចែកថវិកាសាលារៀនដែលបានពីការធ្វើផែនការដើមឆ្នាំឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែងរបស់សាលារៀន | 4.23 | 0.71 | អនុវត្តខ្ពស់ |
| ៩ | សាលាបានឆ្លើយតបនូវសំណើរទិញសម្ភារៈបង្រៀន សម្ភារៈពិសោធន៍ ចាំបាច់របស់គ្រូបង្រៀន | 4.07 | 0.75 | អនុវត្តខ្ពស់ |
| **សរុប** | | **4.25** | 0.84 | អនុវត្តខ្ពស់ |

យោងតាមលទ្ធផលនៃការស្រាវជ្រាវដូចមានក្នុងតារាងខាងលើបានបង្ហាញថា ការអនុវត្តគោលការណ៍អភិបាលកិច្ចរបស់គ្រូបង្រៀន នៅសាលារៀនជំនាន់ថ្មី វិទ្យាល័យព្រះស៊ីសុវត្ថិ និងវិទ្យាល័យព្រែកលៀប ត្រង់ចំណុចទី១ "**តម្លាភាព**" បានឆ្លើយតបទៅលើការអនុវត្ត ក្នុងកម្រិត "អនុវត្តខ្ពស់" (មធ្យមភាគពិន្ទុសរុប=៤.២៥ និងមានគម្លាតស្តង់ដា=០.៨៤)។ សូចនាករដែលបានពិន្ទុខ្ពស់ជាងគេគឺ សូចនាករទី៣ "ការចុះឈ្មោះចូលរៀនរបស់សិស្សក្នុងសាលារៀនជំនាន់ថ្មីបានផ្សព្វផ្សាយទៅកាន់សាធារណៈជនទូទៅ" ក្នុងកម្រិត "អនុវត្តខ្ពស់" (មធ្យមភាគពិន្ទុ=៤.៦២ មានគម្លាតស្តង់ដា=០.៥៩) និងសូចនាករទី៥ "តារាងពិន្ទុប្រចាំខែ ប្រចាំឆមាស និងប្រចាំឆ្នាំតាមមុខវិជ្ជាគោលនីមួយៗបានផ្សព្វផ្សាយទៅកាន់សិស្ស អ្នកអាណាព្យាបាល និងសហគមន៍" ក្នុងកម្រិត "អនុវត្តខ្ពស់" (មធ្យមភាគពិន្ទុ=៤.៦២ មានគម្លាតស្តង់ដា=០.៥១)។

តាមតារាងខាងលើដដែល បើយើងពិនិត្យមើលពិន្ទុមធ្យមភាគរបស់ទិន្នន័យឃើញថាសូចនាករដែលមានមធ្យមភាគពិន្ទុទាបជាងគេគឺ សូចនាករទី១ "សាលារៀនបានធ្វើការផ្សព្វផ្សាយតារាងតម្លាភាពនៃ*ថវិកាចំណូល*នឹងត្រូវបានបិទផ្សាយនៅចុងខែនីមួយៗប្រចាំខែ" ឃើញថាមាន (ធម្យមភាគពិន្ទុ=៣.៦៥ និងមានគម្លាតស្តង់ដា=១.០៨) ស្ថិតក្នុង "**កម្រិតអនុវត្តមធ្យម**" និងសូចនាទី២ "សាលារៀន

បានធ្វើការផ្សព្វផ្សាយតារាងតម្លាភាពនៃ *ថវិកាចំណាយ* នឹងត្រូវបានបិទផ្សាយនៅចុងខែនីមួយៗប្រចាំខែ" ឃើញថាមាន (មធ្យមភាគពិន្ទុ=៣.៦១ និងមានគម្លាតស្តង់ដា=១.១១) ស្ថិតក្នុង កម្រិត "អនុវត្តមធ្យម" ដូចសូចនាករទី១ដែរ ។ ទោះបីជាសូចនាករដែលមានមធ្យមភាគពិន្ទុខ្ពស់ជាងគេ និងទាបជាងគេយ៉ាងណាដោយក៏ស្ថិតក្នុងកម្រិតមួយនៃការអនុវត្តខ្ពស់ដដែល។

## ២. គណនេយ្យភាពសាលារៀន

| ល.រ | បរិយាយ | មធ្យម | គម្លាតស្តង់ដា | កម្រិតការអនុវត្តន៍ |
|---|---|---|---|---|
| **ក. គណនេយ្យភាពពីដំណើរការសាលារៀន** | | | | |
| ១០ | បុគ្គលិក គ្រូបង្រៀន បំពេញភារកិច្ចបង្រៀនទៀតទាត់ពេលវេលា | 4.57 | 0.52 | អនុវត្តខ្ពស់ |
| ១១ | គ្រូបង្រៀនបានបំពេញតាមបទដ្ឋានសាលារៀនជំនាន់ថ្មី | 4.54 | 0.55 | អនុវត្តខ្ពស់ |
| ១២ | សាលាមានគណនេយ្យភាពទៅកាន់សិស្សក្នុងការរៀបចំការប្រឡង និងការកែកិច្ចការដោយមិនលម្អៀងតាមរបបពិន្ទុ | 4.62 | 0.52 | អនុវត្តខ្ពស់ |
| ១៣ | សាលារៀនមានគណនេយ្យភាពចំពោះក្រសួង លើគុណភាពនៃការអប់រំ (ផ្អែកតាមនិយាម) | 4.52 | 0.54 | អនុវត្តខ្ពស់ |
| ១៤ | សាលាបានអនុវត្តផែនការកែលម្អសាលារៀន ស្របតាមថវិកាប្រចាំឆ្នាំ | 4.38 | 0.60 | អនុវត្តខ្ពស់ |
| ១៥ | សាលាមានចំណូលគ្រប់គ្រាន់ក្នុងការទ្រទ្រង់ដំណើរការសាលារៀន | 4.42 | 0.61 | អនុវត្តខ្ពស់ |
| សរុប | | **4.51** | 0.56 | អនុវត្តខ្ពស់ |
| **ខ. គណនេយ្យភាពសិក្សា** | | | | |
| ១៦ | សាលាបានឱ្យសិស្សវាយតម្លៃគ្រូរបស់ខ្លួនគ្រប់មុខវិជ្ជា | 4.11 | 1.15 | អនុវត្តខ្ពស់ |
| ១៧ | សាលាមានគណនេយ្យភាពចំពោះរដ្ឋបាលមូលដ្ឋាន ជាពិសេសសិស្ស និងអាណាព្យាបាលលើគុណភាពនៃការរៀនតាមនិយាម | 4.32 | 0.57 | អនុវត្តខ្ពស់ |
| ១៨ | សាលាមានឆន្ទៈខ្ពស់ក្នុងការឆ្លើយតបរាល់បញ្ហា និងផ្តល់ជាដំណោះស្រាយសមស្របទៅកាន់សិស្ស និងអាណាព្យាបាលសិស្ស | 4.39 | 0.54 | អនុវត្តខ្ពស់ |
| ១៩ | រាល់ពិន្ទុរបស់សិស្ស និងសមត្ថភាពរបស់សិស្សមានភាពជឿទុកចិត្តបាន | 4.47 | 0.57 | អនុវត្តខ្ពស់ |
| សរុប | | **4.32** | 0.76 | អនុវត្តខ្ពស់ |
| **គ. គណនេយ្យភាពហិរញ្ញវត្ថុ** | | | | |

| | | | | |
|---|---|---|---|---|
| ២០ | សាលាមានគណនេយ្យភាពចំពោះ ក្រសួង មន្ទីរ លើកិច្ចការរដ្ឋបាល និងហិរញ្ញវត្ថុ | 4.37 | 0.60 | អនុវត្តខ្ពស់ |
| ២១ | សាលាបានធ្វើរបាយការណ៍ ***ថវិកាចំណូល*** រៀងរាល់ត្រីមាសទៅគណៈកម្មការគ្រប់គ្រងសាលារៀន និងក្រុមប្រឹក្សាភិបាលថ្នាក់រាជធានី | 4.30 | 0.67 | អនុវត្តខ្ពស់ |
| ២២ | សាលាបានធ្វើរបាយការណ៍ ***ថវិកាចំណាយ***រៀងរាល់ត្រីមាសទៅគណៈកម្មការគ្រប់គ្រងសាលារៀន និងក្រុមប្រឹក្សាភិបាលថ្នាក់រាជធានី | 4.29 | 0.67 | អនុវត្តខ្ពស់ |
| ២៣ | រាល់ថវិកាចំណូល និងចំណាយ មានឯកសារត្រឹមត្រូវតាមបទដ្ឋានគណនេយ្យ | 4.38 | 0.67 | អនុវត្តខ្ពស់ |
| សរុប | | **4.33** | 0.65 | អនុវត្តខ្ពស់ |

| **គណនេយ្យភាពសាលារៀន** | **មធ្យម** | **គម្លាតស្តង់ដា** | **កម្រិតការអនុវត្តន៍** |
|---|---|---|---|
| ក. គណនេយ្យភាពពីដំណើរការសាលារៀន | **4.51** | 0.56 | អនុវត្តខ្ពស់ |
| ខ. គណនេយ្យភាពសិក្សា | **4.32** | 0.76 | អនុវត្តខ្ពស់ |
| គ. គណនេយ្យភាពហិរញ្ញវត្ថុ | **4.33** | 0.65 | អនុវត្តខ្ពស់ |
| **សរុបរួម** | **4.41** | 0.66 | អនុវត្តខ្ពស់ |

លទ្ធផលនៃការស្រាវជ្រាវក្នុងតារាងខាងលើ បានបង្ហាញថា គ្រូបង្រៀនបានផ្តល់ទិន្នន័យសរុបពីការអនុវត្តគណនេយ្យភាពសាលារៀន ក្នុងកម្រិត "អនុវត្តខ្ពស់" (មធ្យមភាគពិន្ទុ=៤.៤១ និងមានគម្លាតស្តង់ដា=០.៦៦)។ នៅក្នុងការអនុវត្តគោលការណ៍គណនេយ្យភាពសាលារៀន មានសូចនាករវងធំរបស់គណនេយ្យភាពសាលារៀនមានចំនួនបីគឺ សូចនាករ (ក)គណនេយ្យភាពពីដំណើរការសាលារៀន (ខ) គណនេយ្យភាពសិក្សា និង (គ)គណនេយ្យភាពហិរញ្ញវត្ថុ។ ក្នុងចំណោមសូចនាករវងធំទាំងបី សូចនាករដែលបានមធ្យមភាគពិន្ទុខ្ពស់ជាងគេគឺ សូចនាករ(ក) "គណនេយ្យភាពពីដំណើរការសាលារៀន" ក្នុងកម្រិត "អនុវត្តខ្ពស់" (មធ្យមភាគពិន្ទុ=៤.៥១និងមានគម្លាតស្តង់ដា=០.៥៦) ។ ទោះបីជាសូចនាករដែលមានមធ្យមភាគពិន្ទុខ្ពស់ជាងគេ និងទាបជាងគេយ៉ាងណាដោយក៏ស្ថិតក្នុងកម្រិតមួយនៃការអនុវត្តខ្ពស់ដដែល។

### ៣. នីតិរដ្ឋ (ភាពអាចគ្រោងទុកបាន)

| ល.រ | បរិយាយ | មធ្យម | គម្លាតស្តង់ដា | កម្រិតការអនុវត្តន៍ |
|---|---|---|---|---|
| ២៤ | សាលាមានស្វ័យភាពក្នុងការពង្រីកកម្មវិធីសិក្សាដោយមានការទទួលខុសត្រូវ (បំណិនជីវិត, ភាសាអង់គ្លេស) | 4.48 | 0.59 | អនុវត្តខ្ពស់ |
| ២៥ | សាលាអាចធ្វើសេចក្តីសម្រេចចិត្តក្នុងការវាយតម្លៃគ្រូប្រចាំឆ្នាំដើម្បីតម្លើងប្រាក់ឧបត្ថម្ភក្នុងកម្រិត Gold, Silver, Bronze ដោយផ្អែកគោលការណ៍សាលារៀន | 3.99 | 1.29 | អនុវត្តខ្ពស់ |
| ២៦ | សាលាផ្តល់សិទ្ធជូនប្រធាន អនុប្រធានក្រុមបច្ចេកទេសក្នុងការកំណត់នីតិវិធីធ្វើកិច្ចតែងការបង្រៀន ឆ្លើយតបនឹងកម្មវិធីសិក្សាលម្អិត | 4.50 | 0.55 | អនុវត្តខ្ពស់ |
| ២៧ | សាសាបានធ្វើស្វ័យវាយតម្លៃ បុគ្គលិក គ្រូបង្រៀន រៀងរាល់ឆ្នាំសិក្សា | 4.65 | 0.52 | អនុវត្តខ្ពស់ |
| ២៨ | សាលាបានរៀបចំផែនការថវិកាជាមួយភាគីពាក់ព័ន្ធ (ឧ.គណៈគ្រប់គ្រង គ្រូបង្រៀន គណៈកម្មការទ្រទ្រង់សាលារៀន) | 4.36 | 0.67 | អនុវត្តខ្ពស់ |
| ២៩ | សាលាមានស្វ័យភាពក្នុងការធ្វើលិខិតបង្គាប់ការក្នុងការតែងតាំងគ្រូបង្រៀនក្នុងតំណែងណាមួយ (ជំនួយការគណៈនាយក, ប្រធានក្រុមបច្ចេកទេស, គណៈកម្មការ..) | 4.43 | 0.68 | អនុវត្តខ្ពស់ |
| ៣០ | សាលាមានស្វ័យភាពរៀបចំធ្វើផែនការបុគ្គលិកដើម្បី ប្រកាសជ្រើសរើសគ្រូបង្រៀនមកសម្ភាសន៍ផ្ទាល់ដោយមានការប្រកួតប្រជែងសមត្ថភាពតាមតម្រូវការ | 4.57 | 0.58 | អនុវត្តខ្ពស់ |
| ៣១ | សាលាមានទំនាក់ទំនង និងធ្វើការចុះអនុស្សរណៈយោគយល់គ្នារវាងសាលារដ្ឋនិងឯកជនទាំងក្នុងប្រទេស និងក្រៅប្រទេស | 4.52 | 0.54 | អនុវត្តខ្ពស់ |
| | សរុប | **4.44** | 0.74 | អនុវត្តខ្ពស់ |

លទ្ធផលនៃការស្រាវជ្រាវដែលទទួលបានពីគ្រូបង្រៀនត្រង់ចំណុចទី៣ "នីតិរដ្ឋ (ភាពអាចគ្រោងទុកបាន)" បានបង្ហាញថា គ្រូបង្រៀនបានផ្តល់ទិន្នន័យជាសុរបពីកម្រិតនៃការអនុវត្ត **នីតិរដ្ឋ** ក្នុងកម្រិត "អនុវត្តខ្ពស់" (មធ្យមភាគពិន្ទុ=៤.៤៤ និងមានគម្លាតស្តង់ដា=០.៧៤))។ សូចនាករដែលបានពិន្ទុខ្ពស់ជាងគេគឺសូចនាករទី២៧ "សាសាបានធ្វើស្វ័យវាយតម្លៃ បុគ្គលិក គ្រូបង្រៀន រៀងរាល់ឆ្នាំសិក្សា" ក្នុងកម្រិត "អនុវត្តខ្ពស់" (មធ្យមភាគពិន្ទុ=៤.៦៥ និងមានគម្លាតស្តង់ដា=០.៥២) រីឯសូចនាករដែលទទួលបានពិន្ទុទាបជាងគេគឺ សូចនាករទី២៥ "សាលាអាចធ្វើសេចក្តីសម្រេចចិត្តក្នុងការវាយតម្លៃគ្រូប្រចាំឆ្នាំដើម្បីតម្លើងប្រាក់ឧបត្ថម្ភក្នុងកម្រិត Gold, Silver, Bronze ដោយផ្អែកគោលការណ៍សាលារៀន" ក្នុងកម្រិត "អនុវត្តខ្ពស់" (មធ្យមភាគពិន្ទុ ៣.៩៩ និងមានគម្លាតស្តង់ដា=១.២៩)។ ទោះបីជាសូចនាករដែល

មានមធ្យមភាគពិន្ទុខ្ពស់ជាងគេ និងទាបជាងគេយ៉ាងណាដោយក៏ស្ថិតក្នុងកម្រិតមួយនៃការអនុវត្តខ្ពស់ដដែល។

**៤. ការចូលរួម**

| ល.រ | **បរិយាយ** | មធ្យម | គម្លាតស្តង់ដា | កម្រិតការអនុវត្តន៍ |
|---|---|---|---|---|
| ៣២ | ការចូលរួមរបស់ បុគ្គលិក គណៈកម្មការគ្រប់គ្រងសាលារៀន ក្នុងការធ្វើផែនការថវិកា ផែនការអភិវឌ្ឍសាលារៀន | 4.31 | 0.74 | អនុវត្តខ្ពស់ |
| ៣៣ | គ្រូបានចូលរួមសិក្ខាសាលាសហគមន៍សិក្សាវិជ្ជាជីវៈ (PLC) | 4.25 | 0.85 | អនុវត្តខ្ពស់ |
| ៣៤ | គ្រូបានចូលរួមសិក្ខាបំប៉នសមត្ថភាពគ្រូបង្រៀន និងការប្រជុំប្រចាំខែ | 4.24 | 0.74 | អនុវត្តខ្ពស់ |
| ៣៥ | គ្រូបានចូលរួមប្រជុំបច្ចេកទេស ឬប្រឹក្សាយោបល់អំពីកិច្ចតែងការបង្រៀន ឬវិធីសាស្ត្របង្រៀនជាប្រចាំ | 4.33 | 0.69 | អនុវត្តខ្ពស់ |
| ៣៦ | គ្រូចូលរួមផលិតធនធានសិក្សា ផលិតជាស្នាដៃផ្សេងៗ សម្រាប់គាំទ្រការបង្រៀន និងរៀន | 4.35 | 0.61 | អនុវត្តខ្ពស់ |
| ៣៧ | គ្រូយកចិត្តទុកចំពោះសិស្ស លើកទឹកចិត្តសិស្ស ស្មារតីក្រុម និងការចូលរួមចែករំលែកបទពិសោធន៍ | 4.50 | 0.50 | អនុវត្តខ្ពស់ |
| ៣៨ | គ្រូបង្រៀនចូលរួមស្ម័គ្រចិត្តក្នុងការគ្រប់គ្រងនិងដឹកនាំក្លិបសិក្សា | 4.54 | 0.52 | អនុវត្តខ្ពស់ |
| ៣៩ | ក្រុមប្រឹក្សាកុមារមានភាពសកម្មក្នុងការចូលរួមក្នុងការងារគ្រប់គ្រងសាលារៀន | 4.30 | 0.73 | អនុវត្តខ្ពស់ |
| ៤០ | គណៈកម្មការគ្រប់គ្រងសាលារៀនសកម្ម និងចូលរួមក្នុងការគ្រប់គ្រងសាលារៀន (ប្រជុំ, ចូលរួមជាយោបល់ និងជាអនុសាសន៍...) | 4.37 | 0.71 | អនុវត្តខ្ពស់ |
| **សរុប** | | **4.35** | 0.69 | អនុវត្តខ្ពស់ |

លទ្ធផលនៃការស្រាវជ្រាវដែលទទួលបានពីគ្រូបង្រៀនត្រង់ចំណុចទី៤ "ការចូលរួម" បានបង្ហាញថា គ្រូបង្រៀនបានផ្តល់ទិន្នន័យជាសរុបពីកម្រិតនៃការអនុវត្ត "ការចូលរួម" ក្នុងកម្រិត "អនុវត្តខ្ពស់" (មធ្យមភាគពិន្ទុ=៤.៣៥ និងមានគម្លាតស្តង់ដា=០.៦៩)។ សូចនាករដែលបានពិន្ទុខ្ពស់ជាងគេគឺសូចនាករទី៣៨ "គ្រូបង្រៀនចូលរួមស្ម័គ្រចិត្តក្នុងការគ្រប់គ្រងនិងដឹកនាំក្លិបសិក្សា" ក្នុងកម្រិត "អនុវត្តខ្ពស់" (មធ្យមភាគពិន្ទុ=៤.៥៤ និងមានគម្លាតស្តង់ដា=០.៥២) ។ សូចនាករដែលទទួលបានពិន្ទុទាបជាងគេគឺសូចនាករទី៣៤ "គ្រូបានចូលរួមសិក្ខាបំប៉នសមត្ថភាពគ្រូបង្រៀន និងការប្រជុំប្រចាំខែ" ក្នុងកម្រិត "អនុវត្តខ្ពស់" (មធ្យមភាគពិន្ទុ ៤.២៤ និងមានគម្លាតស្តង់ដា=០.៧៤)។ ទោះបីជាសូចនាករដែលមាន

មធ្យមភាគពិន្ទុខ្ពស់ជាងគេ និងទាបជាងគេយ៉ាងណាដោយក៏ស្ថិតក្នុងកម្រិតមួយនៃការអនុវត្តខ្ពស់ដដែល។

តារាង 5 ៤.១. លទ្ធផលឆ្លើយតបរបស់គ្រូបង្រៀន

| **សមាសធាតុអភិបាលកិច្ចសាលារៀន** | **មធ្យម** | **គម្លាតស្តង់ដា** | **កម្រិតការអនុវត្តន៍** |
|---|---|---|---|
| **១. តម្លាភាពសាលារៀន** | 4.25 | 0.84 | អនុវត្តខ្ពស់ |
| **២. គណនេយ្យភាពសាលារៀន** | 4.41 | 0.66 | អនុវត្តខ្ពស់ |
| **៣. នីតិរដ្ឋ(ភាពអាចគ្រោងទុកបាន)** | 4.44 | 0.74 | អនុវត្តខ្ពស់ |
| **៤. ការចូលរួម** | 4.35 | 0.69 | អនុវត្តខ្ពស់ |
| **សរុបរួម** | 4.36 | 0.73 | អនុវត្តខ្ពស់ |

លទ្ធផលនៃការស្រាវជ្រាវដូចមានក្នុងតារាងខាងលើ បានបង្ហាញថា គ្រូបង្រៀនបានផ្តល់ទិន្នន័យជាសរុបពីកម្រិតនៃការអនុវត្តគោលការណ៍អភិបាលកិច្ចសាលារៀនទាំង៤ ក្នុងកម្រិត "អនុវត្តខ្ពស់" (មធ្យមភាគពិន្ទុ=៤.៣៦ និងមានគម្លាតស្តង់ដា=០.៧៣) ។ សូចនាករដែលទទួលបានមធ្យមភាគពិន្ទុខ្ពស់ជាងគេគឺ "នីតិរដ្ឋ (ភាពអាចគ្រោងទុកបាន)" ក្នុងកម្រិត "អនុវត្តខ្ពស់" (មធ្យមភាគពិន្ទុ៤.៤៤ និងមានគម្លាតស្តង់ដា=០.៧៤)។ សូចនាករដែលបានមធ្យមភាគពិន្ទុទាបជាងគេគឺ "តម្លាភាពសាលារៀន" (មធ្យមភាគពិន្ទុ=៤.២៥ និងមានគម្លាតស្តង់ដា=០.៨៤)។ ទោះបីជាសូចនាករដែលមានមធ្យមភាគពិន្ទុខ្ពស់ជាងគេ និងទាបជាងគេយ៉ាងណាដោយក៏ស្ថិតក្នុងកម្រិតមួយនៃការអនុវត្តខ្ពស់ដដែល។

### ៤.៣. លទ្ធផលឆ្លើយតបរបស់គណៈគ្រប់គ្រង

### ១. តម្លាភាពសាលារៀន

| ល.រ | បរិយាយ | មធ្យម | គម្លាតស្តង់ដា | កម្រិតការអនុវត្តន៍ |
|---|---|---|---|---|
| ១ | សាលារៀនបានធ្វើការផ្សព្វផ្សាយតារាងតម្លាភាពនៃ *ថវិកាចំណូល* នឹងត្រូវបានបិទផ្សាយនៅចុងខែនីមួយៗប្រចាំខែ | 4.00 | 0.89 | អនុវត្តខ្ពស់ |
| ២ | សាលារៀនបានធ្វើការផ្សព្វផ្សាយតារាងតម្លាភាពនៃ *ថវិកាចំណាយ* នឹងត្រូវបានបិទផ្សាយនៅចុងខែនីមួយៗប្រចាំខែ | 4.00 | 0.89 | អនុវត្តខ្ពស់ |
| ៣ | ការចុះឈ្មោះចូលរៀនរបស់សិស្សក្នុងសាលារៀនជំនាន់ថ្មីបានផ្សព្វផ្សាយទៅកាន់សាធារណៈជនទូទៅ | 4.67 | 0.52 | អនុវត្តខ្ពស់ |

| | | | | |
|---|---|---|---|---|
| ៤ | សាលាបានផ្សព្វផ្សាយរាល់ការប្រឡងជ្រើសរើសសិស្សអាហាររូបករណ៍ក្នុងស្រុក និងក្រៅស្រុកទៅកាន់4សិស្ស និងអាណាព្យាបាល | 4.67 | 0.52 | អនុវត្តខ្ពស់ |
| ៥ | តារាងពិន្ទុប្រចាំខែ ប្រចាំឆមាស និងប្រចាំឆ្នាំតាមមុខវិជ្ជាគោលនីមួយៗបានផ្សព្វផ្សាយទៅកាន់សិស្ស អ្នកអាណាព្យាបាល និងសហគមន៍ | 4.50 | 0.55 | អនុវត្តខ្ពស់ |
| ៦ | សាលាបានឆ្លើយតបរាល់បញ្ហាប្រកបដោយទំនួលខុសត្រូវទៅកាន់អាណាព្យាបាលសិស្ស | 4.67 | 0.52 | អនុវត្តខ្ពស់ |
| ៧ | សាលាបានធ្វើការប្រជុំផ្សព្វផ្សាយពីការសិក្សារបស់សិស្សទៅកាន់អាណាព្យាបាលរៀងរាល់មួយឆ្នាំម្តង | 4.83 | 0.41 | អនុវត្តខ្ពស់បំផុត |
| ៨ | ការបែងចែកថវិកាសាលារៀនដែលបានពីការធ្វើផែនការដើមឆ្នាំឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែងរបស់សាលារៀន | 4.50 | 0.55 | អនុវត្តខ្ពស់ |
| ៩ | សាលាបានឆ្លើយតបនូវសំណើរទិញសម្ភារៈបង្រៀន សម្ភារៈពិសោធន៍ ចាំបាច់របស់គ្រូបង្រៀន | 4.50 | 0.55 | អនុវត្តខ្ពស់ |
| សរុប | | **4.48** | 0.64 | អនុវត្តខ្ពស់ |

លទ្ធផលនៃការស្រាវជ្រាវដូចមានក្នុងតារាងខាងលើ បានបង្ហាញថា គណៈគ្រប់គ្រងសាលាបានផ្តល់ទិន្នន័យជាសរុបពីមធ្យមភាគពិន្ទុនៃការអនុវត្តគោលការណ៍អភិបាលកិច្ច ក្នុងកម្រិត "អនុវត្តខ្ពស់" (មធ្យមភាគពិន្ទុ=៤.៤៨ និងមានគម្លាតស្តង់ដា=0.៦៤) ។ សូចនាករទាំង៩ នៅក្នុងចំណុច ***"តម្លាភាពសាលារៀន"*** ទិន្នន័យបានបង្ហាញឱ្យឃើញថា សូចនាករទី៧ មានមធ្យមភាគពិន្ទុខ្ពស់ជាងគេ "សាលាបានធ្វើការប្រជុំផ្សព្វផ្សាយពីការសិក្សារបស់សិស្សទៅកាន់អាណាព្យាបាលរៀងរាល់មួយឆ្នាំម្តង" ក្នុងកម្រិត "អនុវត្តខ្ពស់បំផុត" (មធ្យមភាគពិន្ទុ=៤.៨៣ និងមានគម្លាតស្តង់ដា=0.៤១) ។ សូចនាករដែលមានមធ្យមភាគពិន្ទុទាបជាងគេក្នុងចំណោមសូចនាករទាំង៩គឺ សូចនាករទី១ "សាលារៀនបានធ្វើការផ្សព្វផ្សាយតារាងតម្លាភាពនៃ***ថវិកាចំណូល*** នឹងត្រូវបានបិទផ្សាយនៅចុងខែនីមួយៗប្រចាំខែ" ក្នុងកម្រិត "អនុវត្តខ្ពស់" (មធ្យមភាគពិន្ទុ=៤.00 និងមានគម្លាតស្តង់ដា=0.៨៩) និងសូចនាករទី២ "សាលារៀនបានធ្វើការផ្សព្វផ្សាយតារាងតម្លាភាពនៃ***ថវិកាចំណាយ*** នឹងត្រូវបានបិទផ្សាយនៅចុងខែនីមួយៗប្រចាំខែ" ក្នុងកម្រិត "អនុវត្តខ្ពស់" (មធ្យមភាគពិន្ទុ=៤.00 និងមានគម្លាតស្តង់ដា=0.៨៩)។ ទោះបីជាសូចនាករដែលមានមធ្យមភាគពិន្ទុខ្ពស់ជាងគេ និងទាបជាងគេយ៉ាងណាដោយក៏ស្ថិតក្នុងកម្រិតមួយនៃការអនុវត្តខ្ពស់ដដែល។

## ២. គណនេយ្យភាពសាលារៀន

| ល.រ | បរិយាយ | មធ្យម | គម្លាតស្តង់ដា | កម្រិតការអនុវត្តន៍ |
|---|---|---|---|---|
| | **ក. គណនេយ្យភាពពីដំណើរការសាលារៀន** | | | |
| ១០ | បុគ្គលិក គ្រូបង្រៀន បំពេញភារកិច្ចបង្រៀនទៀតទាត់ពេលវេលា | 5.00 | 0.00 | អនុវត្តខ្ពស់បំផុត |
| ១១ | គ្រូបង្រៀនបានបំពេញតាមបទដ្ឋានសាលារៀនជំនាន់ថ្មី | 4.67 | 0.52 | អនុវត្តខ្ពស់ |
| ១២ | សាលាមានគណនេយ្យភាពទៅកាន់សិស្សក្នុងការរៀបចំការប្រឡង និងការកែកិច្ចការដោយមិនលម្អៀងតាមរបបពិន្ទុ | 4.67 | 0.52 | អនុវត្តខ្ពស់ |
| ១៣ | សាលារៀនមានគណនេយ្យភាពចំពោះក្រសួង លើគុណភាពនៃការអប់រំ (ផ្អែកតាមនិយាម) | 4.67 | 0.52 | អនុវត្តខ្ពស់ |
| ១៤ | សាលាបានអនុវត្តផែនការកែលម្អសាលារៀន ស្របតាមថវិកាប្រចាំឆ្នាំ | 4.67 | 0.52 | អនុវត្តខ្ពស់ |
| ១៥ | សាលាមានចំណូលគ្រប់គ្រាន់ក្នុងការទ្រទ្រង់ដំណើរការសាលារៀន | 4.50 | 0.55 | អនុវត្តខ្ពស់ |
| សរុប | | **4.69** | 0.47 | អនុវត្តខ្ពស់ |
| | **ខ. គណនេយ្យភាពសិក្សា** | | | |
| ១៦ | សាលាបានឱ្យសិស្សវាយតម្លៃគ្រូរបស់ខ្លួនគ្រប់មុខវិជ្ជា | 4.50 | 0.55 | អនុវត្តខ្ពស់ |
| ១៧ | សាលាមានគណនេយ្យភាពចំពោះរដ្ឋបាលមូលដ្ឋាន ជាពិសេសសិស្ស និងអាណាព្យាបាលលើគុណភាពនៃការរៀនតាមនិយាម | 4.50 | 0.55 | អនុវត្តខ្ពស់ |
| ១៨ | សាលាមានឆន្ទៈខ្ពស់ក្នុងការឆ្លើយតបរាល់បញ្ហា និងផ្តល់ជាដំណោះស្រាយសមស្របទៅកាន់សិស្ស និងអាណាព្យាបាលសិស្ស | 4.33 | 0.52 | អនុវត្តខ្ពស់ |
| ១៩ | រាល់ពិន្ទុរបស់សិស្ស និងសមត្ថភាពរបស់សិស្សមានភាពជឿទុកចិត្តបាន | 4.33 | 0.52 | អនុវត្តខ្ពស់ |
| សរុប | | **4.42** | 0.50 | អនុវត្តខ្ពស់ |
| | **គ. គណនេយ្យភាពហិរញ្ញវត្ថុ** | | | |
| ២០ | សាលាមានគណនេយ្យភាពចំពោះ ក្រសួង មន្ទីរ លើកិច្ចការរដ្ឋបាល និងហិរញ្ញវត្ថុ | 4.50 | 0.55 | អនុវត្តខ្ពស់ |
| ២១ | សាលាបានធ្វើរបាយការណ៍ *<u>ថវិកាចំណូល</u>* រៀងរាល់ត្រីមាសទៅគណៈកម្មការគ្រប់គ្រងសាលារៀន និងក្រុមប្រឹក្សាភិបាលថ្នាក់រាជធានី | 4.83 | 0.41 | អនុវត្តខ្ពស់ |
| ២២ | សាលាបានធ្វើរបាយការណ៍ *<u>ថវិកាចំណាយ</u>* រៀងរាល់ត្រីមាសទៅគណៈកម្មការគ្រប់គ្រងសាលារៀន និងក្រុមប្រឹក្សាភិបាលថ្នាក់រាជធានី | 4.67 | 0.52 | អនុវត្តខ្ពស់បំផុត |
| ២៣ | រាល់ថវិកាចំណូល និងចំណាយ មានឯកសារត្រឹមត្រូវតាមបទដ្ឋានគណនេយ្យ | 4.50 | 0.55 | អនុវត្តខ្ពស់ |
| សរុប | | **4.63** | 0.49 | អនុវត្តខ្ពស់ |

## តារាងសរុបពីគណនេយ្យភាពសាលារៀន

| **គណនេយ្យភាពសាលារៀន** | **មធ្យម** | **គម្លាតស្តង់ដា** | **កម្រិតការអនុវត្តន៍** |
|---|---|---|---|
| ក. គណនេយ្យភាពពីដំណើរការសាលារៀន | **4.69** | 0.47 | អនុវត្តខ្ពស់ |
| ខ. គណនេយ្យភាពសិក្សា | **4.42** | 0.50 | អនុវត្តខ្ពស់ |
| គ. គណនេយ្យភាពហិរញ្ញវត្ថុ | **4.63** | 0.49 | អនុវត្តខ្ពស់ |
| **សរុបរួម** | **4.60** | 0.49 | អនុវត្តខ្ពស់ |

លទ្ធផលនៃការស្រាវជ្រាវដូចមានក្នុងតារាងខាងលើ បានបង្ហាញថា គណៈគ្រប់គ្រងសាលាបានផ្តល់ទិន្នន័យជាសរុបពីពិន្ទុនៃការអនុវត្តគោលការណ៍អភិបាលកិច្ចក្នុងកម្រិត "អនុវត្តខ្ពស់" (មធ្យមភាគពិន្ទុ=៤.៦០ និងមានគម្លាតស្តង់ដា=០.៤៩) ។ សូចនាករវងទាំង៣ នៅក្នុងចំណុច "**គណនេយ្យភាពសាលារៀន**" ទិន្នន័យបានបង្ហាញឱ្យឃើញថា សូចនាករវង "ក" មានមធ្យមភាគពិន្ទុខ្ពស់ជាងគេ "គណនេយ្យភាពពីដំណើរការសាលារៀន" ក្នុងកម្រិត "អនុវត្តខ្ពស់" (មធ្យមភាគពិន្ទុ=៤.៦៩ និងមានគម្លាតស្តង់ដា=០.៤៧) ។ សូចនាករដែលមានមធ្យមភាគពិន្ទុទាបជាងគេក្នុងចំណោមសូចនាករវងទាំង៣ គឺ សូចនាករ "ខ" "គណនេយ្យភាពសិក្សា" ក្នុងកម្រិត "អនុវត្តខ្ពស់" (មធ្យមភាគពិន្ទុ=៤.៤២ និងមានគម្លាតស្តង់ដា=០.៥០)។ ទោះបីជាសូចនាករដែលមានមធ្យមភាគពិន្ទុខ្ពស់ជាងគេ និងទាបជាងគេយ៉ាងណាដោយក៏ស្ថិតក្នុងកម្រិតមួយនៃការអនុវត្តខ្ពស់ដដែល។

### ៣. នីតិរដ្ឋ(ភាពអាចគ្រោងទុកបាន)

| ល.រ | បរិយាយ | មធ្យម | គម្លាតស្តង់ដា | កម្រិតការអនុវត្តន៍ |
|---|---|---|---|---|
| ២៤ | សាលាមានស្វ័យភាពក្នុងការពង្រីកកម្មវិធីសិក្សាដោយមានការទទួលខុសត្រូវ (បំណិនជីវិត, ភាសាអង់គ្លេស) | 4.67 | 0.52 | អនុវត្តខ្ពស់ |
| ២៥ | សាលាអាចធ្វើសេចក្តីសម្រេចចិត្តក្នុងការវាយតម្លៃគ្រូប្រចាំឆ្នាំដើម្បីតម្លើងប្រាក់ឧបត្ថម្ភក្នុងកម្រិត Gold, Silver, Bronze ដោយផ្អែកគោលការណ៍សាលារៀន | 4.33 | 0.52 | អនុវត្តខ្ពស់ |
| ២៦ | សាលាផ្តល់សិទ្ធជូនប្រធាន អនុប្រធានក្រុមបច្ចេកទេសក្នុងការកំណត់នីតិវិធីធ្វើកិច្ចតែងការបង្រៀន ឆ្លើយតបនឹងកម្មវិធីសិក្សាលម្អិត | 4.67 | 0.52 | អនុវត្តខ្ពស់ |
| ២៧ | សាសាបានធ្វើស្វ័យវាយតម្លៃ បុគ្គលិក គ្រូបង្រៀន រៀងរាល់ឆ្នាំសិក្សា | 4.83 | 0.41 | អនុវត្តខ្ពស់បំផុត |
| ២៨ | សាលាបានរៀបចំផែនការថវិកាជាមួយភាគីពាក់ព័ន្ធ (ឧ.គណៈគ្រប់គ្រង គ្រូបង្រៀន គណៈកម្មការទ្រទ្រង់សាលារៀន) | 4.67 | 0.52 | អនុវត្តខ្ពស់ |

| | | | | |
|---|---|---|---|---|
| ២៩ | សាលាមានស្វ័យភាពក្នុងការធ្វើលិខិតបង្គាប់ការក្នុងការតែងតាំងគ្រូបង្រៀនក្នុងតំណែងណាមួយ (ជំនួយការគណៈនាយក, ប្រធានក្រុមបច្ចេកទេស, គណៈកម្មការ..) | 4.50 | 0.55 | អនុវត្តខ្ពស់ |
| ៣០ | សាលាមានស្វ័យភាពរៀបចំធ្វើផែនការបុគ្គលិកដើម្បី ប្រកាសជ្រើសរើសគ្រូបង្រៀនមកសម្ភាសន៍ផ្ទាល់ដោយមានការប្រកួតប្រជែងសមត្ថភាពតាមតម្រូវការ | 4.50 | 0.55 | អនុវត្តខ្ពស់ |
| ៣១ | សាលាមានទំនាក់ទំនង និងធ្វើការចុះអនុស្សរណៈយោគយល់គ្នារវាងសាលារដ្ឋនិងឯកជនទាំងក្នុងប្រទេស និងក្រៅប្រទេស | 4.83 | 0.41 | អនុវត្តខ្ពស់បំផុត |
| សរុប | | **4.63** | 0.49 | អនុវត្តខ្ពស់ |

លទ្ធផលនៃការស្រាវជ្រាវដូចមានក្នុងតារាងខាងលើ បានបង្ហាញថា គណៈគ្រប់គ្រងសាលាបានផ្តល់ទិន្នន័យជាសរុបពីប្រកង់ពិន្ទុនៃការអនុវត្តគោលការណ៍អភិបាលកិច្ច ក្នុងកម្រិត "អនុវត្តខ្ពស់" (មធ្យមភាគពិន្ទុ=៤.៦៣ និងមានគម្លាតស្តង់ដា=០.៤៩) ។ សូចនាករទាំង៨ នៅក្នុងចំណុច "**នីតិរដ្ឋ(ភាពអាចគ្រោងទុកបាន)**" ទិន្នន័យបានបង្ហាញឱ្យឃើញថា សូចនាករទី២៧ មានមធ្យមភាគពិន្ទុខ្ពស់ជាងគេ "សាសាបានធ្វើស្វ័យវាយតម្លៃ បុគ្គលិក គ្រូបង្រៀន រៀងរាល់ឆ្នាំសិក្សា" ក្នុងកម្រិត "អនុវត្តខ្ពស់បំផុត" (មធ្យមភាគពិន្ទុ=៤.៨៣ និងមានគម្លាតស្តង់ដា=០.៤១) និងសូចនាករទី៣១ "សាលាមានទំនាក់ទំនង និងធ្វើការចុះអនុស្សរណៈយោគយល់គ្នារវាងសាលារដ្ឋនិងឯកជនទាំងក្នុងប្រទេស និងក្រៅប្រទេស" ក្នុងកម្រិត "អនុវត្តខ្ពស់បំផុត" (មធ្យមភាគពិន្ទុ=៤.៨៣ និងមានគម្លាតស្តង់ដា=០.៤១) ។ សូចនាករដែលមានមធ្យមភាគពិន្ទុទាបជាងគេក្នុងចំណោមសូចនាករទាំង៨គឺ សូចនាករទី២៩ "សាលាមានស្វ័យភាពក្នុងការធ្វើលិខិតបង្គាប់ការក្នុងការតែងតាំងគ្រូបង្រៀនក្នុងតំណែងណាមួយ (ជំនួយការគណៈនាយក, ប្រធានក្រុមបច្ចេកទេស, គណៈកម្មការ..)" ក្នុងកម្រិត "អនុវត្តខ្ពស់" (មធ្យមភាគពិន្ទុ=៤.៥០ និងមានគម្លាតស្តង់ដា=០.៥៥) និងសូចនាករទី៣០ "សាលាមានស្វ័យភាពរៀបចំធ្វើផែនការបុគ្គលិកដើម្បីប្រកាសជ្រើសរើសគ្រូបង្រៀនមកសម្ភាសន៍ផ្ទាល់ដោយមានការប្រកួតប្រជែងសមត្ថភាពតាមតម្រូវការ" ក្នុងកម្រិត "អនុវត្តខ្ពស់" (មធ្យមភាគពិន្ទុ=៤.៥០ និងមានគម្លាតស្តង់ដា=០.៥៥)។ ទោះបីជាសូចនាករដែលមានមធ្យមភាគពិន្ទុខ្ពស់ជាងគេ និងទាបជាងគេយ៉ាងណាដោយក៏ស្ថិតក្នុងកម្រិតមួយនៃការអនុវត្តខ្ពស់ដដែល។

## ៤. ការចូលរួម

| ល.រ | បរិយាយ | មធ្យម | គម្លាតស្តង់ដា | កម្រិតការអនុត្តន៍ |
|---|---|---|---|---|
| ៣២ | ការចូលរួមរបស់ បុគ្គលិក គណៈកម្មការគ្រប់គ្រងសាលារៀន ក្នុងការធ្វើផែនការថវិកា ផែនការអភិវឌ្ឍសាលារៀន | 4.33 | 0.52 | អនុវត្តខ្ពស់ |
| ៣៣ | គ្រូបានចូលរួមសិក្ខាសាលាសហគមន៍សិក្សាវិជ្ជាជីវៈ (PLC) | 4.33 | 0.82 | អនុវត្តខ្ពស់ |
| ៣៤ | គ្រូបានចូលរួមសិក្ខាបំប៉នសមត្ថភាពគ្រូបង្រៀន និងការប្រជុំប្រចាំខែ | 4.67 | 0.52 | អនុវត្តខ្ពស់ |
| ៣៥ | គ្រូបានចូលរួមប្រជុំបច្ចេកទេស ឬប្រឹក្សាយោបល់អំពីកិច្ចតែងការបង្រៀន ឬវិធីសាស្ត្របង្រៀនជាប្រចាំ | 4.67 | 0.52 | អនុវត្តខ្ពស់ |
| ៣៦ | គ្រូចូលរួមផលិតធនធានសិក្សា ផលិតជាស្នាដៃផ្សេងៗ សម្រាប់គាំទ្រការបង្រៀន និងរៀន | 4.17 | 0.41 | អនុវត្តខ្ពស់ |
| ៣៧ | គ្រូយកចិត្តទុកចំពោះសិស្ស លើកទឹកចិត្តសិស្ស ស្មារតីក្រុម និងការចូលរួមចែករំលែកបទពិសោធន៍ | 4.33 | 0.52 | អនុវត្តខ្ពស់ |
| ៣៨ | គ្រូបង្រៀនចូលរួមស្ម័គ្រចិត្តក្នុងការគ្រប់គ្រងនិងដឹកនាំក្លិបសិក្សា | 4.50 | 0.55 | អនុវត្តខ្ពស់ |
| ៣៩ | ក្រុមប្រឹក្សាកុមារមានភាពសកម្មក្នុងការចូលរួមក្នុងការងារគ្រប់គ្រងសាលារៀន | 4.50 | 0.55 | អនុវត្តខ្ពស់ |
| ៤០ | គណៈកម្មការគ្រប់គ្រងសាលារៀនសកម្ម និងចូលរួមក្នុងការគ្រប់គ្រងសាលារៀន (ប្រជុំ, ចូលរួមជាយោបល់ និងជាអនុសាសន៍...) | 4.67 | 0.52 | អនុវត្តខ្ពស់ |
| សរុប | | **4.46** | 0.54 | អនុវត្តខ្ពស់ |

លទ្ធផលនៃការស្រាវជ្រាវដូចមានក្នុងតារាងខាងលើ បានបង្ហាញថា គណៈគ្រប់គ្រងសាលាបានផ្តល់ទិន្នន័យជាសរុបពីពិន្ទុនៃការអនុវត្តគោលការណ៍អភិបាលកិច្ច ក្នុងកម្រិត "អនុវត្តខ្ពស់" (មធ្យមភាគពិន្ទុ=៤.៤៦) ។ សូចនាករទាំង៩ នៅក្នុងចំណុច "**ការចូលរួម**" ទិន្នន័យបានបង្ហាញឱ្យឃើញថា សូចនាករលេខ៣៤ "គ្រូបានចូលរួមសិក្ខាបំប៉នសមត្ថភាពគ្រូបង្រៀន និងការប្រជុំប្រចាំខែ" មានមធ្យមភាគពិន្ទុខ្ពស់ជាងគេ ក្នុងកម្រិត "អនុវត្តខ្ពស់" (មធ្យមភាគពិន្ទុ=៤.៦៧ និងមានគម្លាតស្តង់ដា=០.៥២), សូចនាករទី៣៥ "គ្រូបានចូលរួមប្រជុំបច្ចេកទេស ឬប្រឹក្សាយោបល់អំពីកិច្ចតែងការបង្រៀន ឬវិធីសាស្ត្របង្រៀនជាប្រចាំ" ក្នុងកម្រិត "អនុវត្តខ្ពស់" (មធ្យមភាគពិន្ទុ=៤.៦៧ និងមានគម្លាតស្តង់ដា=០.៥២) និងសូចនាករទី៤០ "គណៈកម្មការគ្រប់គ្រងសាលារៀនសកម្ម និងចូលរួមក្នុងការគ្រប់គ្រងសាលារៀន (ប្រជុំ, ចូលរួមជាយោបល់ និងជាអនុសាសន៍...)" ក្នុងកម្រិត "អនុវត្តខ្ពស់" (មធ្យមភាគពិន្ទុ=៤.៦៧ និងមាន

គម្លាតស្តង់ដា=០.៥២)។ សូចនាករដែលមានមធ្យមភាគពិន្ទុទាបជាងគេក្នុងចំណោមសូចនាករងទាំង៩ គឺ សូចនាករទី៣៦ "គ្រូចូលរួមផលិតធនធានសិក្សា ផលិតជាស្នាដៃផ្សេងៗ សម្រាប់គាំទ្រការបង្រៀន និងរៀន" ក្នុងកម្រិត "អនុវត្តខ្ពស់" (មធ្យមភាគពិន្ទុ=៤.១៧ និងមានគម្លាតស្តង់ដា=០.៤១)។ ទោះបីជាសូចនាករដែលមានមធ្យមភាគពិន្ទុខ្ពស់ជាងគេ និងទាបជាងគេយ៉ាងណាដោយក៏ស្ថិតក្នុងកម្រិតមួយនៃការអនុវត្តខ្ពស់ដដែល។

**តារាង 6 ៤.៣. លទ្ធផលឆ្លើយតបរបស់គណៈគ្រប់គ្រង**

| ការអនុវត្តអភិបាលកិច្ចរបស់គណៈគ្រប់គ្រង | មធ្យម | គម្លាតស្តង់ដា | កម្រិតការអនុវត្តន៍ |
|---|---|---|---|
| **១. តម្លាភាពសាលារៀន** | 4.48 | 0.64 | អនុវត្តខ្ពស់ |
| **២. គណនេយ្យភាពសាលារៀន** | 4.60 | 0.49 | អនុវត្តខ្ពស់ |
| **៣. នីតិរដ្ឋ(ភាពអាចគ្រោងទុកបាន)** | 4.63 | 0.49 | អនុវត្តខ្ពស់ |
| **៤. ការចូលរួម** | 4.46 | 0.54 | អនុវត្តខ្ពស់ |
| **សរុបរួម** | 4.55 | 0.54 | អនុវត្តខ្ពស់ |

លទ្ធផលនៃការស្រាវជ្រាវដូចមានក្នុងតារាងខាងលើ បានបង្ហាញថា គណៈគ្រប់គ្រងបានផ្តល់ទិន្នន័យជាសរុបពីកម្រិតនៃការអនុវត្តគោលការណ៍អភិបាលកិច្ចសាលារៀនទាំង៤ ក្នុងកម្រិត "អនុវត្តខ្ពស់" (មធ្យមភាគពិន្ទុ=៤.៥៥ និងមានគម្លាតស្តង់ដា=០.៥៤) ។ សូចនាករដែលទទួលបានមធ្យមភាគពិន្ទុខ្ពស់ជាងគេគឺ "នីតិរដ្ឋ (ភាពអាចគ្រោងទុកបាន)" ក្នុងកម្រិត "អនុវត្តខ្ពស់" (មធ្យមភាគពិន្ទុ=៤.៦៣ និងមានគម្លាតស្តង់ដា=០.៤៩)។ សូចនាករដែលបានមធ្យមភាគពិន្ទុទាបជាងគេគឺ "ការចូលរួម" (មធ្យមភាគពិន្ទុ=៤.៤៦ និងមានគម្លាតស្តង់ដា=០.៥៤)។ ទោះបីជាសូចនាករដែលមានមធ្យមភាគពិន្ទុខ្ពស់ជាងគេ និងទាបជាងគេយ៉ាងណាដោយក៏ស្ថិតក្នុងកម្រិតមួយនៃការអនុវត្តខ្ពស់ដដែល។

## ៤.៤. លទ្ធផលឆ្លើយតបរបស់គ្រូបង្រៀន និងគណៈគ្រប់គ្រង

តារាង 7 ៤.៤. លទ្ធផលឆ្លើយតបរបស់គ្រូបង្រៀន និងគណៈគ្រប់គ្រង

| សមាសធាតុអភិបាលកិច្ចសាលារៀន | គណៈគ្រប់គ្រង | | គ្រូបង្រៀន | | គ្រូបង្រៀន និងគណៈគ្រប់គ្រង | |
|---|---|---|---|---|---|---|
| | មធ្យម | គម្លាតស្តង់ដា | មធ្យម | គម្លាតស្តង់ដា | មធ្យម | គម្លាតស្តង់ដា |
| ១. តម្លាភាពសាលារៀន | 4.48 | 0.64 | 4.25 | 0.84 | 4.26 | 0.83 |
| ២. គណនេយ្យភាពសាលារៀន | 4.60 | 0.49 | 4.41 | 0.66 | 4.42 | 0.65 |
| ៣. នីតិរដ្ឋ | 4.63 | 0.49 | 4.44 | 0.74 | 4.45 | 0.73 |
| ៤. ការចូលរួម | 4.46 | 0.54 | 4.35 | 0.69 | 4.36 | 0.68 |
| **សរុបរួម** | **4.55** | **0.54** | **4.36** | **0.73** | **4.37** | **0.72** |
| **កម្រិតនៃការអនុវត្ត** | **អនុវត្តកម្រិតខ្ពស់** | | **អនុវត្តកម្រិតខ្ពស់** | | **អនុវត្តកម្រិតខ្ពស់** | |

លទ្ធផលនៃការស្រាវជ្រាវដូចមានក្នុងតារាងខាងលើ បានបង្ហាញថា គ្រូបង្រៀននិងគណៈគ្រប់គ្រង បានផ្តល់ទិន្នន័យឆ្លើយតបជាសរុបពីកម្រិតនៃការអនុវត្តគោលការណ៍អភិបាលកិច្ចសាលារៀនទាំង៤ ក្នុងកម្រិត "អនុវត្តខ្ពស់" (មធ្យមភាគពិន្ទុ=៤.៣៧ និងមានគម្លាតស្តង់ដា=០.៧២) ។ សូចនាករដែលទទួលបានមធ្យមភាគពិន្ទុខ្ពស់ជាងគេគឺ "នីតិរដ្ឋ (ភាពអាចគ្រោងទុកបាន)" ក្នុងកម្រិត "អនុវត្តខ្ពស់" (មធ្យមភាគពិន្ទុ៤.៤៥ និងមានគម្លាតស្តង់ដា=០.៧៣)។ សូចនាករដែលបានមធ្យមភាគពិន្ទុទាបជាងគេគឺ "តម្លាភាពសាលារៀន" (មធ្យមភាគពិន្ទុ=៤.២៦ និងមានគម្លាតស្តង់ដា=០.៨៣)។ ទោះបីជាសូចនាករដែលមានមធ្យមភាគពិន្ទុខ្ពស់ជាងគេ និងទាបជាងគេយ៉ាងណាក៏ដោយក៏ស្ថិតក្នុងកម្រិតមួយនៃការអនុវត្តខ្ពស់ដដែល។

ការកែលម្អអភិបាលកិច្ចសាលារៀនត្រូវបានគេមើលឃើញថា ជាមធ្យោបាយគន្លឹះដ៏សំខាន់មួយសម្រាប់ឈានទៅរកការបង្កើតគំរូអប់រំឱ្យមានគុណភាពខ្ពស់និងមាននិរន្តរភាពដែលមាន លក្ខណៈស្រដៀងទៅនឹងអ្វីដែលគេសង្កេតឃើញមាននៅក្នុងសាលារៀនឯកជន ប៉ុន្តែកម្ររកឃើញនៅក្នុងសាលារៀនរដ្ឋ (ខេប, ២០១៤) ។ របាយការណ៍ ខេប, (២០១៤) ក៏បានបន្ថែមទៀតថា គំរូសាលារៀននេះទទួលបានការវិនិយោគខ្ពស់ ផ្សារភ្ជាប់ទៅនឹងស្តង់ដាថ្មីនៃគណនេយ្យភាព និងអភិបាលកិច្ច និងស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀនសម្រាប់ការសិក្សាសតវត្សទី២១ ។

យោងតាមលទ្ធផលនៃការសិក្សាស្រាវជ្រាវ តាមរយៈកម្រងសំណួរដែលប្រមូលបានពីបុគ្គលិកអប់រំសាលារៀនជំនាន់ថ្មីទាំងពីរបានឱ្យឃើញថា ការអនុវត្តគោលការណ៍អភិបាលកិច្ចនៅសាលារៀនជំនាន់ថ្មីដែលអ្នកសិក្សាស្រាវជ្រាវផ្តោតទៅលើសមាសធាតុធំៗចំនួន៤ ដូចជា តម្លាភាព គណនេយ្យភាព នីតិរដ្ឋ និងការចូលរួម ស្ថិតក្នុងកម្រិតនៃការអនុវត្តខ្ពស់ ។

អ្នកសិក្សាស្រាវជ្រាវនិងធ្វើការសំយោគនូវទិន្នន័យដែលទាញចេញពីសមាសធាតុទាំង៤ខាងលើដូចខាងក្រោម ៖

**(១) តម្លាភាព ៖** ពាក់ព័ន្ធនឹងតម្លាភាពនេះផងដែរ ក្រសួង អប់រំ យុវជន និងកីឡា (២០១៦) បានលើកឡើងថាតម្លាភាពសំដៅលើរាល់វិធាន នីតិវិធី សេចក្តីសម្រេច និងព័ត៌មានពាក់ព័ន្ធទាំងឡាយត្រូវបានបើកចំហជាសាធារណៈ។ ឆ្លងតាមការវិភាគទិន្នន័យដែលទទួលបានពីបុគ្គលិកអប់រំសាលារៀនជំនាន់ថ្មីទាំងពី បានបង្ហាញឱ្យឃើញថា កម្រិតនៃការអនុវត្តគោលការណ៍អភិបាលកិច្ចស្របតាមទ្រឹស្តីដែលក្រសួង អប់រំ យុវជន និងកីឡា ដែលបានដាក់ចេញនោះ ។ កម្រិតនៃការអនុវត្តខ្ពស់នេះកើតចេញពីសាលាមាន នីតិវិធី សេចក្តីសម្រេច ព័ត៌មានពាក់ព័ន្ធទាំងឡាយត្រូវបានប្រជុំផ្សព្វផ្សាយ ទៅកាន់ភាគីពាក់ព័ន្ធជាសាធារណៈ។ ដូចនេះព័ត៌មានសាធារណៈជាកត្តាដ៏សំខាន់មួយសម្រាប់ ឱ្យមានការចូលរួមពីមតិសាធារណៈជនលើការពិនិត្យតាមដានក្នុងការធ្វើសេចកីសម្រេចប្រកបដោយតម្លាភាព។ កាលណាមានតម្លាភាពកាន់តែខ្ពស់កម្រិតអភិបាលកិច្ចក៏មានលក្ខណៈកាន់តែប្រសើរដែរ (ក្រសួងអ.យ.ក, ២០១៦ь)។

**(២) គណនេយ្យភាព ៖** សំដៅទៅលើការអនុវត្តតួនាទី និងភារកិច្ចក្នុងដំណើរការនៃការសម្រេចចិត្តហើយទទួលខុសត្រូវចំពោះទង្វើរបស់ខ្លួន ដោយរាយការណ៍ព្រមទាំងបញ្ជាក់អំពីមូលហេតុដែលខ្លួនបានសម្រេច និងអនុវត្ត (ក្រសួងអ.យ.ក, ២០១៦ь) ។ “គណនេយ្យភាពរបស់សាលារៀនចំពោះសង្គមពង្រឹងគុណភាពអប់រំនៅកម្ពុជា” នេះជាសារខ្លឹរបស់ឯកឧត្តមបណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ក្នុងពិធីសម្ពោធការដាក់ឱ្យអនុវត្តគម្រោងគាំទ្រ ផែនការអនុវត្តគណនេយ្យភាពសង្គម ដំណាក់កាលទី២ នៅថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០២១ និងក្នុងយុទ្ធនាការផ្សព្វផ្សាយការងារ

គណនេយ្យសង្គម។ គណនេយ្យភាពសាលារៀនរួមមាន (១) គណនេយ្យភាពពីដំណើរការសាលារៀន (២) គណនេយ្យភាពសិក្សា (៣) និងគណនេយ្យភាពហរិញ្ញវត្ថុ (ក្រសួង អប់រំ យុវជន និងកីឡា, ២០១៨) ។ ក្រសួង អប់រំ យុវជន និងកីឡា (២០១៨) ក៏បានបន្ថែមទៀតថា លទ្ធផលបានពីការវាយតម្លៃសិស្ស និងសាលារៀន ត្រូវបានយកមកប្រើប្រាស់ដើម្បីបញ្ជាក់គណនេយ្យភាពពីប្រតិបត្តិការណ៍សាលារៀន ។ ភស្តុតាងជាតារាងទិន្នន័យចំនួនការពីរបិទផ្សាយជាសាធារណៈនៅដើមឆ្នាំសិក្សា ដែលបញ្ជាក់នូវគណនេយ្យភាពសាលារៀន ៖ (១) ផែនការកែលម្អសាលារៀននិងថវិកាប្រចាំឆ្នាំ និង (២) ចំណូលរបស់សាលារៀនពីគ្រប់ប្រភេទធនធាន ។

ការសិក្សាស្រាវជ្រាវនេះរកឃើញថា កម្រិតនៃការអនុវត្តគោលការណ៍អភិបាលកិច្ច ក្នុងកម្រិតអុវត្តខ្ពស់អនុវត្តខ្ពស់ ។ កម្រិតនៃការអនុវត្តខ្ពស់នេះកើតចេញពី សាលាអនុវត្តតួនាទីភារកិច្ចប្រកបដោយការទទួលខុសត្រូវខ្ពស់ ចំពោះភាគីពាក់ព័ន្ធដោយបង្ហាញភស្តុតាងជាតារាងទិន្នន័យ និងធ្វើការបិទផ្សាយជាសាធារណៈនៅដើមឆ្នាំសិក្សា បង្ហាញពីផែនការកែលម្អសាលារៀននិងថវិកាប្រចាំឆ្នាំ និង តារាងថវិកាចំណូលរបស់សាលារៀនពីគ្រប់ប្រភេទធនធាន ។ ការសិក្សាស្រាវជ្រាវខាងលើរកឃើញថាស្របទៅនឹងទ្រឹស្តីដែលក្រសួង អប់រំ យុវជន និងកីឡា (២០១៦) ដែលបានដាក់ចេញ។

**(៣) នីតិរដ្ឋ ៖** ដើម្បីធានាឱ្យមានសេចក្តីសម្រេចប្រកបដោយទំនួលខុសត្រូវលើវិធានច្បាប់ចាំបាច់គេត្រូវមានតម្លាភាព និងស្វែងយល់យ៉ាងច្បាស់ពីការធ្វើសេចក្តីសម្រេចចិត្តនោះ ដោយមានការចូលរួមពីមន្ត្រី អង្គការ ក្រសួង ស្ថាប័ន នានាដែលពាក់ព័ន្ធ។ បន្ថែមលើតម្លាភាពក្នុងការធ្វើសេចក្តីសម្រេចនៃភាពអាចគ្រោងទុកបាន និងនីតិរដ្ឋគឺជាកត្តាធ្វើឱ្យកម្រិតអភិបាលកិច្ចកាន់តែប្រសើរ (ក្រសួងអ.យ.ក, ២០១៦b) ។ ការសិក្សាស្រាវជ្រាវនេះក៏បានរកឃើញដែរថា នីតិរដ្ឋ គឺមានការអនុវត្តក្នុងកម្រិតអុវត្តខ្ពស់អនុវត្តខ្ពស់ នៃគោលការណ៍អភិបាលកិច្ច ។ យោងតាមការសិក្សាស្រាវជ្រាវរកឃើញថា កត្តាដែលនាំឱ្យការអនុវត្តនីតិរដ្ឋស្ថិតក្នុងកម្រិតខ្ពស់នោះគឺ សាលាមានស្វ័យភាពក្នុងការរៀបផែនការផ្អែកលើវិធានច្បាប់ដោយមានការចូលរួមពីភាគីពាក់ព័ន្ធ ដូចជា អង្គការខេប ក្រុមប្រឹក្សាភិបាលថ្នាក់ជាតិ ក្រុមប្រឹក្សាភិបាល

ថ្នាក់រាជធានី ។ ម្យ៉ាងវិញទៀតសាលាមានទំនួលខុសត្រូវខ្ពស់លើសេចក្ដីសម្រេចនានាដែលសាលាបានអនុវត្តតួយ៉ាង ស្វ័យភាពក្នុងការពង្រីកកម្មវិធីសិក្សា ការជ្រើសរើសបុគ្គលិក ការវាយតម្លៃបុគ្គលិក និងការរៀបចំផែនការថវិកាប្រចាំឆ្នាំ ប្រកបដោយតម្លាភាព។

(៤) ) **ការចូលរួម ៖** ជាការធ្វើឱ្យមានឥទ្ធិពលលើគោលនយោបាយ និងវិធាន ច្បាប់លើការកំណត់អាទិភាពផែនការ និងយុទ្ធសាស្ត្រ លើសេចក្ដីសម្រេចចិត្ត លើលទ្ធផលនៃសកម្មភាពជាក់លាក់ណាមួយ (ក្រសួងអ.យ.ក, ២០១៦ខ) ។ ក្រសួង អប់រំ យុវជន និងកីឡា (២០១៦) បានកត់សម្គាល់ថាការចូលរួមដែលសំខាន់ចាំបាច់ដើម្បីឱ្យមានអភិបាលកិច្ចកាន់តែល្អ គឺការចូលរួមជាយោបល់ និងដោយផ្ទាល់។ អ្នកពាក់ព័ន្ធអាចចូលរួមក្នុងអភិបាលកិច្ច រួមមានសមាសសភាពដូចជាមន្ត្រីសាធារណៈ សមាជិកក្រុមប្រឹក្សា សមាជិក ក្រុមការងារ ឬគណៈកម្មាធិការនានាជាទីប្រឹក្សា ឬអ្នកពិគ្រោះយោបល់ ជាអ្នកចូលរួមយ៉ាងសកម្មក្នុងកិច្ចប្រជុំពិភាក្សាពិគ្រោះយោបល់នានា ឬការទំនាក់ទំនងតាមមធ្យោបាយណាជាមួយមន្ត្រី ឬអ្នកធ្វើការសម្រេចនោះ។

តាមការបំពេញកម្រងសំណួររបស់បុគ្គលិកអប់រំទាំងពីរសាលាបានបង្ហាញថា ការចូលរួមរបស់ភាគីពាក់ព័ន្ធមានដូចជា គ្រូបង្រៀន គណៈកម្មការគ្រប់គ្រងសាលារៀន ក្រុមប្រឹក្សាកុមារ និងសហគមន៍ គឺមានការចូលរួមយ៉ាងសកម្មផ្អែកតាមទិន្នន័យដែលបានវិភាគរកឃើញថាមានការចូលរួមខ្ពស់ ។ នេះបញ្ជាក់ឱ្យឃើញថា ការចូលរួមចំណែករបស់ភាគីពាក់ព័ន្ធខាងលើ ក្នុងការធ្វើផែនការ ការប្រជុំ និងធ្វើសេចក្ដីសម្រេចនានា ជាមូលដ្ឋានក្នុងការធ្វើឱ្យសេចក្ដីសម្រេចចុងក្រោយមានឥទ្ធិពលទៅច្បាប់ ឬគោលការណ៍ដែលបានកំណត់ស្របតាម ក្រសួងអប់រំ យុវជន និងកីឡា (២០១៦) បានលើកឡើងខាងលើ។

### ៤.៥. ប្រឈមនៃការអនុវត្តគោលការណ៍អនុវត្តអភិបាលកិច្ច

នៅក្នុងគោលបំណងទី២នៃការស្រាវជ្រាវនេះ អ្នកស្រាវជ្រាវប្រើប្រាស់ការអនុវត្តការចុះប្រមូលទិន្នន័យដោយប្រើប្រាស់វិធីសាស្ត្របែបប្រភេទទម្រង់កម្រងសំណួរបើក ដោយរៀបចំព័ត៌មានកំណត់ខ្លឹមសារ និងសំយោគក្របខណ្ឌនៃគោលគំនិតរួមដែលទាក់ទងនិងបញ្ហាប្រឈមដែលសាលាកំពុងតែជួប

ប្រទះ (Main Indicators) **សំខាន់ៗចំនួនបួន គឺ (១) តម្លាភាព (២) គណនេយ្យភាព (៣) នីតិរដ្ឋ និង(៤) ការចូលរួម។**

អ្នកស្រាវជ្រាវ ប្រើវិធីសាស្ត្រប្រមូលទិន្នន័យតាមបែបប្រភេទទម្រង់កម្រងសំណួរបើកដោយអ្នកស្រាវជ្រាវបានខលណាត់ជាមួយគណៈគ្រប់គ្រងទាំងពីរសាលារៀនដែលគាត់មានពេលវេលាដើម្បីផ្តល់ឱកាសឱ្យអ្នកស្រាវជ្រាវបានធ្វើការសម្ភាន់ផ្ទាល់ជាមួយគ្នា ។ ការសម្ភាសន៍ដោយប្រើប្រាស់កម្រងសំណួរជាមធ្យោបាយក្នុងការពង្រីក និងរំលេចចេញនូវរឿងរ៉ាវនានា ដែលពាក់ព័ន្ធនិងការអនុវត្តគោលការណ៍អភិបាលកិច្ចនៅក្នុងសាលារៀនជំនាន់ថ្មី ។ វិធីសាស្ត្រមួយចំនួននៃការប្រមូលទិន្នន័យត្រូវបានប្រើប្រាស់ក្នុងការសម្ភាន៍ គឺសុំការអនុញ្ញាតក្នុងការថតជាខ្សែអាទ៏សម្លេងរបស់គាត់ដោយការសន្ទនានោះប្រកបដោយវិជ្ជាជីវៈ និងធ្វើការកត់ត្រា។ រីឯប្រភេទទម្រង់កម្រងសំណួរបើកវិញគឺធ្វើការសម្ភាសន៍ពីរភាគី គឺ គ្រូបង្រៀនចំនួន១៥នាក់ និងគណៈគ្រប់គ្រងសាលារៀនចំនួន០២នាក់ ។ ខាងក្រោមជាខ្លឹមសារបញ្ហាប្រឈមដែលចាប់ជា Main indicators:

| **ល.រ** | **ខ្លឹមសារ** | **ចំនួនអ្នកសម្ភាសន៍** | **ចម្លើយ** |
|---|---|---|---|
| ១ | តម្លាភាព | ០២នាក់ | -បញ្ហាធ្វើបញ្ជីគណនេយ្យ និងឯកសារមិនទាន់តាមកាលកំណត់ |
| ២ | គណនេយ្យភាព | ១៣នាក់ | ***គណនេយ្យភាពសិក្សា**<br>-សិស្សមិនសូវ ពេញចិត្តនិងលទ្ធផល ទៅតាមកម្រិតសមត្ថភាពរបស់ពួកគេ ព្រោះប្រឡងតាម app សិស្សមិនសូវមានគុណភាព<br>***គណនេយ្យភាពហិរញ្ញវត្ថុ**<br>-សាលាមិនដឹងពីរបៀបចំណាយ សាលាធ្វើតាមទម្លាប់ដែលបានចាយកន្លងមក ។<br>-គ្រូមានភាពខ្លាចរអា មិនសូវហ៊ានបញ្ចេញមតិយោបល់ទេនិងពេលធ្វើផែនការស្នើសុំថវិកាសម្រាប់គាំទ្រការពិសោធន៍ គឺមិនងាយធ្លាក់លុយសោះគឺត្រូវចំណាយថវិកាខ្លួនឯងជាមុនសិន។<br>-រាល់សំណើរបស់គ្រូមួយចំនួនដែលចំណាយប្រាក់មិនត្រូវបានយល់ស្របតាមតម្រូវការភ្លាមៗ |

| | | | |
|---|---|---|---|
| ៣ | នីតិរដ្ឋ | ១២នាក់ | -សាលាមិនទាន់មានសវនកម្មចុះមកមើល ថាតើការអនុវត្តកន្លងមកមានភាពត្រឹមត្រូវបានកម្រិតណា<br>-សាលាមិនដឹងថាតើការចំណាយនិងការធ្វើឯកសារហិរញ្ញវត្ថុមានភាពត្រឹមត្រូវបានកម្រិតណាបើធៀបនឹងរបៀបនៃការធ្វើឯកសាររបស់ក្រសួងហិរញ្ញវត្ថុ<br>*ក្រសួងចុះមកវាយតម្លៃសាលារៀន មិនមានអ្នកជំនាញខាងគណនេយ្យដើម្បីធ្វើការវាយតម្លៃ និងធ្វើសវកម្មឱ្យបានគ្រប់ជ្រុងជ្រោយតាមច្បាប់គណនេយ្យនោះទេ ។<br>-សាលាមានភាពលម្អៀង លើការវាយតម្លៃគ្រូ ផ្អែកលើទម្រង់វាយតម្លៃតែមួយ |
| ៤ | ការចូលរួម | ១៤នាក់ | -ការធ្វើផែនការអភិវឌ្ឍសាលារៀនមានភាពលំបាកព្រោះមានការចូលរួមតិចតួចពីភាគីពាក់ព័ន្ធ និងមិនមានហិរញ្ញវត្ថុគ្រប់គ្រាន់សម្រាប់ធ្វើផែនការ។ (កាលពីដំណាក់កាលដំបូងនៃការបង្កើតសាលារៀនជំនាន់ថ្មី)។<br>-គ្រូបង្រៀន មិនស្ថិតស្ថេរភាព (គ្រូកិច្ចសន្យាមួយឆ្នាំ) ការជ្រើសរើសគ្រូបង្រៀនមកពីគ្រប់ខេត្ត/ក្រុង ចូលមកបម្រើការងារនៅក្រុងភ្នំពេញ ។ គ្រូបង្រៀនត្រូវចំណាយច្រើនលើជីវភាពជាប្រចាំ។<br>- គ្រូបង្រៀននៅក្នុងកម្មវិធីសិក្សាធម្មតាមានការចូលរួមតិចតួចបំផុតក្នុងកម្មវិធីសាលារៀនជំនាន់ថ្មី ដាហេតុធ្វើឱ្យគ្រូកម្មវិធីធម្មតាសល់<br>- បញ្ហាការទទួលសិស្សពីសាលាគោលដៅ<br>-បញ្ហាការទទួលសិស្សពីសាលាគោលដៅ<br>-គណៈគ្រប់គ្រងខ្វះការលើកទឹកចិត្តគ្រូបង្រៀន<br>- គណៈគ្រប់គ្រងមិនសូវស្តាប់មតិបុគ្គលិក<br>- យោបល់គ្រូ មិនសូវមានប្រសិទ្ធភាព<br>- ការអនុម័តភាគច្រើនបានពីគណៈគ្រប់គ្រង<br>-គណៈគ្រប់គ្រងខ្វះការទទួលយកយោបល់ឱ្យគ្រប់ជ្រុងជ្រោយពីគ្រូបង្រៀន |

### ៤.៥.១. តម្លាភាព

យោតាមក្រសួង អប់រំ យុវជន និងកីឡា (២០១៦) តម្លាភាពសំដៅលើរាល់វិធាន នីតិវិធី សេចក្តីសម្រេច និងព័ត៌មានពាក់ព័ន្ធទាំងឡាយត្រូវបានបើកចំហជាសាធារណៈ ។ ផ្អែកតាមការសម្ភាសន៍ផ្ទាល់ពីគណៈគ្រប់គ្រងបានលើកឡើងថា បញ្ហាដែលប្រឈមគឺការធ្វើបញ្ជីស្នាមគណនេយ្យមិនទាន់តាម

កាលកំណត់ប្រចាំខែ ជាហេតុធ្វើឱ្យការបិទផ្សាយមានការយឺតយ៉ាវនៅចុងខែ និងធ្វើការបិទបញ្ជីមិនទាន់ពេលវេលា (គណៈគ្រប់គ្រង, ២០២៣)។ ស្របជាមួយគ្នានេះ ការបិទផ្សាយមិនទាន់ពេលវេលាជាបញ្ហាមួយដែលគ្រូបង្រៀនបានលើកឡើងផងដែរ នេះបើតាមការសម្ភាសន៍ផ្ទាល់ពីលោកគ្រូអ្នកគ្រូ (គ្រូបង្រៀន, ២០២៣)។

### ៤.៥.២. គណនេយ្យភាព

គណនេយ្យភាពសំដៅទៅលើការអនុវត្តតួនាទី និងភារកិច្ចក្នុងដំណើរការនៃការសម្រេចចិត្តហើយទទួលខុសត្រូវចំពោះទង្វើរបស់ខ្លួនដោយរាយការណ៍ព្រមទាំងបញ្ជាក់អំពីមូលហេតុដែលខ្លួនបានសម្រេច និងអនុវត្ត ។ ចំពោះផ្នែកគណនេយ្យភាពហិរញ្ញវត្ថុវិញ គណៈគ្រប់គ្រងសាលាក៏បានឡើងពីបញ្ហាដែរថាសាលាមិនដឹងពីរបៀបចំណាយថវិកាភាគទានឱ្យបានត្រឹមត្រូវតាមលំនាំរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុនៅឡើយ ព្រោះសាលាធ្វើតាមតែទម្លាប់ដែលបានចំណាយកន្លងមក ហើយសាលាក៏បានស្នើទៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឱ្យមកធ្វើការបង្ហាញពីរបៀបរបបនៃការចំណាយ និងធ្វើឯកសារឱ្យត្រឹមត្រូវទៅតាមអ្វីដែលក្រសួងអនុវត្តផងដែរ តែមិនទាន់មានការឆ្លើយតបមកវិញនូវបញ្ហាដែលបានដាក់ស្នើទៅ (គណៈគ្រប់គ្រង, ២០២៣) ។

គណនេយ្យភាពសាលារៀនជាផ្នែកសំខាន់ទី៣នៃប្រព័ន្ធ ៣អា បិទជិត ។ វារួមមាន (១) គណនេយ្យភាពពីដំណើរការសាលារៀន (២) គណនេយ្យភាពសិក្សា (៣) និងគណនេយ្យភាពហរិញ្ញវត្ថុ (ក្រសួង អប់រំ យុវជន និងកីឡា, ២០១៨) ។ គ្រូបង្រៀនដែលអ្នកស្រាវជ្រាវបានជ្រើសរើសធ្វើជាសំណាកបានលើកឡើងភាគច្រើនថា ចំពោះគណនេយ្យភាពដំណើរការសាលារៀន មានបញ្ហាជួបប្រទះគឺ ការប្រើប្រាស់ App សម្រាប់គ្រប់គ្រងដំណើរការក្នុងការបង្រៀន និងរៀន ។ បញ្ហានោះគឺ App មិនទាន់ដំណើរលូន មានភាព Error ពិន្ទុ និង អវត្តមានសិស្ស (គ្រូបង្រៀន, ២០២៣)។ ចំពោះផ្នែកគណនេយ្យភាពហិរញ្ញវត្ថុវិញ គ្រូបង្រៀនមានភាពខ្លាចរអា មិនសូវហ៊ានបញ្ចេញមតិយោបល់ទេ និងពេលធ្វើផែនការស្នើសុំថវិកាសម្រាប់គាំទ្រការពិសោធន៍ ។ ក្នុងនោះដែរការស្នើថវិកាដើម្បីចំណាយប្រើប្រាស់

ដូចជាពិសោធន៍ ឬទិញសម្ភារៈបម្រើឱ្យដំណើរការបង្រៀន និងរៀនត្រូវការប្រើពេលវេលាយូរដើម្បីយកមកចំណាយ ជាហេតុធ្វើឱ្យគ្រូប្រើថវិកាផ្ទាល់ខ្លួនសិនដើម្បីចំណាយលើដំណើរនេះ។

**៤.៥.៣. នីតិរដ្ឋ (ភាពអាចគ្រោងទុកបាន)**

នីតិរដ្ឋ (ភាពអាចគ្រោងទុកបាន) សំដៅទៅលើការធ្វើសេចក្តីសម្រេចចិត្តដោយផ្អែក លើវិធានច្បាប់ច្បាស់លាស់ ។ ការមានវិធានច្បាប់ច្បាស់លាស់អាចនិងធ្វើការសម្រេច ដោយផ្អែកលើវិធានច្បាប់ជាធរមាន មិនមានផ្អែកលើគំនិត ឬអំណាចបុគ្គលទេ (ក្រសួងអ.យ.ក, ២០១៦)។ តួយ៉ាងផ្អែកតាមការសម្ភាសន៍ផ្ទាល់ជាមួយគណៈគ្រប់គ្រងសាលារៀនជំនាន់ថ្មីទាំងពីរបានបង្ហាញថា មិនទាន់មានសវនកម្មចុះមកមើល ថាតើការអនុវត្តកន្លងមកមានភាពត្រឹមត្រូវតាមច្បាប់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងសវនកម្មរបស់ក្រសួង អប់រំ យុវជន និងកីឡាបានកម្រិតណានោះទេ និងមិនដឹងថាតើការធ្វើឯកសារហិរញ្ញវត្ថុមានភាពត្រឹមត្រូវបានកម្រិតណាបើធៀបនឹងក្របខណ្ឌច្បាប់របស់ក្រសួងហិរញ្ញវត្ថុ ។ មួយផ្នែកទៀត នៅពេលដែលក្រសួងអប់រំ យុវជន និងកីឡា ចុះមកវាយតម្លៃសាលារៀន មិនមានអ្នកជំនាញខាងគណនេយ្យ ឬសវនកម្មដើម្បីធ្វើការវាយតម្លៃឱ្យបានគ្រប់ជ្រុងជ្រោយតាមច្បាប់គណនេយ្យនោះទេ (គណៈគ្រប់គ្រង, ២០២៣) ។

ដោយឡែកចំពោះបញ្ហារបស់គ្រូបង្រៀនវិញបានលើកឡើងផងដែរថា ៖

-មានភាពលម្អៀង លើការវាយតម្លៃ ផ្អែកលើទម្រង់វាយតម្លៃតែមួយ

-ខ្វះការលើកទឹកចិត្តពីគណៈគ្រប់គ្រងសាលារៀន

**៤.៥.៤. ការចូលរួម**

ការចូលរួមគឺជាការធ្វើឱ្យមានឥទ្ធិពលលើគោលនយោបាយ និងវិធាន ច្បាប់លើការកំណត់អាទិភាពផែនការ និងយុទ្ធសាស្ត្រ លើសេចក្តីសម្រេចចិត្តលើលទ្ធផលនៃសកម្មភាពជាក់លាក់ណាមួយ (ក្រសួងអ.យ.ក, ២០១៦)។ ដោយឈរលើសេចក្តីសម្រេចចិត្ត ផ្អែកតាមវិធានច្បាប់ និងកំណត់ផែនការអទិភាព សាលាបានជួបបញ្ហាក្នុងការធ្វើផែនការអភិវឌ្ឍសាលារៀន ព្រោះមានការចូលរួមតិចតួច

ពីភាគីពាក់ព័ន្ធ កាលពីឆ្នាំទើបបង្កើតសាលារៀនជំនាន់ថ្មីដំបូង ។ បញ្ហាដែលធ្វើឱ្យការធ្វើផែនការអភិវឌ្ឍសាលារៀនមានការប្រឈមព្រោះ មិនមានហិរញ្ញវត្ថុគ្រប់គ្រាន់ក្នុងការធ្វើហេដ្ឋារចនាសម្ព័ន្ធរបស់សាលារៀនជំនាន់ថ្មី (គណៈគ្រប់គ្រង, ២០២៣)។

បញ្ហាប្រឈមមួយទៀតដែលសាលារៀនជំនាន់ថ្មីទាំងពីរសាលាកំពុងជួបប្រទះនោះគឺ គ្រូមិនមានស្ថេរភាព (គ្រូបង្រៀនធ្វើកិច្ចសន្យាមួយឆ្នាំម្តង) (គណៈគ្រប់គ្រង, ២០២៣)។ ជារៀងឆ្នាំសាលារៀនជំនាន់ថ្មីតែងតែប្រកាសជ្រើសរើសគ្រូបង្រៀនចូលថ្មីនេះបើយោងតាមសេចក្តីប្រកាសជ្រើសរើសចូលបម្រើការងារនៅសាលារៀនជំនាន់ថ្មី និងគ្រូផ្លាស់ប្តូរទីកន្លែងការងារទៅអង្គភាពដើមវិញជារៀងរាល់ឆ្នាំ (ប្រកាស, ២០១៩)។ មួយវិញទៀតគ្រូបង្រៀនដែលកំពុងបង្រៀននៅក្នុងកម្មវិធីសិក្សាធម្មតាមានការចូលរួមតិចតួចបំផុតក្នុងកម្មវិធីសាលារៀនជំនាន់ថ្មី ជាហេតុធ្វើឱ្យគ្រូកម្មវិធីធម្មតាសល់ប្រហែលជាង ៦០នាក់ (សុភ័ក្រ្ត, ២០២៣)។ គណៈគ្រប់គ្រងជានាយកវិទ្យាល័យព្រែកលៀបសាលារៀនជំនាន់ថ្មីក៏បានបន្ថែមទៀតថា បញ្ហាប្រឈមដែលសាលាតែងតែជួបជារៀងរាល់ឆ្នាំនោះគឺ ការទទួលសិស្សពីសាលាគោលដៅ ។ យោងតាមគោលការណ៍សាលារៀនជំនាន់ថ្មី សិស្សទាំងអស់ដែលចុះឈ្មោះចូលរៀននៅសាលារៀនជំនាន់ថ្មីត្រូវឆ្លងកាត់ការប្រឡងឱ្យជាប់ជាមុនសិនទើបមានសិទ្ធចូលរៀន។

ដោយឡែកចំពោះគ្រូបង្រៀនវិញគាត់បានលើកឡើងពីបញ្ហាគ្រូផងដែរដូចជា ៖

- គណៈគ្រប់គ្រងមិនសូវស្តាប់មតិបុគ្គលិក
- យោបល់គ្រូ មិនសូវមានប្រសិទ្ធភាពចំពោះការលើកឡើងរបស់គ្រូ និងខ្វះការទទួលយកយោបល់ឱ្យគ្រប់ជ្រុងជ្រោយ
- ការអនុម័តភាគច្រើនបានពីគណៈនាយក ។

# ជំពូក៥
# សេចក្តីសន្និដ្ឋាន
# និងសំណូមពរ

# ជំពូក៥

# សេចក្តីសន្និដ្ឋាន និងសំណូមពរ

## ៥.១. សេចក្តីសន្និដ្ឋាន

បន្ទាប់ពីធ្វើការសិក្សាស្រាវជ្រាវលើប្រធានបទ "**ស្ថានភាពនៃការអនុវត្តគោលការណ៍អភិបាលកិច្ចនៅសាលារៀនជំនាន់ថ្មី នៅរាជធានីភ្នំពេញ**" រួចមកអ្នកសិក្សាស្រាវជ្រាវបានរកឃើញថាការអនុវត្តគោលការណ៍អភិបាលកិច្ចនៅសាលារៀនជំនាន់ថ្មី នៅរាជធានីភ្នំពេញស្ថិតក្នុង "**អនុវត្តកម្រិតខ្ពស់**" អាចបញ្ជាក់បានថាគណៈគ្រប់គ្រងសាលា គ្រូបង្រៀន និងគណៈកម្មការគ្រប់គ្រងសាលារៀន បានអនុវត្តគោលការណ៍អភិបាលកិច្ចសាលារៀនទាំងបួនមាន គោលការណ៍តម្លាភាព គោលការណ៍គណនេយ្យភាព គោលការណ៍នីតិរដ្ឋ និងគោលការណ៍ការចូលរួមបានយ៉ាងល្អប្រសើរ ។ ដូចគ្នានេះផងដែរ ដោយផ្អែកលើលទ្ធផលនៃការសិក្សាស្រាវជ្រាវនេះ អ្នកស្រាវជ្រាវអាចធ្វើការវាយតម្លៃបានថា គណៈគ្រប់គ្រងនៅសាលារៀនជំនាន់ថ្មីទាំងពីរនៅរាជធានីភ្នំពេញគាត់ពិតជាបានខិតខំបំពេញតួនាទីបានយ៉ាងល្អ ក្នុងនាមជាអ្នកដឹកនាំគ្រប់គ្រងដំណើរការសាលារៀនប្រកបដោយ គុណភាព ភាពឆ្លើយតប និងសុខុដុមនីយកម្មក្នុងអង្គភាពរបស់គាត់យ៉ាងពិតប្រាកដមែន។ ពិតណាស់តួអង្គសំខាន់ក្នុងការធ្វើឱ្យវិស័យអប់រំមានគុណភាពគឺជានាយកសាលារៀន ព្រោះគុណភាពអប់រំគឺជាគុណភាពនាយកសាលារៀន ដោយផ្តោតសំខាន់ទៅលើការពង្រឹងការគ្រប់គ្រង ការពង្រឹងគុណភាពគ្រូ និងកែលម្អការបង្រៀននិងរៀន ដើម្បីឆ្លើយតបទៅនឹងតម្រូវការកំណែទម្រង់ឱ្យមានគុណភាព (ក្រសួង.អ.យ.ក, ២០១៧) ។ នាយកសាលាជាឆ្អឹងខ្នងវិស័យអប់រំដើម្បីឱ្យវិស័យអប់រំកាន់តែមានគុណភាព អ្នកស្រាវជ្រាវសង្ឃឹមថានឹងមានការស្រាវជ្រាវបន្ថែមលំអិតលើការនុវត្តគោលការណ៍តម្លាភាព  និងគោលការណ៍គណនេយ្យភាព របស់នាយកសាលាក្នុងដំណើរការគ្រប់គ្រងសាលារបស់គាត់ ព្រោះលទ្ធផលនៃការស្រាវជ្រាវបានបង្ហាញថា ប្រសិនបើការអនុវត្តគោលការណ៍តម្លាភាព និងគណនេយ្យភាពល្អប្រសើរ និងមានភាពត្រឹមត្រូវកម្រិតខ្ពស់នោះនឹងអាចពង្រឹងទំនុកចិត្តដល់

បុគ្គលិកក្នុងអង្គភាពទាំងអស់ ឱ្យពេញចិត្តអស់ពីបេះដូងក្នុងការចូលរួមជាមួយគ្នាក្នុងដំណើរឆ្ពោះទៅមុខ ដើម្បីធ្វើឱ្យសិស្សានុសិស្សទទួលបានលទ្ធល្អប្រសើរក្នុងកម្រិតស្តង់ដាជាតិ និងអន្តរជាតិ។

ស្របជាមួយគ្នានេះ ក្រសួងអប់រំ យុវជន និងកីឡា (២០២៣) បាននឹងកំពុងរៀបចំចេញជាគោលនយោបាយ ស្តីពីការសម្រួចអាទិភាព នៃកំណែទម្រង់វិស័យអប់រំ សម្រាប់ឆ្នាំ២០២៣-២០២៨ ដោយក្រសួងអប់រំបានកំណត់អាទិភាពស្នូលទី១ គឺ ការពង្រឹងអភិបាលកិច្ចសាលារៀន រួមមាន (១) កំណែទម្រង់នៅថ្នាក់ជាតិ (២) កំណែទម្រង់នៅកម្រិតសាលារៀន ។ ដើម្បីឆ្លើយតបទៅនឹងកំណែទម្រង់វិស័យអប់រំនេះ ក្រសួងអប់រំ យុវជន និងកីឡា (២០២៣) ក៏បានបែងចែកជា៣ប្រភេទផងដែរ សម្រាប់ការកែទម្រង់នៅកម្រិតសាលារៀន ៖ ប្រភេទទី១ សាលារៀនជំនាន់ថ្មី ដោយផ្តោតលើការផ្តល់ស្វ័យភាពក្នុងការអនុវត្តកម្មវិធីសិក្សា ដើម្បីបណ្តុះធនជានមនុស្សមានបំណិនសតវត្សទី២១ ក្នុងនោះគណៈគ្រប់គ្រងសាលារៀន និងគ្រូបង្រៀន ។ ប្រភេទទី២ សាលារៀនគំរូ ដោយផ្តោតលើ ក),សាលារៀនមានគណនេយ្យភាពជាមួយសហគមន៍ និងសម្រេចបានស្តង់ដាសាលារៀនមានប្រសិទ្ធភាព, ខ).សាលារៀនមានស្វ័យភាព ក្នុងការងារផែនការកែលម្អ សាលារៀន ថ្នាក់រៀន និងផ្តល់ការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំដល់គណៈគ្រប់គ្រង និងគ្រូបង្រៀន, គ).សិស្សត្រូវបាន ធ្វើតេស្តស្តង់ដាប្រកបដោយតម្លាភាព និងយុត្តិធម៌ ដើម្បីបម្រើដល់ការកែលម្អការបង្រៀន និងរៀន, ការជួយសិស្ស រៀនយឺត និងផ្តល់ព័ត៌មានដល់មាតាបិតាឬអ្នកអាណាព្យាបាល និងសហគមន៍ ឃ).គ្រូបង្រៀនប្រើប្រាស់ លទ្ធផលតេស្ត ដើម្បីកែលម្អការបង្រៀន និងទទួលបានការអភិវឌ្ឍគុណវុឌ្ឍជាប្រចាំ ង),មាតាបិតា ឬអ្នកអាណាព្យាបាលនិងសហគមន៍ចូលរួមគាំទ្រ និងអភិវឌ្ឍសាលារៀន។ ប្រភេទទី៣ សាលារៀនធម្មតា ផ្តោតលើ ក).ការកែលម្អលទ្ធផលនៃការសិក្សារបស់សិស្សស្របតាមការរកឃើញនៃលទ្ធផលតេស្តវង្វាយតម្លៃការសិក្សារបស់សិស្សថ្នាក់ជាតិ ថ្នាក់ទី៣ ទី៦ ទី៨ និងទី១១ ខ).ការពង្រឹងវត្តមានគ្រូ និងវត្តមានសិស្ស និង គ).ការពង្រឹងការគ្រប់គ្រងតាមសាលារៀន។

លទ្ធផលនៃការសិក្សាស្រាវជ្រាវនៃគោលបំណងទី២ បង្ហាញពីបញ្ហាប្រឈមអ្នកសិក្សាស្រាវជ្រាវអាចចសង្ខេបបានជា ០៦ចំណុច ដូចជា ១). ការធ្វើបញ្ជីស្នាមគណនេយ្យមិនទាន់តាមកាលកំណត់ប្រចាំខែ ជាហេតុធ្វើឱ្យការបិទផ្សាយមានការយឺតយ៉ាវនៅចុងខែ និងធ្វើការបិទបញ្ជីមិនទាន់ពេលវេលា ២). សាលាមិនដឹងពីរបៀបចំណាយថវិកាភាគទានឱ្យបានត្រឹមត្រូវតាមលំនាំរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុនៅឡើយ ព្រោះសាលាធ្វើតាមតែទម្លាប់ដែលបានចំណាយកន្លងមក ៣).មិនទាន់មានសវនកម្មចុះមកពិនិត្យមើលដំណើរការនៃការចំណាយ ថាតើការអនុវត្តកន្លងមកមានភាពត្រឹមត្រូវតាមច្បាប់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងសវនកម្មរបស់ក្រសួង អប់រំ យុវជន និងកីឡាបានកម្រិតណានោះទេ និងមិនដឹងថាតើការធ្វើឯកសារហិរញ្ញវត្ថុ មានភាពត្រឹមត្រូវបានកម្រិតណាបើធៀបនឹងក្របខណ្ឌច្បាប់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ៤).គ្រូមិនមានស្មេរភាព (គ្រូបង្រៀនធ្វើកិច្ចសន្យាមួយឆ្នាំម្តង) ៥). គ្រូបង្រៀននៅក្នុងកម្មវិធីសិក្សាធម្មតាមានការចូលរួមតិចតួចបំផុតក្នុងកម្មវិធីសាលារៀនជំនាន់ថ្មី ជាហេតុធ្វើឱ្យគ្រូកម្មវិធីធម្មតានៅសល់ ៦).បញ្ហាការទទួលសិស្សពីសាលាគោលដៅ ព្រោះយោងតាមគោលការណ៍សាលារៀនជំនាន់ថ្មី សិស្សទាំងអស់ដែលចុះឈ្មោះចូលរៀននៅសាលារៀនជំនាន់ថ្មីត្រូវឆ្លងកាត់ការប្រឡងឱ្យជាប់ជាមុនសិនទើបមានសិទ្ធចូលរៀន ជាហេតុធ្វើឱ្យសល់សិស្សពីសាលាគោលដៅ ឬសិស្សតម្រង់ទិស។

អ្នកសិក្សាស្រាវជ្រាវសង្ឃឹមថា ការសិក្សាស្រាវជ្រាវនេះអាចជំរុញ និងលើកទឹកចិត្តដល់គ្រប់ភាគីពាក់ព័ន្ធទាំងអស់បន្តការចូលរួមអនុវត្តយ៉ាងសកម្មក្នុងការបំពេញភារកិច្ចរៀងខ្លួនឱ្យបានល្អ ឆ្លើយតបទៅនឹងបញ្ហាប្រឈម ដើម្បីបង្កើតបានសមិទ្ធិផល គុណភាពអប់រំ និងលទ្ធផលការសិក្សារបស់សិស្សកាន់តែមានភាពល្អប្រសើរឡើងសមស្របទៅទិសដៅអាទិភាពទី១របស់ក្រសួអប់រំ យុវជន និងកីឡា សម្រាប់ឆ្នាំ ២០២៣-២០២៨ ។

## ៥.២. សំណូមពរ

យោងតាមការរកឃើញ អ្នកស្រាវជ្រាវ សូមលើកឡើងនូវគំនិតយោបល់ ព្រមទាំងសំណូមពរមួយចំនួនសម្រាប់ភាគីពាក់ព័ន្ធដើម្បីចូលរួមលើកកម្ពស់ការអនុវត្តគោលការណ៍អភិបាលកិច្ចសាលារៀនឱ្យកាន់តែប្រសើរជាងនេះដូចជា ៖

- **ក្រសួងអប់រំ យុវជន និងកីឡា**
  - ក្រសួងគួរតែបន្តការចូលរួមខ្ពស់ក្នុងការលើកកម្ពស់ការអនុវត្តគោលការណ៍អភិបាលកិច្ចនៅតាមសាលារៀនបន្ថែមទៀត ។
  - ក្រសួងគួរតែបង្កើតសវនកម្មផ្ទៃក្នុងផ្នែកសាលារៀនជំនាន់ថ្មីមួយ ដើម្បីចុះធ្វើការវាយតម្លៃ និងត្រួតពិនិត្យមើលផ្នែកហិរញ្ញវត្ថុ ថាតើការចំណាយនោះត្រឹមត្រូវតាមគោលការណ៍ច្បាប់ឬទេ។
  - ក្រសួងគួរមានចំណាត់ការ និងដោះស្រាយគ្រូបង្រៀនកម្មវិធីសិក្សាធម្មតាដែលនៅសល់ ឬធ្វើការផ្លាស់ប្តូរទីកន្លែងការងាររបស់ពួកគាត់។
- **មន្ទីរអប់រំ យុវជន និងកីឡា**
  - គួរតែចាត់ចែងសិស្សសាលាគោលដៅ (សិស្សតម្រង់ទិស)ចូលសាលារៀនជំនាន់ថ្មីដែលធ្លងកាត់ការប្រឡងធ្លាក់ ទៅសាលាដែលនៅក្បែរមូលដ្ឋានរបស់សិស្ស ឬធ្វើសេចក្តីប្រកាសមួយសម្រាប់សិស្សទាំងនោះ។
  - មន្ទីរអប់រំ យុវជន និងកីឡា និងជាក្រុមប្រឹក្សាភិបាលថ្នាក់រាជធានីរបស់សាលារៀនជំនាន់ថ្មី គួរតែចុះអធិការកិច្ចផ្ទាល់ ដើម្បីមើលលើគណនេយ្យភាពពីដំណើរការសាលារៀន។

- **គ្រូបង្រៀន**

  - គ្រូគួរបន្តការគោរពតួនាទី ភារកិច្ច ជាបុគ្គលិកអប់រំ ដោយមានទំនួលខុសត្រូវខ្ពស់ចំពោះសិស្ស និងមានមនសិការវិជ្ជាជីវៈខ្ពស់ ដើម្បីបន្តពង្រឹកអភិបាលកិច្ចសាលារៀនស្របតាមទិសដៅសម្រេចអទិភាពទី១ របស់ក្រសួងអប់រំ យុវជន និងកីឡា ២០២៣-២០២៨។

- **សម្រាប់ការសិក្សាស្រាវជ្រាវបន្ត**

ដើម្បីឱ្យលទ្ធផលការសិក្សាស្រាវជ្រាវនេះ អាចយកទៅអនុវត្តន៍កើតជាប្រយោជន៍នាថ្ងៃអនាគត អ្នកសិក្សាស្រាវជ្រាវ មានសំណូមពរសម្រាប់ការសិក្សាបន្តដូចខាងក្រោម៖

- ការឆ្លើយតបរបស់គ្រូបង្រៀនលើ ប្រសិទ្ធភាពនៃការអនុវត្តការងាររបស់គណៈគ្រប់គ្រងសាលារៀនជំនាន់ថ្មី ។
- ផលប៉ះពាល់រវាងការអនុវត្តកម្មវិធីសាលារៀនជំនាន់ថ្មី និងការអនុវត្តកម្មវិធីធម្មតាជាមួយគ្នា ។ ដើម្បីយល់ដឹងឱ្យកាន់តែស៊ីជម្រៅនិងល្អិតល្អន់នោះ សម្រាប់ការសិក្សាស្រាវជ្រាវបន្តគួរប្រើវិធីសាស្ត្របែបគុណវិស័យ (Qualitative Research) បន្ថែមទៀត ដូចជាការសម្ភាសន៍ស៊ីជម្រៅ (In-depth Interview) ការសម្ភាសន៍ជាក្រុម ឬការសន្ទនាក្រុម (Focus Group) ដើម្បីឱ្យបានទិន្នន័យកាន់តែស៊ីជម្រៅ និងច្បាស់លាស់ដែលអាចប្រើជាប្រយោជន៍ក្នុងការយកទៅប្រើប្រាស់ ដើម្បីបន្តបង្កើតសាលារៀនជំនាន់ថ្មីបន្ថែមទៀតស្របតាមគោលដៅរបស់ក្រសួងអប់រំ យុវជន និងកីឡា ។
- ការសិក្សាប្រៀបធៀបទស្សនៈរបស់គ្រូបង្រៀនសាលារៀនជំនាន់ថ្មីនៅរាជធានីភ្នំពេញ និងគ្រូបង្រៀនសាលារៀនជំនាន់ថ្មីនៅតាមបណ្តាខេត្ត លើកម្រិតនៃការអនុវត្តគោលការណ៍អភិបាលកិច្ចក្នុងការគ្រប់គ្រងរបស់គណៈគ្រប់គ្រងសាលារៀនជំនាន់ថ្មី។

# តារាងឧបសម្ព័ន្ធ

## តារាង ៤ ២ .៥.១ ស្តង់ដាទទួលស្គាល់គុណភាពអប់រំសាលារៀនជំនាន់ថ្មី

| លក្ខណៈវិនិច្ឆ័យសេវាកម្មអប់រំ | | ស្ថានភាពលក្ខណៈវិនិច្ឆ័យ | | កំណត់សម្គាល់ |
|---|---|---|---|---|
| | | ដាច់ខាត | ជម្រើស | |
| ១ | បញ្ឈប់ការបង្រៀនគួរ(ភ្ជាប់ជាមួយការឱ្យសិស្សឡើងថ្នាក់) | □ | | |
| ២ | លុបបំបាត់ចោលទម្លាប់បង្គាប់ សិស្សឱ្យទិញទំនិញគ្រូ(ដូចជាលក់នំ សំណៅឯកសារជាដើម ។ល។) | □ | | |
| ៣ | ភស្តុតាងបែងចែកធនធានប្រកបដោយសនិទានភាព | □ | | ចំណូលទាំងអស់ត្រូវប្រគល់ឱ្យសាលា មិនមែនឱ្យបុគ្គលទេ |
| ៤ | ការបង្កើនម៉ោងសិក្សា៖<br>- ៣០ម៉ោង/សប្តាហ៍សម្រាប់បឋមសិក្សា<br>- ៤០ម៉ោង/សប្តាហ៍សម្រាប់មធ្យមសិក្សា | □ | | |
| ៥ | ផែនការគន្លងអាជីពគ្រូបង្រៀន និងប្រព័ន្ធគាំទ្រការបង្រៀនស្វាហាប់ | □ | | តាមលក្ខណៈវិនិច្ឆ័យស្តង់ដាកំណត់ |
| ៦ | មានបណ្ណាល័យទំនើបសតវត្សទី២១ | □ | | តាមលក្ខណៈវិនិច្ឆ័យស្តង់ដាកំណត់ |
| ៧ | មានភស្តុតាងបង្ហាញពីសហគមន៍វិជ្ជាជីវៈគ្រូបង្រៀន | □ | | តាមលក្ខណៈវិនិច្ឆ័យស្តង់ដាកំណត់ |
| ៨ | មានភស្តុតាងសិស្សប្រើប្រាស់បច្ចេកវិទ្យាមានក្នុងអត្រាខ្ពស់ | □ | | កំណត់យកអត្រា៧៥% |
| ៩ | មានសេវាបន្ទប់កុំព្យូទ័រ | □ | | តាមលក្ខណៈវិនិច្ឆ័យស្តង់ដាកំណត់ |
| ១០ | មានសម្ភារៈបរិក្ខាបន្ទប់ពិសោធវិទ្យាសាស្ត្រ | □ | | តាមលក្ខណៈវិនិច្ឆ័យស្តង់ដាកំណត់ |
| ១១ | ផលធៀបថ្នាក់ សិស្ស សមស្របក្នុងថ្នាក់រៀនភាគជាច្រើន | □ | | ចំនួនសិស្សត្រឹម៣៦នាក់ ឬតិចជាងនេះក្នុងថ្នាក់យ៉ាងតិច៨០% |
| ១២ | ភស្តុតាងនៃតម្លាភាពក្នុងរបាយការណ៍ហិរញ្ញវត្ថុដោយបានសង្ខេបបង្ហាញចំណូល និងចំណាយ | □ | | តាមលក្ខណៈវិនិច្ឆ័យស្តង់ដាកំណត់ |
| ១៣ | មានភស្តុតាងបង្ហាញថា ក្រុមប្រឹក្សាកុមារសេកម្ម និងចូលរួមក្នុងការគ្រប់គ្រងសាលា | | □ | តាមលក្ខណៈវិនិច្ឆ័យស្តង់ដាកំណត់ |

| | | | | |
|---|---|---|---|---|
| ១៤ | ភស្តុតាងដែលគណៈកម្មការទ្រទ្រង់សាលាមានភាពសកម្ម និងចូលរួមយ៉ាងពេញលេញក្នុងការគ្រប់គ្រងសាលា | | □ | តាមលក្ខណៈវិនិច្ឆ័យស្តង់ដាកំណត់ |
| ១៥ | ភស្តុតាងគ្រូប្រើបច្ចេកវិទ្យាថ្មីក និងមានអត្រាខ្ពស់ | | □ | តាមការអង្កេតការប្រើបច្ចេកវិទ្យាស្ទាត់ជំនាញ |
| ១៦ | ភស្តុតាងនៃសេវាប្រឹក្សាអាជីព (សម្រាប់មធ្យមសិក្សា) | | □ | តាមលក្ខណៈវិនិច្ឆ័យស្តង់ដាកំណត់ |
| ១៧ | បន្ទប់រៀនភាគច្រើនមានអនាម័យល្អ និងមានភាពទាក់ទាញ | | □ | តាមលក្ខណៈវិនិច្ឆ័យស្តង់ដាកំណត់ |
| ១៨ | ស្តង់ដាខ្ពស់នៃអនាម័យក្នុងបង្គន់អនាម័យ និងសេវាទឹកស្អាត | | □ | តាមលក្ខណៈវិនិច្ឆ័យស្តង់ដាកំណត់ |
| ១៩ | មានទីលានកីឡា និងបរិក្ខាកីឡា | | □ | តាមលក្ខណៈវិនិច្ឆ័យស្តង់ដាកំណត់ |
| ២០ | ភស្តុតាងនៃកម្មវិធីអប់រំបំណិនជីវិតដោយប្រើកម្មវិធីសិក្សាអនុម័តដោយក្រសួង | | □ | តាមលក្ខណៈវិនិច្ឆ័យស្តង់ដាកំណត់ |
| ២១ | មានកម្មវិធីអំណានសៀវភៅល្បីៗ | | □ | តាមលក្ខណៈវិនិច្ឆ័យស្តង់ដាកំណត់ |
| ២២ | មានសេវាអាហារដ្ឋានសម្រាប់សិស្ស | | □ | តាមលក្ខណៈវិនិច្ឆ័យស្តង់ដាកំណត់ |
| ២៣ | គ្រូបង្រៀននៅសាលារៀនជំនាន់ថ្មីមានគុណវុឌ្ឍិខ្ពស់ | | □ | គ្រូបង្រៀនយ៉ាងតិច៨០% មានបរិញ្ញាបត្រ ឬសញ្ញាបត្រខ្ពស់ជាងនេះ |
| ២៤ | មានសេវាគ្លីនិកសម្រាប់បម្រើសិស្ស | | □ | |

- (*ពីឧបសម្ព័ន្ធទី៤៖ សង្ខេបស្តង់ដាទទួលស្គាល់គុណភាព*) (ក្រសួង.អ.យ.ក, ២០២០)

## តារាង ១ ២.១០.២ ទម្រង់សម្រាប់វាយតម្លៃការងារគ្រូបង្រៀន

| | | | |
|---|---|---|---|
| **ឈ្មោះគ្រូ:** | | **ឈ្មោះសាលារៀន:** | |
| បង្រៀន | ☐ គ្រូអនុវិទ្យាល័យ ☐ វិទ្យាល័យ | ភេទ: | ☐ ប្រុស / ☐ ស្រី |
| មុខវិជ្ជា *(សូមគូសវង់គ្រប់ចំណុចដែលមាន)* | ភាសាខ្មែរ, គណិតវិទ្យា ,គីមីវិទ្យា, រូបវិទ្យា , ជីវវិទ្យា, ភូមិវិទ្យា, ភាសាអង់គ្លេស ,ប្រវត្តិវិទ្យា, ផែនដីវិទ្យា, គេហកិច្ច,កីឡា,សិល្បៈ,*ICT,*<br>មុខវិជ្ជាផ្សេងទៀត:<br>____________________ | - សញ្ញាបត្រ**ទទួលបាន**<br>*(សូមគូសវង់គ្រប់ចំណុចដែលមាន)*<br><br>- សញ្ញាបត្រ **នឹងទទួលបាន** **ឆ្នាំសិក្សា** ........................<br>*(សូមគូសវង់គ្រប់ចំណុចដែលមាន)* | *បរិញ្ញាបត្រ/បរិញ្ញាបត្រវិទ្យាសាស្ត្រ*<br>*បរិញ្ញាបត្រជាន់ខ្ពស់/បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកវិទ្យាសាស្ត្រ*<br>*សញ្ញាបត្រពីវិទ្យាស្ថានជាតិអប់រំ*<br>*សញ្ញាបត្រផ្សេងទៀត:* .............<br>*បរិញ្ញាបត្រ/បរិញ្ញាបត្រវិទ្យាសាស្ត្រ*<br>*បរិញ្ញាបត្រជាន់ខ្ពស់/បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកវិទ្យាសាស្ត្រ*<br>*សញ្ញាបត្រពីវិទ្យាស្ថានជាតិអប់រំ*<br>*សញ្ញាបត្រផ្សេងទៀត:* ........................ |
| *ប្រភេទថវិកាលើកទឹកចិត្តទទួលបាន* | ☐ *ប្រាក់លើកទឹកចិត្តថេរ*<br>☐ *ប្រាក់លើកទឹកចិត្តតាមសកម្មភាព* | *អ្នកបំពេញទម្រង់៖ តួនាទី*<br>------------------------------<br>------------------------------<br>------------------------------<br>------------------------------ | |
| *កាលបរិច្ឆេទបំពេញ៖* | .............ខែ ... ឆ្នាំ | *មូលដ្ឋានវាយតម្លៃ* | ☐ *ការសង្កេត*<br>☐ *ការសម្ភាសន៍* |

| *ល.រ* | ***បញ្ជីវាយតម្លៃ*** | ***ពិន្ទុ*** |
|---|---|---|
| 1. | *តើគ្រូបង្រៀនរូបនេះមកបំពេញភារកិច្ចបង្រៀន**ទៀងទាត់ពេលវេលា**កម្រិតណា?*<br>☐ *ទៀងទាត់ល្អណាស់* ☐*ទៀងទាត់* ☐ *ជួនកាលយឺត* ☐ *យឺតញឹកញាប់* | **5 4 3 0** |

| | | |
|---|---|---|
| 2. | តើគ្រូបង្រៀនរូបនេះបំពេញភារកិច្ចបង្រៀនបានពេញលេញកម្រិតណា ?<br>☐ ល្អឥតខ្ចោះ ☐ល្អណាស់ ☐ ល្អបង្គួរ ☐ ខ្សោយ<br>☐ គ្រូរូបនេះមិនដែលស្នើសុំបំពេញការងារទេ។ សូមបញ្ជាក់ការងារដែលត្រូវបំពេញ ( ឧ. ការដឹកនាំក្លឹប ដឹកនាំសិស្សអនុវត្តគម្រោង។ល។)………………………………………………………………………… | 5 4 3 2 0 |
| 3. | តើគ្រូបង្រៀនរូបនេះថែរក្សា និងបំពេញព័ត៌មានក្នុងកំណត់ត្រាផ្លូវការជីពគ្រូបានល្អកម្រិតណា ?<br>☐ ល្អឥតខ្ចោះ ☐ល្អណាស់ ☐ល្អបង្គួរ ☐ខ្សោយ | 5 4 3 0 |
| 4. | តើគ្រូបង្រៀនរូបនេះប្រើប្រាស់បច្ចេកវិទ្យាព័ត៌មានក្នុងការបង្រៀនច្រើនកម្រិតណា ?<br>☐ ច្រើនប្រភេទណាស់ ☐ ច្រើនប្រភេទ ☐ តិចតួច ☐ មិនដែលប្រើទេ | 5 4 1 0 |
| 5. | តើគ្រូរូបនេះបានបញ្ច្រាបវិធីសាស្ត្របង្រៀនថ្មីៗដែលទទួលបានពីសិក្ខាសាលាទៅក្នុងសកម្មភាពបង្រៀនបានល្អកម្រិតណា ?<br>☐ ប្រើកម្រិតខ្ពស់ ☐ ប្រើកម្រិតមធ្យម ☐ ប្រើកម្រិតទាប ☐ មិនប្រើសោះ | 5 4 1 0 |
| 6. | ពេលបង្រៀន តើគ្រូរូបនេះបានត្រៀមលក្ខណៈទុកមុនល្អកម្រិតណា ?<br>☐ ត្រៀមលក្ខណៈទុកមុនល្អណាស់ ☐ត្រៀមលក្ខណៈបានល្អ ☐ ត្រៀមបានខ្លះ<br>☐ ត្រៀមលក្ខណៈមិនបានល្អ | 5 4 3 0 |
| 7. | តើគ្រូរូបនេះបានចូលរួមសិក្ខាសាលាពង្រឹងសមត្ថភាពបានញឹកញាប់ប៉ុនណា ?<br>☐ចូលរួមបានល្អណាស់ ☐ ចូលរួមបានមធ្យម ☐ ចូលរួមបានតិចតួច ☐ មិនបានចូលរួមសោះ | 5 4 3 0 |
| 8. | តើគ្រូរូបនេះធ្លាប់ស្នើសុំប្រាក់ឧបត្ថម្ភតាមការកិច្ចសម្រាប់កិច្ចការដែលគាត់មិនបានធ្វើដែរឬទេ ?<br>☐ ញឹកញាប់ ☐ ពេលខ្លះ ☐មិនដែលទេ | -5 -3 +5 |
| 9. | តើគ្រូរូបនេះដែលមានស្នាដៃលេចធ្លោនៅក្នុងសាលារៀនដែរឬទេ ?<br>☐ មាន ☐ គ្មានទេ<br>បើមាន តើស្នាដៃអ្វី? ………………………………………………………………………… | 5 0 |
| 10. | តើគ្រូរូបនេះធ្លាប់បង្រៀនគួរបំពានលើវិន័យសាលាដែរឬទេ ? (សម្រាប់តែសិស្សសាលាខ្លួនឯងប៉ុណ្ណោះ)<br>☐ ញឹកញាប់ ☐ ជួនកាល ☐មិនដែលបង្រៀនទេ | -5 -3 +5 |
| 11. | តើជារួមគ្រូរូបនេះបានបំពេញតាមបទដ្ឋានសាលារៀនជំនាន់ថ្មីបានល្អកម្រិតណា ?<br>☐បំពេញបានកម្រិតខ្ពស់ណាស់ ☐ បំពេញបានកម្រិតមធ្យម ☐ បំពេញបានកម្រិតខ្សោយ | 5 3 0 |
| 12. | នៅក្នុងសហគមន៍ពង្រឹងសមត្ថភាពវិជ្ជាជីវៈរបស់សាលា(PLC) តើគ្រូរូបនេះសកម្មកម្រិតណា ?<br>☐ បង្ហាញភាពដឹកនាំយ៉ាងសកម្ម ក្នុងន័យធ្វើឱ្យសហគមន៍នេះដំណើរការបានល្អ។ | 5 4 3 0 0 |

| | | |
|---|---|---|
| | ☐ ចូលរួមជាសមាជិកយ៉ាងសកម្ម ក្នុងការចែករំលែកព័ត៌មាន និងចំណេះដឹង<br>☐ ចូលរួមជាសមាជិកក្នុងកម្រិតបទដ្ឋានអប្បបរមា<br>☐ មិនបានចូលរួមជាសមាជិកទេ<br>☐ សាលារៀនគ្មានសហគមន៍នេះទេ | |
| 13. | តើគ្រូរូបនេះ**ប្រើប្រាស់បណ្ណាល័យជាធនធានសម្រាប់បង្រៀនសិស្ស**បានល្អកម្រិតណា ?( សូមជ្រើសរើសគ្រប់សកម្មភាពដែលគ្រូបានធ្វើតាមការសង្កេត )<br>☐ ដាក់កិច្ចការឱ្យសិស្សទៅស្រាវជ្រាវក្នុងបណ្ណាល័យ<br>☐ ដាក់សកម្មភាពឱ្យសិស្សធ្វើដោយប្រើឧបករណ៍អេឡិកត្រូនិចចល័ត<br>☐ ប្រើឧបករណ៍សោទស្សន៍ដូចជាការបង្រៀនតាមកម្មវិធីទស្សនា<br>☐ កំណត់សៀវភៅឱ្យសិស្សអានក្នុងក្របខ័ណ្ឌទៀងទាត់<br>☐ ប្រាប់ឱ្យសិស្សទៅបណ្ណាល័យ ☐ មិនដែលសោះ | **5 4 3 2 1 0** |
| 14. | តើគ្រូបង្រៀនរូបនេះ**ធ្លាប់ប្រើសម្ភារៈ ឬខ្លឹមសារក្រៅកម្មវិធីដើម្បីពង្រីកខ្លឹមសារមេរៀន**ដែរឬទេ ?<br>☐បានធ្វើញឹកញាប់ ☐ ធ្វើជាហូរហែ ☐ កម្រធ្វើ ឬមិនដែលបានធ្វើទេ | **5 3 0** |
| 15. | តើគ្រូបង្រៀនរូបនេះ**ធ្លាប់កែលម្អ រឺធ្វើបច្ចុប្បន្នភាពកិច្ចតែងការដើម្បីពង្រីកខ្លឹមសារមេរៀន**ដែរឬទេ ?<br>☐បានធ្វើញឹកញាប់គ្រប់មេរៀន ☐ ធ្វើជាហូរហែ ☐ ធ្វើបានខ្លះៗ ☐ កម្រធ្វើ ☐ មិនដែលបានធ្វើ | **5 3 2 1 0** |
